**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**


**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៩

ឈ្មោះស្ថាប័ន៖ **ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា** (CSX)


តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **យិន ចរិយា**

**ម៉ុន តារាច័ន្ទ**

សាស្ត្រាចារ្យណែនាំ

លោក **សួន ចំរើន**


ថ្នាក់បរិញ្ញាបត្រ គ្រប់គ្រងធុរកិច្ច

ជំនាន់ទី ០៣

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេររបាយការណ៍ ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ឃិន ចរិយា** និង **ប៊ុន តារាច័ន្ទ** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងធុរកិច្ច ឆ្នាំទី ៤ ជំនាន់ទី ៣ ក្រុម $M_4A_2$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨-២០១៩ សូមគោរពថ្លែងអំណរគុណ និងសំដែងនូវកត្តញ្ញូតាធមិដ៏ជ្រាលជ្រៅបំផុតជូនចំពោះ៖

**លោកឪពុក និងអ្នកម្តាយ ជាអ្នកមានគុណដ៏ក្រៃលែង** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅ ទំនុកបំរុងរាល់ការខ្វះខាត និងផ្គត់ផ្គង់រាល់សម្ភារៈប្រើប្រាស់ និងថវិកា ដើម្បីឲ្យកូនបានក្រេបជញ្ជក់ចំណេះវិជ្ជា ដើម្បីជាថ្នូរទៅថ្ងៃអនាគត។ ម្យ៉ាងវិញទៀត លោកទាំងពីរក៏បានពលីទាំងកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីឲ្យកូនបានក្លាយជាកូនល្អ និងពលរដ្ឋល្អក្នុងសង្គមដូចសព្វថ្ងៃនេះ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធិបុរស ព្រឹទ្ធិបុរសរង លោក លោកស្រី សាស្ត្រាចារ្យ និងបុគ្គលិក**ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ក្នុងការអប់រំទូន្មាន បង្ហាត់បង្រៀន និងខិតខំផ្តល់ចំណេះដឹងដល់យើងខ្ញុំដោយមិនខ្លាចនឿយហត់ ដើម្បីបណ្តុះបណ្តាលឲ្យយើងខ្ញុំក្លាយជាធនធានមនុស្សដ៏មានគុណភាព ដើម្បីបំពេញតម្រូវការសង្គម និងប្រទេសជាតិ។

**លោកសាស្ត្រាចារ្យ សួន ចំរើន** ជាសាស្ត្រាចារ្យណែនាំក្នុងការស្រាវជ្រាវ និងសរសេររបាយការណ៍បញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំ លោកសាស្ត្រាចារ្យបានជួយណែនាំ ចង្អុលបង្ហាញ ផ្តល់ជាអនុសាសន៍ល្អៗ និងព័ត៌មានដែលទាក់ទង ដើម្បីជាជំនួយក្នុងការស្រាវជ្រាវរបាយការណ៍មួយច្បាប់នេះ។ ជាពិសេសលោកបានផ្តល់ជាយោបល់ និងជួយកែតម្រូវនូវរាល់ចំណុចខ្វះខាតដែលកើតមានឡើងក្នុងអំឡុងពេលនៃការរៀបចំរបាយការណ៍បញ្ចប់ការសិក្សានេះផងដែរ។

**ឯកឧត្តមអគ្គនាយក និងឯកឧត្តមអគ្គនាយករង**នៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងបណ្តាបុគ្គលិកគ្រប់ជាន់ថ្នាក់ ជាពិសេស**លោក ហៃ លីដេត** ប្រធាននាយកដ្ឋានចុះបញ្ជី និងផ្តល់ព័ត៌មាន ដែលបានអនុញ្ញាតឲ្យយើងខ្ញុំទាំងពីរ បានមានឱកាសចុះកម្មសិក្សាផ្ទាល់នៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជានេះ។ **អ្នកស្រី យូ កញ្ញារី** ដែលបានឆ្លៀតពេលវេលាដ៏មមាញឹកមកជួយពន្យល់ណែនាំ ផ្តល់ជាឯកសារផ្សេងៗ និងទិន្នន័យសំខាន់ៗ សម្រាប់ជាគ្រឹះក្នុងការសរសេររបាយការណ៍

កម្មសិក្សាមួយច្បាប់នេះ។ យើងខ្ញុំទាំងពីរ មានអារម្មណ៍រំភើបរីករាយ ដែលបានទទួលការស្វាគមន៍យ៉ាងរាក់ទាក់ និងកក់ក្ដៅពីសំណាក់ក្រុមការងារនៃនាយកដ្ឋានចុះបញ្ជី និងផ្ដល់ព័ត៌មានទាំងមូល។

រៀមច្បងគ្រប់ជំនាន់ ដែលបានបន្សល់ទុកនូវស្នាដៃល្អៗសម្រាប់សិស្សនិស្សិតជំនាន់ក្រោយ ក្នុងការយកមកធ្វើជាគំរូល្អៗសម្រាប់ការស្រាវជ្រាវ និងរៀបចំសារណា ឬរបាយការណ៍បញ្ចប់ការសិក្សារបស់ខ្លួនផងដែរ។

ជាចុងបញ្ចប់ យើងខ្ញុំសូមធ្វើការគោរពដឹងគុណ និងជូនពរដល់អ្នកមានគុណទាំងអស់ឲ្យជួបប្រទះតែសេចក្ដីសុខ សុភមង្គល និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លៀតឡើយ។

# អារម្ភកថា

ទីផ្សារមូលបត្រ ជាផ្នែកមួយនៃទីផ្សារហិរញ្ញវត្ថុ ដែលប្រតិបត្តិការរបស់វាគឺ ប្រមូលនូវប្រភពមូលធនសន្សំមួយចំណែកតូចនៅក្នុងសង្គម ឲ្យប្រែក្លាយទៅជាប្រភពមូលធនដ៏ធំសម្រាប់រយៈពេលវែងដល់បណ្តាសហគ្រាស ស្ថាប័នឯកជន និងស្ថាប័នរដ្ឋ ដើម្បីអភិវឌ្ឍផលិតកម្ម សេដ្ឋកិច្ច និងគម្រោងវិនិយោគផងដែរ។ នាពេលថ្មីៗនេះ យើងសង្កេតឃើញថា វិស័យមូលបត្រនៅកម្ពុជាកំពុងទទួលបានការពេញនិយមពីសំណាក់មហាជន ជាពិសេសវិនិយោគិនគ្រប់លំដាប់ថ្នាក់។ ទោះបីជាបែបនេះក្តី ក៏សាធារណជនមួយចំនួនហាក់ពុំទាន់យល់ដឹង និងទទួលបានព័ត៌មានទូលំទូលាយទាក់ទងនឹងវិស័យមូលបត្រនៅក្នុងប្រទេសកម្ពុជានៅឡើយទេ។

អាស្រ័យហេតុនេះ ក្នុងនាមយើងខ្ញុំជានិស្សិតបរិញ្ញាបត្រគ្រប់គ្រងធុរកិច្ចដែលត្រៀមនឹងបញ្ចប់ការសិក្សា បានមានឱកាសក្នុងការរៀបចំរបាយការណ៍បញ្ចប់ការសិក្សាមួយច្បាប់នេះឡើងមក ក្រោមប្រធានបទ "ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" ដើម្បីជាផ្នែកមួយក្នុងការចែករំលែកចំណេះដឹង ក៏ដូចជាព័ត៌មានខ្លះៗដែលអាចផ្តល់ជាសារៈប្រយោជន៍ដល់អ្នកអាន សិស្សនិស្សិត សាធារណជនគ្រប់រូបឲ្យបានយល់ដឹងបន្ថែមទាក់ទងនឹងវិស័យមូលបត្រនៅកម្ពុជា ជាពិសេសបណ្តាក្រុមហ៊ុន ឬសហគ្រាស ដែលមានបំណងចង់កៀរគរមូលធនរយៈពេលខ្លី មធ្យម ឬរយៈពេលវែងពីសាធារណជន ក្នុងការបង្កើតគម្រោងវិនិយោគបន្ថែមសម្រាប់ការអភិវឌ្ឍក្រុមហ៊ុនផងដែរ។ យើងខ្ញុំសង្ឃឹមផងដែរថា របាយការណ៍បញ្ចប់ការសិក្សាមួយច្បាប់នេះ អាចចូលរួមជាចំណែកក្នុងការលើកស្ទួយវិស័យមូលបត្រនៅកម្ពុជា និងផ្តល់ជាជំនួយក្នុងការស្វែងយល់បន្ថែមទាក់ទង ទៅនឹងព័ត៌មានផ្សេងៗនៃដំណើរការចុះបញ្ជីលក់មូលបត្រនៅកម្ពុជា។ យើងខ្ញុំ សូមចូលរួមក្នុងការលើកកម្ពស់ការអានដល់សិស្សនិស្សិតគ្រប់រូប ដែលស្រលាញ់ការអានសៀវភៅផងដែរ។

ជាចុងក្រោយនេះ យើងខ្ញុំទាំងពីរ សូមខន្តីអភ័យទោស និងការយោគយល់អធ្យាស្រ័យពីសំណាក់សាស្ត្រាចារ្យ គណៈកម្មាការការពារសារណា និងសិស្សនិស្សិតទាំងឡាយ ចំពោះការកើតមាននូវរាល់កំហុសឆ្គងដោយអចេតនាដោយប្រការណាមួយដូចជា កំហុសអក្ខរាវិរុទ្ធ ឬភាពខ្វះចន្លោះផ្សេងៗ ដោយក្តីអនុគ្រោះ។ យើងខ្ញុំ រីករាយទទួលរាល់មតិរិះគន់ក្នុងន័យស្ថាបនាទាំងឡាយពីសំណាក់មិត្តអ្នកអានគ្រប់រូប ដើម្បីកែប្រែ និងអភិវឌ្ឍខ្លួនឯងបន្ថែមទៀត។

# មាតិកា


បញ្ជីតារាង v

បញ្ជីរូបភាព vi

បញ្ជីក្រាហ្វិក vii

បញ្ជីឧបសម្ព័ន្ធ viii


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ២

៣. គោលបំណងនៃការស្រាវជ្រាវ ២

៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ៤


## ជំពូកទី១

## រំលឹកទ្រឹស្តី


១.១. មូលបត្រ ៦

១.១.១. និយមន័យមូលបត្រ ៦

១.១.២. ប្រភេទនៃមូលបត្រ ៦

១.១.២.១. មូលបត្រកម្មសិទ្ធិ ៦

១.១.២.២. មូលបត្របំណុល ៧

១.១.២.៣. ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ ៩

១.២. ទីផ្សារមូលបត្រ ៩

១.២.១. ប្រវត្តិទីផ្សារមូលបត្រ ៩

១.២.២. និយមន័យទីផ្សារមូលបត្រ ១១

១.២.៣. ប្រភេទទីផ្សារមូលបត្រ ១២

១.២.៣.១. ទីផ្សារដំបូង ១២

១.២.៣.២. ទីផ្សារបន្ទាប់ ១៣

១.២.៤. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ច ១៤
១.២.៥. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន ១៧
១.៣. ធាតុផ្សំសំខាន់ៗនៅក្នុងទីផ្សារមូលបត្រ ១៨
១.៣.១. ហេដ្ឋារចនាសម្ព័ន្ធ ១៩
១.៣.២. អន្តរការី ១៩
១.៣.៣. ក្រុមហ៊ុនបោះផ្សាយ ២០
១.៣.៤. វិនិយោគិន ២០

## ជំពូកទី ២

## ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

២.១. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ២២
២.១.១. ប្រវត្តិរបស់ ផ.ម.ក. ២២
២.១.២. រូបសញ្ញា និងនាមករណ៍របស់ ផ.ម.ក. ២៤
២.១.៣. រចនាសម្ព័ន្ធរបស់ ផ.ម.ក. ២៥
២.២. ចក្ខុវិស័យ និងបេសកម្មរបស់ ផ.ម.ក. ២៧
២.៣. ប្រតិបត្តិករទាំងបីរបស់ ផ.ម.ក. ២៧
២.៤. សមាជិករបស់ ផ.ម.ក. ២៩
២.៤.១. ក្រុមហ៊ុនធានាទិញមូលបត្រ ២៩
២.៤.២. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ២៩
២.៤.៣. ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ ៣០
២.៥. អ្នកចូលរួមរបស់ ផ.ម.ក. ៣០
២.៥.១. ភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ ៣០
២.៥.២. ភ្នាក់ងារបញ្ជិកាមូលបត្រ និងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ៣១
២.៦. ព័ត៌មានអំពី ផ.ម.ក. ៣១

# ជំពូកទី ៣
# ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា


៣.១. ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក. ៣២

៣.១.១. លក្ខខណ្ឌចម្បងនៃការចុះបញ្ជីនៃមូលបត្រកម្មសិទ្ធិ ៣២

៣.១.១.១. លក្ខខណ្ឌតម្រូវជាតួលេខ ៣២

៣.១.១.២. លក្ខខណ្ឌមិនមែនជាតួលេខ ៣៥

៣.១.១.៣. អភិបាលកិច្ចសាជីវកម្ម ៣៥

៣.១.២. ដំណើរការនៃការចុះបញ្ជី ៣៦

៣.១.២.១. ដំណាក់កាលរៀបចំរបស់ក្រុមហ៊ុន ៣៧

៣.១.២.២. ពិនិត្យលទ្ធភាពអាចចុះបញ្ជី ៣៩

៣.១.២.៣. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ៤០

៣.១.២.៤. ការចុះបញ្ជីជាផ្លូវការនៅ ផ.ម.ក. ៤១

៣.១.៣. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ៤២

៣.១.៣.១.ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជី ៤២

៣.១.៣.២. ថ្លៃសេវាសម្រាប់ការចុះបញ្ជី ៤២

៣.១.៣.៣. ថ្លៃសេវាចុះបញ្ជីប្រចាំឆ្នាំ ៤២

៣.១.៣.៤. ថ្លៃសេវាផ្សេងៗ ៤៣

៣.២. ការផ្តល់ព័ត៌មានបន្ទាប់ពីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក. ៤៣

៣.២.១. ព័ត៌មានទាន់ពេល ៤៣

៣.២.២. របាយការណ៍សមាជិក ៤៣

៣.២.៣. ព័ត៌មានពិសេស ៤៤

៣.២.៤. ព័ត៌មានតាមការស្នើសុំ ៤៥

៣.៣. ព័ត៌មានក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក. ៤៦

៣.៣.១. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រទសភ) ៤៦

៣.៣.២. ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (ហាធអ) ៤៦

៣.៣.៣. កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) ៤៧

៣.៣.៤. ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី) ៤៨

៣.៣.៥. កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) ........ ៤៩
៣.៤. ទិន្នន័យក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក. ........ ៥០
៣.៤.១. ការវិភាគទិន្នន័យនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (រៀល) ........ ៥០
៣.៤.២. ការវិភាគទិន្នន័យនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (%) ........ ៥៣
៣.៥. អត្ថប្រយោជន៍នៃការចុះបញ្ជីនៅ ផ.ម.ក. ........ ៥៥
៣.៦. ការវិភាគពីចំនុចខ្លាំង និងចំនុចខ្សោយ ........ ៥៨

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........ ៦០
២. អនុសាសន៍ ........ ៦១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីតារាង


តារាងទី១ ៖ បញ្ជីក្រុមហ៊ុនធានាទិញមូលបត្រ

តារាងទី២ ៖ បញ្ជីក្រុមហ៊ុនពាណិជ្ជករមូលបត្រ

តារាងទី៣ ៖ បញ្ជីក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ

តារាងទី៤ ៖ បញ្ជីភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ

តារាងទី៥ ៖ បញ្ជីភ្នាក់ងារបញ្ជិកាមូលបត្រ និងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ

តារាងទី៦ ៖ លក្ខខណ្ឌតម្រូវជាតួលេខសម្រាប់ទីផ្សារគោល

តារាងទី៧ ៖ លក្ខខណ្ឌតម្រូវជាតួលេខសម្រាប់ទីផ្សារកំណើន

តារាងទី៨ ៖ លក្ខខណ្ឌមិនមែនជាតួលេខសម្រាប់ក្រុមហ៊ុនចុះបញ្ជី

តារាងទី៩ ៖ ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

តារាងទី១០ ៖ ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ

តារាងទី១១ ៖ ការវិភាគទិន្នន័យនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (គិតជារៀល)

តារាងទី១២ ៖ ការវិភាគទិន្នន័យនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (គិតជា %)

# បញ្ជីរូបភាព

រូបភាពទី១ ៖ គំរូមូលបត្រកម្មសិទ្ធិ

រូបភាពទី២ ៖ គំរូមូលបត្របំណុល

រូបភាពទី៣ ៖ យន្តការទីផ្សារដំបូង

រូបភាពទី៤ ៖ រូបសញ្ញាក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

រូបភាពទី៥ ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ ផ.ម.ក.

រូបភាពទី៦ ៖ ក្រុមប្រឹក្សាភិបាលនៃ ផ.ម.ក.

រូបភាពទី៧ ៖ ដំណើរការនៃការចុះបញ្ជី

រូបភាពទី៨ ៖ ដ្យាក្រាមនៃការបង្ហាញព័ត៌មាន

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១ ៖ ចំនួនភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូង
ក្រាហ្វិកទី២ ៖ ចំនួនទឹកប្រាក់ដែលទទួលបានពីការបោះផ្សាយ (រៀល)
ក្រាហ្វិកទី៣ ៖ ប្រៀបធៀបចំនួនភាគហ៊ុននៅក្នុងក្រុមហ៊ុននីមួយៗ
ក្រាហ្វិកទី៤ ៖ ភាគរយនៃចំនួនភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូង

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ គោលការណ៍ណែនាំស្តីពី យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង
ឧបសម្ព័ន្ធទី២ ៖ ប្រកាសស្តីពី ការដាក់ឲ្យអនុវត្តនូវការកែប្រែវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
ឧបសម្ព័ន្ធទី៣ ៖ ប្រកាសស្តីពី ការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
ឧបសម្ព័ន្ធទី៤ ៖ ប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
ឧបសម្ព័ន្ធទី៥ ៖ ប្រកាសស្តីពី ការបង្ហាញព័ត៌មានសាជីវកម្ម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

វិស័យហិរញ្ញវត្ថុ ដើរតួយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍឲ្យប្រទេសជាតិមានការរីកចម្រើនលូតលាស់ មានស្ថេរភាពល្អ និងប្រកបដោយចីរភាព។ រដ្ឋាភិបាលនៃប្រទេសនីមួយៗបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការអភិវឌ្ឍលើវិស័យនេះ ដោយសារតែវាជះឥទ្ធិពលទៅដល់សេដ្ឋកិច្ចជាតិទាំងមូល។ ក្នុងនោះដែរ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវ "ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០" នឹងត្រូវធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ទៅជា "យុទ្ធ-សាស្ត្រអភិវឌ្ឍន៍ហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០" ។ បច្ចុប្បន្ននេះ វិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជាមានការរីកចម្រើនទៅមុខជាបន្តបន្ទាប់ដោយមានវិស័យមូលបត្រចូលរួមក្នុងនោះផងដែរ។

ដើម្បីឈានមួយជំហានទៀតទៅក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ឲ្យដំណើរការនូវក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រឲ្យកាន់តែមានភាពងាយស្រួលក្នុងការធ្វើសំណើលក់ ផ្ទេរ ឬធ្វើការទិញ-លក់មូលបត្រ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជានេះផងដែរ ត្រូវបានប្រកាសបើកការជួញដូរមូលបត្រនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២។ មកទល់ពេលនេះមានរយៈពេល ៧ឆ្នាំហើយ ដែលក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាអនុវត្តនូវប្រតិបត្តិការដូចជា ការចុះបញ្ជី និងផ្តល់ព័ត៌មាន ការជួញដូរ ការទូទាត់ និងផាត់ទាត់ និងការរក្សាទុកមូលបត្រជាដើម។ មួយវិញទៀត ការដាក់ឲ្យដំណើរការនូវទីផ្សារមូលបត្រ វាជាជម្រើសថ្មីមួយទៀតសម្រាប់វិនិយោគិនក្នុងការវិនិយោគបន្ថែមទៅលើវិស័យធនាគារ និងអចលនទ្រព្យ។ បន្ថែមពីនេះទៀត វាជាមធ្យោបាយមួយក្នុងការកៀរគរយកមូលធនដែលទំនេរ យកមកធ្វើការវិនិយោគបន្ថែម និងបែងចែកមូលធនដល់អ្នកដែលមានតម្រូវការយ៉ាងមានប្រសិទ្ធិភាព ដើម្បីទទួលបាននូវប្រាក់ចំណេញ និងធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនបន្តទៀតផងដែរ។ ជាមួយគ្នានេះដែរ យើងក៏សង្កេតឃើញថា មានវិនិយោគិនជាច្រើនបានចាប់អារម្មណ៍ និងចូលរួមក្នុងដំណើរការទីផ្សារមូលបត្រនេះ។ លើសពីនេះទៅទៀត ក៏មានក្រុមហ៊ុនធំៗជាច្រើនបានយល់ដឹងនូវអត្ថប្រយោជន៍ និងធ្វើការចុះបញ្ជីលក់មូលបត្រជាបន្តបន្ទាប់។

ហេតុដូច្នេះហើយ ទើបយើងខ្ញុំជ្រើសរើសយកប្រធានបទ "ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" មកធ្វើជារបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្នុងគោលបំណងផ្តល់ជាចំណេះដឹងបន្ថែមទៅដល់វិនិយោគិន សិស្សនិស្សិត ក៏ដូចជាសាធារណ-

ជនដែលមានបំណងចង់ស្វែងយល់ឲ្យកាន់តែច្បាស់ អំពីប្រធានបទទាក់ទងនឹងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ថ្វីត្បិតតែវិស័យមូលបត្របានដំណើរការអស់រយៈពេល ៧ឆ្នាំមកហើយ ប៉ុន្តែដោយសារវិស័យនេះជាវិស័យថ្មីមួយដែលទើបតែទទួលបានការចាប់អារម្មណ៍ពីមហាជន នោះជាហេតុធ្វើឲ្យសាធារណជន ក្រុមហ៊ុន ឬសហគ្រាស និងវិនិយោគិនថ្មីៗមិនទាន់យល់ច្បាស់ និងទទួលបានព័ត៌មានយ៉ាងទូលំទូលាយ និងលម្អិតពីវានៅឡើយ ព្រមទាំងមិនទាន់យល់ដឹងពីគុណសម្បត្តិនៃមូលបត្រចំពោះសេដ្ឋកិច្ចជាតិ និងវិនិយោគិន។ មិនតែប៉ុណ្ណោះក៏នៅមានក្រុមហ៊ុន និងសហគ្រាសមួយចំនួនដែលមិនទាន់ដឹង និងយល់ពីការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ក៏ដូចជាអត្ថប្រយោជន៍នៃការចុះបញ្ជីនេះ។ ដោយផ្អែកលើចំណោទបញ្ហានេះ តើការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានលក្ខណៈយ៉ាងណា និងតម្រូវឲ្យមានលក្ខខណ្ឌអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទ "ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្រុមហ៊ុនផ្សារមូលត្រកម្ពុជា" នេះ យើងខ្ញុំមានបំណងចង់សិក្សាស្វែងយល់ទៅលើចំណុចមួយចំនួនដូចខាងក្រោម៖

- ស្វែងយល់ពីប្រភេទ និងលក្ខណៈពិសេសនៃមូលបត្រ
- ស្វែងយល់ពីតួនាទី និងអត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន និងសេដ្ឋកិច្ចជាតិ
- ស្វែងយល់ពីតួអង្គ និងធាតុផ្សំសំខាន់ៗក្នុងដំណើរការនៃការចុះបញ្ជី
- ស្វែងយល់ពីវិធីសាស្ត្រ និងវិធានផ្សេងៗនៃការចុះបញ្ជី
- ស្វែងយល់ពីអត្ថប្រយោជន៍នៃការចុះបញ្ជីលក់មូលបត្រ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដោយសម្លឹងឃើញសន្ទុះនៃការវិនិយោគលើវិស័យមូលបត្រ មានការរីកលូតលាស់គួរឲ្យកត់សម្គាល់ក្នុងអំឡុងឆ្នាំ២០១៨-២០១៩នេះ ដូច្នេះហើយ ទើបយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទ ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ដែលជាផ្នែកមួយនៃដំណើរការបោះផ្សាយលក់មូលបត្រដែលមានសារៈសំខាន់ចំពោះក្រុមហ៊ុន និងបណ្តាសហគ្រាស ដែលមាន

បំណងចង់ធ្វើការវិនិយោគនៅលើវិស័យមូលបត្រ។ ប្រធានបទនេះ ផ្តោតសំខាន់ទៅលើវិធីសាស្ត្រ បទប្បញ្ញត្តិ និងលក្ខខណ្ឌតម្រូវផ្សេងៗនៃការចុះបញ្ជីនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះ ផ្តល់ជាអត្ថប្រយោជន៍ជាច្រើនដូចខាងក្រោមៈ

- ទទួលបាននូវចំណេះដឹងបន្ថែមមួយកម្រិតទៀតទាក់ទងនឹងវិស័យមូលបត្រ
- ផ្តល់ឱកាសឲ្យយើងខ្ញុំបានអនុវត្តការងារជាក់ស្តែងផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តីដែលបានសិក្សារួច
- ផ្តល់ជាទស្សនៈទានស្តីអំពីការចុះបញ្ជីលក់មូលបត្រដែលមានភាពទូលំទូលាយ និងលម្អិតដល់វិនិយោគិន និងសាធារណជន ដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងបន្ថែមទាក់ទងនឹងវិស័យនេះ
- ផ្តល់ជាព័ត៌មានដែលមានសារៈសំខាន់ដល់ក្រុមហ៊ុន ឬសហគ្រាស ដែលត្រៀមខ្លួនក្នុងការបោះផ្សាយលក់មូលបត្រ
- ចូលរួមចំណែកជាចំណេះដឹង និងព័ត៌មានផ្សេងៗក្នុងការយល់ដឹងបន្ថែមទាក់ទងទៅនឹងវិស័យមូលបត្រ
- ផ្តល់ជាឯកសារជំនួយដល់សិស្សនិស្សិតជំនាន់ក្រោយក្នុងការយល់ដឹង និងសិក្សស្រាវជ្រាវបន្ថែមទាក់ទងនឹងវិស័យនេះ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីទទួលចំណេះដឹង និងប្រមូលយកនូវទិន្នន័យព័ត៌មានទាក់ទងនឹងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិឲ្យមានភាពច្បាស់លាស់ និងត្រឹមត្រូវ គឺយើងខ្ញុំបានប្រើវិធីពីរយ៉ាងៈ

- ទិន្នន័យចម្បង
  - ការបកស្រាយ និងពន្យល់ណែនាំយ៉ាងលម្អិតពីសំណាក់មន្ត្រី និងអ្នកជំនាញពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្រនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
  - ការសាកសួរដោយផ្ទាល់ទៅកាន់មន្ត្រីនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
  - ការណែនាំយ៉ាងយកចិត្តទុកដាក់ពីសាស្ត្រាចារ្យណែនាំ។
- ទិន្នន័យបន្ទាប់
  - ការស្រាវជ្រាវរកទិន្នន័យតាមប្រព័ន្ធអ៊ីនធើណេត
  - ការស្វែងរកព័ត៌មានតាមរយៈគេហទំព័ររបស់ ជ.ម.ក. និង គ.ម.ក.

- ការអាន និងដកស្រង់នូវអត្ថន័យក្នុងឯកសារ និងខិតប័ណ្ណដែលពាក់ព័ន្ធនឹងមូលបត្រ
- ការអាននូវរបាយការណ៍ ឬសារណារបស់សិស្សច្បង
- ការអាននូវប្រកាស បទប្បញ្ញត្តិ ច្បាប់ និងអនុក្រឹត្យដែលពាក់ព័ន្ធនឹងមូលបត្រ
- ការចូលរួមសិក្ខាសិលានានាដែលទាក់ទងនឹងមូលបត្រ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីផ្តល់ភាពងាយស្រួលដល់ការសិក្សាស្រាវជ្រាវរបាយការណ៍បញ្ចប់ការសិក្សានេះ យើងខ្ញុំបានរៀបចំរចនាសម្ព័ន្ធនៃការស្រាវជ្រាវដូចខាងក្រោមៈ

### សេចក្តីផ្តើម

ជាការចាប់ផ្តើមនៃការស្រាវជ្រាវនេះ យើងខ្ញុំបានសិក្សាស្វែងយល់ពីស្ថានភាពទូទៅនៃការស្រាវជ្រាវដែលរួមមាន លំនាំបញ្ហា ចំណោទបញ្ហា ទំហំ និងដែនកំណត់ គោលបំណង សារៈសំខាន់ វិធីសាស្ត្រ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

### ជំពូកទី១ៈ រំលឹកទ្រឹស្តី

នៅក្នុងជំពូកនេះ យើងខ្ញុំបានរំលឹកនូវទ្រឹស្តីខ្លះៗដែលទាក់ទងទៅនឹងប្រធានបទ ដូចជា និយមន័យនៃមូលបត្រ ប្រភេទ តួនាទី និងអត្ថប្រយោជន៍នៃមូលបត្រ ដើម្បីផ្តល់ជាគ្រឹះរួមចំណែកក្នុងការសរសេររបាយការណ៍នេះ។

### ជំពូកទី២ៈ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ដោយសារការសិក្សាស្រាវជ្រាវនេះផ្តោតទៅលើការចុះបញ្ជីនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូច្នេះស្ថានភាពទូទៅរបស់ក្រុមហ៊ុនមានដូចជា ប្រវត្តិរបស់ ផ.ម.ក. រចនាសម្ព័ន្ធ ចក្ខុវិស័យ និងបេសកម្ម ប្រតិបត្តិការ និងសមាជិករបស់ ផ.ម.ក. ពិតជាមានសារៈសំខាន់ណាស់ចំពោះការសិក្សាស្រាវជ្រាវនេះ។

### ជំពូកទី៣ៈ ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ជំពូកនេះ យើងខ្ញុំបានសិក្សាយ៉ាងលម្អិតទាក់ទងនឹងដំណើរការទាំងមូលនៃការចុះបញ្ជីនៅ ផ.ម.ក. រួមមាន លក្ខខណ្ឌចម្បង ដំណើរការ និងរយៈពេលនៃការចុះបញ្ជី។ ក្នុងនោះដែរ យើងខ្ញុំបានដកស្រង់នូវទិន្នន័យនៃក្រុមហ៊ុនចុះបញ្ជីផងដែរ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ដើម្បីសរុបន័យនៃរបាយការណ៍បញ្ចប់ការសិក្សាទាំងមូល យើងខ្ញុំបានធ្វើសេចក្តីសន្និដ្ឋាន និងអនុសាសន៍នៃការស្រាវជ្រាវក្នុងគោលបំណងកែលម្អចំនុចខ្វះខាតមួយចំនួនក្នុងន័យស្ថាបនា។

# ជំពូកទី ១

# រំលឹកទ្រឹស្ដី

## ១.១. មូលបត្រ

### ១.១.១. និយមន័យមូលបត្រ

[1]មូលបត្រ ជាប្រភេទទំនិញពិសេសម្យ៉ាង-ទំនិញហិរញ្ញវត្ថុ គឺជាឧបករណ៍ប្រមូលនូវមូលធនពីកន្លែងលើសមកកន្លែងខ្វះ ពីអ្នកផ្គត់ផ្គង់មូលធនដល់អ្នកត្រូវការមូលធន។ មូលបត្រ គឺជាប្រភេទទំនិញចរាចរនៅលើទីផ្សារមូលបត្រ ដែលតម្លៃរបស់វាជានិច្ចជាកាលកើនឡើង និងថយចុះជានិច្ចនៅលើទីផ្សារ ចាំបាច់ត្រូវចេះរបៀបស្វែងយល់វា។ និយាយឲ្យខ្លី មូលបត្រ ជាក្រដាសបញ្ជាក់ពីសិទ្ធិរបស់ម្ចាស់កម្មសិទ្ធិមួយចំណែកនៅក្នុងសហគ្រាសណាមួយ នោះត្រូវបានគេហៅថា Stock ចំណែកឯបញ្ជាក់ពីម្ចាស់បំណុលហៅថា Bonds។

### ១.១.២. ប្រភេទនៃមូលបត្រ

#### ១.១.២.១. មូលបត្រកម្មសិទ្ធិ

[2]មូលបត្រកម្មសិទ្ធិ ឬភាគហ៊ុន (Stock) គឺជាមូលបត្រដែលបានបោះផ្សាយដោយក្រុមហ៊ុនសាធារណៈ ដើម្បីកៀរគរមូលនិធិពីសាធារណជន។ វារួមបញ្ចូលទាំងភាគហ៊ុនរបស់ក្រុមហ៊ុនដែលតំណាងឲ្យភាពជាម្ចាស់របស់វិនិយោគិននៅក្នុងក្រុមហ៊ុននោះ។ ភាពជាម្ចាស់នៃទ្រព្យកម្មសិទ្ធិ នឹងផ្ដល់សិទ្ធិដល់ភាគហ៊ុនិកនូវចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈភាគលាភ។ ភាគហ៊ុនិក គឺជាម្ចាស់នៃអាជីវកម្ម ព្រមទាំងចូលរួមទទួលនូវការចែករំលែកភាពជោគជ័យ ឬបរាជ័យនៃអាជីវកម្មរបស់ក្រុមហ៊ុន។ លទ្ធផលដំណើរការនៃអាជីវកម្មរបស់ក្រុមហ៊ុនចុះបញ្ជី ជាធម្មតាអាចវាយតម្លៃបានតាមរយៈភាគលាភដែលភាគហ៊ុនិកបានទទួល និងតាមរយៈថ្លៃភាគហ៊ុនដែលបានដាក់ថ្លៃនៅលើទីផ្សារ។ មូលបត្រនេះរួមមាន ២ ប្រភេទសំខាន់គឺ៖

- **ភាគហ៊ុនធម្មតា (Common Stock)**

  ភាគហ៊ុនធម្មតា គឺជាភាគហ៊ុនដែលមានការលើកទឹកចិត្តដោយផ្ទាល់ ដល់អ្នកកាន់កាប់ភាគហ៊ុនតាមរយៈភាគលាភដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុន ការចំណេញ

[1] សួន ចំរើន ២០១៨-២០១៩, "ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១", ទំព័រទី៣៦

[2] http://www.csx.com.kh/kh/product/equities.jsp?MNCD=4020មូលបត្រកម្មសិទ្ធិ

លើមូលធន និងសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុននៅពេលដែលក្រុមហ៊ុនសម្រេចក្នុងការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។

- **ភាគហ៊ុនបុរិមា (Preferred Stock)**

ភាគហ៊ុនបុរិមាក៏ជាផ្នែកមួយនៃទ្រព្យកម្មសិទ្ធិផងដែរ។ ភាពខុសគ្នារវាងភាគហ៊ុនបុរិមា និងភាគហ៊ុនធម្មតាគឺ អ្នកកាន់កាប់ភាគហ៊ុនបុរិមានឹងមានសិទ្ធិទទួលបានមូលនិធិ ឬប្រាក់ចំណេញរបស់ក្រុមហ៊ុនមុនភាគហ៊ុនធម្មតា។

រូបភាពទី១៖ គំរូមូលបត្រកម្មសិទ្ធិ




ប្រភព៖ https://corporatepublishingcompany.com/product/kg2-stock-certificte-online-design-advance

### ១.១.២.២. មូលបត្របំណុល

[3]មូលបត្របំណុល ឬសញ្ញាបណ្ណ (Bonds) គឺជាប្រភេទមូលបត្រ ដែលតំណាងឲ្យកិច្ចសន្យាខ្ចីប្រាក់រវាងបុគ្គលបោះផ្សាយមូលបត្របំណុល (រួមមានសាជីវកម្ម សហគ្រាសរដ្ឋ ឬ រាជ-រដ្ឋាភិបាល) និងវិនិយោគិន (ម្ចាស់មូលបត្របំណុល) ។ តាមរយៈកិច្ចសន្យានេះ បុគ្គលបោះផ្សាយលក់មូលបត្របំណុល ត្រូវមានកាតព្វកិច្ចបង់ឲ្យវិនិយោគិននូវទឹកប្រាក់ជាក់លាក់មួយជាទៀងទាត់ដែលហៅថា "គូប៉ុង" ឬ "ការប្រាក់" (លើកលែងសម្រាប់សញ្ញាបណ្ណគ្មានការប្រាក់) ព្រមទាំងបង់ប្រាក់ដើមនៅពេលដែលសញ្ញាបណ្ណនោះដល់កាលកំណត់សង ដែលហៅថា "ឥណប្រតិទាន"។ ជំនួសឲ្យការខ្ចីប្រាក់ពីធនាគារ ក្រុមហ៊ុន ឬ អង្គភាពមួយ អាចធ្វើការបោះផ្សាយសញ្ញាបណ្ណទៅឲ្យ

[3] http://www.csx.com.kh/kh/product/bond.jsp?MNCD=4040មូលបត្របំណុល

វិនិយោគិនដោយផ្ទាល់ នៅពេលដែលក្រុមហ៊ុននោះត្រូវការសាច់ប្រាក់ ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងថ្មីៗ បន្តប្រតិបត្តិការក្រុមហ៊ុន ឬ ដើម្បីទូទាត់បំណុល។

[4]មូលបត្រនេះរួមមាន ២ ប្រភេទសំខាន់គឺ៖

- **សញ្ញាបណ្ណសាជីវកម្ម (Corporate Bonds)**

  សញ្ញាបណ្ណសាជីវកម្ម គឺជាប្រភេទមូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្មជាមួយនឹងគោលដៅប្រមូលមូលធន ដើម្បីបន្ថែមមូលធនបណ្តោះអាសន្នដែលខ្វះខាតបម្រើឲ្យអ្នកវិនិយោគទុន។

- **សញ្ញាបណ្ណរដ្ឋ (Government Bonds)**

  សញ្ញាបណ្ណរដ្ឋ គឺជាប្រភេទមូលបត្រដែលរដ្ឋាភិបាលបោះផ្សាយ ដើម្បីប្រមូលថវិការដ្ឋក្នុងគោលដៅកសាងហេដ្ឋារចនាសម្ព័ន្ធ ស្ថាប័នសាធារណៈដូចជា មន្ទីរពេទ្យ វិស័យអប់រំជាដើម។ វាជាប្រភេទមូលបត្រដែលមានសុវត្ថិភាពបំផុត ពីព្រោះមូលបត្រនេះត្រូវបានធានាដោយរដ្ឋាភិបាល។

[5]លក្ខណៈខុសគ្នាចម្បងមួយរវាងភាគហ៊ុន និងសញ្ញាបណ្ណ គឺថាសញ្ញាបណ្ណតំណាងឲ្យភាពជាម្ចាស់បំណុល រីឯភាគហ៊ុនតំណាងឲ្យភាពជាម្ចាស់កម្មសិទ្ធិនៃក្រុមហ៊ុនមួយ។ ថ្លៃភាគហ៊ុនអាចកើនឡើងយ៉ាងឆាប់រហ័ស ប្រសិនបើក្រុមហ៊ុននោះមានការរីកចម្រើន និងមានប្រាក់ចំណេញច្រើន។ ផ្ទុយទៅវិញ សញ្ញាបណ្ណធ្វើការទូទាត់តែការប្រាក់ដែលបានកំណត់ជាមុន ហើយថ្លៃរបស់វាប្រែប្រួលនៅក្នុងដែនដែលកំណត់ដោយអត្រាការប្រាក់ ពោលគឺ មិនមែនកំណត់ដោយប្រាក់ចំណេញរបស់ក្រុមហ៊ុននោះឡើយ។

រូបភាពទី២៖ គំរូមូលបត្របំណុល




ប្រភព៖ https://www.thebalance.com/series-ee-savings-bonds-photo-gallery-4061799

[4] សួន ចំរើន ២០១៧-២០១៨, "រូបិយវត្ថុ និងធនាគារ", ទំព័រទី៥២

[5] http://www.csx.com.kh/kh/product/bond.jsp?MNCD=4040

#### ១.១.២.៣. ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ

[6]ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ សំដៅដល់កិច្ចសន្យាដែលផ្តល់សិទ្ធិ ឬកាតព្វកិច្ចនៃមូលបត្រដើមទៅឲ្យបុគ្គលណាមួយដែលរួមបញ្ចូលទាំងសិទ្ធិ កាតព្វកិច្ចទិញ-លក់ ឬដាក់ពាក្យសុំទិញមូលបត្រក្នុងពេលអនាគតដោយមិនគិតថាបុគ្គលនេះមានបំណងប្រើសិទ្ធិ ឬមិនប្រើប្រាស់សិទ្ធិនេះក៏ដោយ។

## ១.២. ទីផ្សារមូលបត្រ

### ១.២.១. ប្រវត្តិទីផ្សារមូលបត្រ

[7]ទីផ្សារភាគហ៊ុន (Stock Market) មានប្រវត្តិតាំងពីយូរយារណាស់មកហើយ។ បច្ចុប្បន្នទីផ្សារនេះ ត្រូវបានគេធ្វើបច្ចុប្បន្នកម្មទៅជាទីផ្សារមូលបត្រ (Securities Market)។ ទីផ្សារភាគហ៊ុនប្រើប្រាស់រយៈពេលអស់រាប់សតវត្ស ក្នុងការវិវត្តន៍រហូតក្លាយទៅជាទីផ្សារមូលបត្រដូចបច្ចុប្បន្ន។ ប៉ុន្តែប្រទេសជាច្រើននៅតែពេញនិយមក្នុងការប្រើប្រាស់ពាក្យ "ទីផ្សារភាគហ៊ុន" ជាជាង "ទីផ្សារមូលបត្រ" ដដែល។ ទីផ្សារភាគហ៊ុន កើតឡើងដំបូងប្រហែលជានៅពេលដែលភាគហ៊ុនរបស់ The Dutch East India Company ត្រូវបានគេជួញដូរនៅលើទីផ្សារអាំស្ទែដាំ (Amsterdam Market)។ ក្រុមហ៊ុន The Dutch East India Company បង្កើតនៅឆ្នាំ ១៦០២ ហើយវាជាក្រុមហ៊ុនដំបូងគេដែលបោះផ្សាយលក់ភាគហ៊ុន ដើម្បីប្រមូលទុនសម្រាប់ការវិនិយោគរបស់ខ្លួន។ ភាគរយនៃផលចំណេញរបស់ក្រុមហ៊ុន ត្រូវបានផ្តល់ជូនដល់អ្នកទិញដោយអាស្រ័យទៅនឹងភាគហ៊ុនដែលមាន។ ភាគហ៊ុននេះត្រូវបានគេជួញដូរជាបន្តបន្ទាប់ រហូតលេចចេញការជួញដូរនៅលើក្រុមហ៊ុនផ្សារអាំស្ទែដាំ (Amsterdam Exchange)។ ហើយក្រោយមក ឧបករណ៍ហិរញ្ញវត្ថុសំបូរបែបផ្សេងៗត្រូវបានធ្វើការទិញ-លក់នៅលើទីផ្សារអាំស្ទែដាំ (Amsterdam Market) នេះ។

ក្រុមហ៊ុនផ្សារភាគហ៊ុន (Stock Exchange) នៅក្នុងទីក្រុងញូយ៉ កត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៧៩២ នៅពេលដែលឈ្មួញជើងសារ (Brokers) ចំនួន ២៤ នាក់ បានសម្រេចចិត្តយកកំរៃជើងសានៅពេលដែលពួកគេដើរតួជាភ្នាក់ងារសម្រាប់មនុស្សផ្សេងៗទៀតក្នុងការធ្វើជំនួញ។ ពួកគេបានធ្វើការជួញដូរជាច្រើននៅក្រោមដើមឈើមួយនៅ វ៉លស្ទ្រីត (Wall Street) ជាប្រចាំទើបបង្កើតឲ្យមានទីផ្សារមួយឈ្មោះថា វ៉លស្ទ្រីត មកដល់បច្ចុប្បន្ននេះនៅសហរដ្ឋអាមេរិក។

[6] គឹម ច័ន្ទសុវណ្ណលក្ខិណា, ឆ្នាំ ២០១៧ "ការជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជា"

[7] http://siborann.blogspot.com/2011/09/blog-post_09.htmlប្រវត្តិទីផ្សារមូលបត្រ

ឧបករណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាល បានបង្កើតនូវមូលដ្ឋានគ្រឹះនៃការធ្វើការជួញដូរជាលើកដំបូង ហើយភាគហ៊ុនរបស់ធនាគារ និងក្រុមហ៊ុនធានារ៉ាប់រង បានបន្ថែមលើបរិមាណនៃប្រតិបត្តិការនៃការជួញដូរបន្ថែមទៀត។ ក្នុងឆ្នាំ ១៨១៧ ឈ្មួញជើងសារ នៅក្នុងទីក្រុងញូយ៉ក បានសម្រេចចិត្តចាត់ចែងជាផ្លូវការនូវក្រុមប្រឹក្សាសំរាប់ទីផ្សារភាគហ៊ុន បន្ទាប់មកទីផ្សារភាគហ៊ុនបានរីកចម្រើនជាមួយនឹងឧស្សាហូបនីយកម្មរបស់អាមេរិកដែរ។ នៅឆ្នាំ ១៨៦៣ ក្រុមហ៊ុនផ្សារភាគហ៊ុននៅទីក្រុងញូយ៉ក បានអនុម័តនូវឈ្មោះបច្ចុប្បន្នរបស់ខ្លួន គឺក្រុមហ៊ុនផ្សារភាគហ៊ុនញូយ៉ក (New York Stock Exchange)។ ក្នុងពេលនៃសង្គ្រាមស៊ីវិល ក្រុមហ៊ុនផ្សារភាគហ៊ុនមួយចំនួនបន្ថែមទៀតត្រូវបានគេបង្កើតឡើង ហើយក្រុមហ៊ុនផ្សារភាគហ៊ុនមួយក្នុងចំណោមផ្សារភាគហ៊ុនទាំងនោះ ដែលចាត់ទុកជាអ្នកនាំមុខគេគឺ ក្រុមហ៊ុនផ្សារភាគហ៊ុនអាមេរិក (American Stock Exchange) គឺជាក្រុមហ៊ុនផ្សារភាគហ៊ុនធំទី ២ នៅសហរដ្ឋអាមេរិកនាពេលបច្ចុប្បន្ននេះ។

ទីផ្សារភាគហ៊ុនមានការរីវត្តន៍ជាខ្លាំងក្រោយសង្គ្រាមលោកលើកទី២។ សង្គ្រាមលោកលើកទី២ បានជះឥទ្ធិពលជាវិជ្ជមានជាច្រើនដល់ការវិវត្តន៍របស់ទីផ្សារនេះ ព្រោះក្រោយពីប្រទេសទាំងអស់ងើបពីសង្គ្រាម ហិរញ្ញប្បទានជាបញ្ហាប្រឈមមួយដ៏ធ្ងន់ធ្ងរ។ រដ្ឋាភិបាលនៃប្រទេសមួយចំនួនមានការចាប់អារម្មណ៍ក្នុងការប្រើប្រាស់ទីផ្សារភាគហ៊ុន ព្រោះការវិវត្តន៍ខាងផ្នែកនយោបាយក្រោយសង្គ្រាមបានធ្វើឲ្យរដ្ឋាភិបាលខំស្វែងរកនូវប្រភពទុនថ្មីៗ សម្រាប់ទ្រទ្រង់ការចំណាយចរន្ត និងចំណាយមូលធនរបស់ខ្លួន ហើយទីផ្សារភាគហ៊ុនជាជម្រើសប្រភពហិរញ្ញប្បទានដ៏ល្អមួយ។ ម្យ៉ាងទៀត ដើម្បីធ្វើឲ្យសាច់ប្រាក់មានចលនាវិលឡើងចុះកាន់តែខ្លាំងនៅក្នុងចរន្តសេដ្ឋកិច្ច ក៏ដូចជាធ្វើឲ្យសកម្មភាពនៃជំនួញកាន់តែមានភាពរស់រវើកថែមទៀតផង ក្នុងទិសដៅលើកកំពស់កំណើនសេដ្ឋកិច្ចដែលទើបងើបផុតពីសង្គ្រាម ទីផ្សារភាគហ៊ុនក៏ជាគោលនយោបាយដ៏ល្អមួយសម្រាប់រដ្ឋាភិបាលផងដែរ។ ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និងសហគ្រាសរួមទុនមួយចំនួនទៀតជាពិសេស ក្រុមហ៊ុនពាណិជ្ជកម្មធំៗ ក៏ខ្វះប្រភពទុនថ្មីៗដែរសម្រាប់យកមកទ្រទ្រង់ការចំណាយ និងពង្រីកនូវមុខជំនួញរបស់គេ ជាហេតុធ្វើឱ្យទីផ្សារភាគហ៊ុន ជាជម្រើសប្រភពហិរញ្ញប្បទានដ៏ល្អមួយដល់ពួកគេបន្ថែមលើប្រភពហិរញ្ញប្បទានផ្ទាល់ខ្លួន និងប្រភពហិរញ្ញប្បទានដោយប្រយោលតាមរយៈធនាគារ។ ភាពរួមគ្នានៃតម្រូវការទាំងនេះ ទីផ្សារភាគហ៊ុនកាន់តែច្រើនត្រូវបានគេបង្កើតដើម្បីធ្វើសញ្ជ័យលើធនធាន និងកៀរគរនូវធនធានហិរញ្ញវត្ថុពីប្រភពផ្សេងៗ។ ការធ្វើសញ្ជ័យលើធនធាន និងកៀរគរនូវធនធានហិរញ្ញវត្ថុពីប្រភពផ្សេងៗទាំងនេះ ធ្វើឡើងតាមរយៈការបោះផ្សាយលក់ឧបករណ៍ហិរញ្ញវត្ថុ ដោយផ្តល់ផលប្រយោជន៍ហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុដល់អ្នកលក់

អ្នកទិញ និងអ្នកទិញហើយលក់វិញផងដែរ។ ឧបករណ៍ហិរញ្ញវត្ថុទាំងនោះ ត្រូវបានគេជួញដូរនៅលើទីផ្សារភាគហ៊ុនជាបន្តបន្ទាប់។ តាំងពីពេលនោះមក មានប្រទេសជាច្រើនផ្សេងៗទៀតបានមើលឃើញពីអត្ថប្រយោជន៍នៃទីផ្សារភាគហ៊ុននៅបណ្តាប្រទេសទាំងនោះ ហើយចាប់ផ្តើមខិតខំបង្កើតជាទីផ្សារនេះឡើងផងដែរ។

ទីផ្សារភាគហ៊ុនបានអភិវឌ្ឍយ៉ាងលឿន ដែលមានឧបករណ៍ហិរញ្ញវត្ថុជាច្រើនដូចជា សញ្ញាបណ្ណ ឧបករណ៍ដេរីវេទីវ ឬឧបករណ៍និស្សន្ទ ត្រូវបានគេទិញ-លក់នៅលើទីផ្សារនេះផងដែរ ពុំមែនមានតែភាគហ៊ុនប៉ុណ្ណោះទេ។ ហេតុដូចនេះ អ្នកវិនិយោគសាធារណៈងាយនឹងយល់ច្រឡំអំពីទីផ្សារនេះណាស់នៅពេលដែលប្រើប្រាស់ពាក្យទីផ្សារភាគហ៊ុន ព្រោះពួកគេអាចយល់ថា ភាគហ៊ុនគឺជាឧបករណ៍តែមួយគត់ដែលត្រូវបានគេទិញ-លក់នៅលើទីផ្សារនេះ។ ក្រោយមក ឧបករណ៍ទាំងអស់នោះ ដែលគេទិញ-លក់ត្រូវបានគេហៅថា មូលបត្រ (Securities) ជំនួសវិញ ហើយទីផ្សារដែលជាកន្លែងទិញ-លក់មូលបត្រនេះ ជាទីផ្សារមូលបត្រវិញ។

បច្ចុប្បន្នទីផ្សារមូលបត្រ មាននៅប្រទេសអភិវឌ្ឍស្ទើរតែទាំងអស់ និង មាននៅប្រទេសកំពុងអភិវឌ្ឍមួយចំនួន ហើយប្រទេសកំពុងអភិវឌ្ឍមួយចំនួនផ្សេងៗទៀត ក៏កំពុងតែខិតខំបង្កើតទីផ្សារនេះឡើងផងដែរ។ ទីផ្សារមូលបត្រដែលធំៗជាងគេ មាននៅក្នុងសហរដ្ឋអាមេរិច ចក្រភពអង់គ្លេស ជប៉ុន ឥណ្ឌា ចិន កាណាដា អាឡឺម៉ង់ បារាំង កូរ៉េខាងត្បូង និងហូឡង់។

### ១.២.២. និយមន័យទីផ្សារមូលបត្រ

[8]និយមន័យនៃទីផ្សារមូលបត្រ មិនត្រូវបានកំណត់យ៉ាងជាក់លាក់នោះទេ ដោយសារតែការអភិវឌ្ឍន៍យ៉ាងលឿននៃវិស័យនេះ ប៉ុន្តែជាទូទៅទីផ្សារមូលបត្រត្រូវបានគេឲ្យនិយមន័យថា ជាកន្លែងបង្ហាញនូវប្រតិបត្តិការទិញ-លក់មូលបត្រ និងក្រដាសបំណុលរយៈពេលមធ្យម និងវែងចាប់ពី ១ឆ្នាំឡើងទៅ។

[8] សួន ចំរើន, "ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១ ២០១៨-២០១៩", ទំព័រទី ២០

### ១.២.៣. ប្រភេទទីផ្សារមូលបត្រ

#### ១.២.៣.១. ទីផ្សារដំបូង ( Primary Market )

[៩]ទីផ្សារដំបូង គឺជាកន្លែងបោះផ្សាយមូលបត្រលើកដំបូង ដើម្បីលក់ទៅឲ្យសាធារណជន (ហេតុនេះបណ្ដាមូលបត្រនេះត្រូវបានហៅថា មូលបត្រថ្មី) ការបង្កើតមូលធនឲ្យអ្នកបោះផ្សាយ និងគ្រាន់តែបង្កើតនូវមធ្យាបាយប្រមូលមូលធនប៉ុណ្ណោះ។ តួនាទីចម្បងរបស់ទីផ្សារដំបូង គឺបង្កើតទំនិញឲ្យទីផ្សារជួញដូរ និងធ្វើឲ្យកើនមូលធនវិនិយោគដល់វិស័យសេដ្ឋកិច្ច។ មុខងារនេះអាចបញ្ជាក់ដូចជា ជាដំណើរការនៃមូលបត្រ ដើម្បីប្រមូលនូវមូលធនពេលត្រូវការ និងជាដំណើរការហិរញ្ញវត្ថុដោយផ្ទាល់ ដែលផ្ទេរសាច់ប្រាក់ទៅជាទម្រង់មូលបត្ររយៈពេលមធ្យម និងរយៈពេលវែង។

ទីផ្សារដំបូង គឺជាទីផ្សារបោះផ្សាយ ពីព្រោះកន្លែងនេះជាកន្លែងទិញ-លក់បណ្ដាមូលបត្រដែលទើបបោះផ្សាយលើកដំបូងរវាងអ្នកបោះផ្សាយ (អ្នកលក់) និងអ្នកវិនិយោគ (អ្នកទិញ)។ នៅលើទីផ្សារដំបូង រដ្ឋាភិបាល និងបណ្ដាក្រុមហ៊ុន អនុវត្តការប្រមូលមូលធនតាមរយៈការបោះផ្សាយ ការលក់មូលបត្ររបស់ខ្លួនឲ្យអ្នកវិនិយោគក្នុងគោលបំណង៖ បណ្ដារដ្ឋអំណាចតាមស្រទាប់ឋានៈ បោះផ្សាយមូលបត្រលក់ឲ្យបណ្ដាលតម្រូវការចាំបាច់ផ្សេងៗគ្នា និងបណ្ដាក្រុមហ៊ុនបោះផ្សាយ មូលបត្រ ដើម្បីបង្កើតជាក្រុមហ៊ុនភាគហ៊ុន ឬ ប្រមូលមូលធនបន្ថែម ដើម្បីពង្រីកអាជីវកម្ម។

រូបភាពទី៣៖ យន្តការទីផ្សារដំបូង




ប្រភព៖ ហាក់ ស្រីល័ក្ខ និង អ៊ឹង ហ៊ុយមាន, ឆ្នាំ២០១៧ "ដំណើរការបោះផ្សាយមូលបត្រនៅកម្ពុជា", ទំព័រទី ១០

[៩] សួន ចំរើន, "រូបិយវត្ថុ និងធនាគារ ២០១៧-២០១៨", ទំព័រទី ៤៧-៤៨

**១.២.៣.២. ទីផ្សារបន្ទាប់** ( Secondary Market )

[10]ទីផ្សារបន្ទាប់ ជាទីកន្លែងជួញដូរ ទិញ-លក់នូវមូលបត្រដែលបានបោះផ្សាយនៅលើទីផ្សារបន្ទាប់ និងជាចំណែកមួយដ៏សំខាន់របស់ទីផ្សារហិរញ្ញវត្ថុ ដែលផ្សារភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធគ្នាជាមួយនឹងទីផ្សារដំបូង។ ប៉ុន្តែប្រភេទមូលបត្រជួញដូរនៅទីនេះ អាចត្រូវបានទិញហើយលក់វិញច្រើនដងជាមួយនឹងតម្លៃខ្ពស់ ទាបផ្សេងៗគ្នា ពីព្រោះជាក់ស្តែងទីផ្សារបន្ទាប់ អាចហៅថាជាទីផ្សារជួញដូរមូលបត្រ។

ទីផ្សារបន្ទាប់ អនុវត្តនូវតួនាទីកែតម្រូវការចរាចរសាច់ប្រាក់ ជានាការផ្ទេរមូលបត្ររយៈពេលខ្លីឲ្យក្លាយទៅជារយៈពេលវែង និងបញ្ជូនទៅវិនិយោគដើម្បីអភិវឌ្ឍសេដ្ឋកិច្ច។ ដោយមានទីផ្សារបន្ទាប់ បណ្តាអ្នកមានមូលធនទំនេរជាបណ្តោះអាសន្នអាចស្ងប់ចិត្ត ដើម្បីវិនិយោគលើមូលបត្រ ពីព្រោះពេលត្រូវការសាច់ប្រាក់ ពួកគេអាចលក់មូលបត្ររបស់ខ្លួនវិញឲ្យបណ្តាអ្នកវិនិយោគផ្សេងៗទៀតនៅលើទីផ្សារបន្ទាប់។

ទីផ្សារបន្ទាប់ អនុវត្តនូវមុខងារដូចខាងក្រោម៖

- បង្កើតលក្ខណៈងាយស្រួល ដើម្បីលក់បណ្តាឧបករណ៍ហិរញ្ញវត្ថុក្នុងគោលបំណងប្រមូលនូវសាច់ប្រាក់ និងបង្កើននូវឧបករណ៍ហិរញ្ញវត្ថុ មានន័យថាបង្កើននូវលក្ខណៈងាយស្រួលក្នុងការផ្ទេរសាច់ប្រាក់ទៅជាឧបករណ៍ហិរញ្ញវត្ថុ និងផ្ទេរពីឧបករណ៍ហិរញ្ញវត្ថុទៅជាសាច់ប្រាក់។
- រកផលចំណេញពីការកាន់កាប់មូលបត្រ
- កំណត់តម្លៃមូលបត្រឲ្យសមស្របផ្អែកលើមូលដ្ឋានដេញថ្លៃដោយសេរី (ការប្រកួតប្រជែងដោយសេរី)
- តម្លៃសមរម្យនៅលើទីផ្សារបន្ទាប់ ជះឥទ្ធិពលដល់តម្លៃបោះផ្សាយមូលបត្រនៅលើទីផ្សារបន្ទាប់ និងត្រូវកំណត់តម្លៃមូលបត្រថ្មីដែលក្រុមហ៊ុនទើបបោះផ្សាយនៅទីផ្សារបន្ទាប់។

[10] សួន ចំរើន, "រូបិយវត្ថុ និងធនាគារ ២០១៧-២០១៨", ទំព័រទី ៤៨, ៤៩

**ទីផ្សារបន្ទាប់ អាចប្រតិបត្តិការតាម ២វិធីគឺ៖**

- Organized Exchange: ប្រតិបត្តិការតាមមូលដ្ឋានជួញដូរ គឺជាមជ្ឈមណ្ឌលជួញដូរដែលមានទីតាំងត្រឹមត្រូវ។
- OTC Market (Over the Counter Market): គឺតាមរយៈការទិញ-លក់មូលបត្រដោយត្រង់ៗ ឲ្យអ្នកណាម្នាក់ដែលទទួលស្គាល់នូវតម្លៃដែលអ្នកលក់បានកំណត់ វាមានលក្ខណៈប្រកួតប្រជែងខ្ពស់។

### ១.២.៤. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចកម្ពុជា

[11]ទីផ្សារមូលបត្រ គឺជាសរសៃឈាមដ៏សំខាន់សម្រាប់ក្រុមហ៊ុនបោះផ្សាយ វិនិយោគិននានា ក៏ដូចជាសេដ្ឋកិច្ចជាតិទាំងមូល។ អាស្រ័យហេតុនេះ គ្រប់ប្រទេសទាំងអស់នៅលើពិភពលោកតែងតែផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបង្កើត និងអភិវឌ្ឍទីផ្សារនេះ ដើម្បីធានាបាននូវការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយភាពរឹងមាំ និងចីរភាពក្នុងទិសដៅរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។

ក្នុងរយៈពេលជាងមួយទសវត្សកន្លងទៅ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចជាមធ្យមក្នុងអត្រាប្រមាណ ៨,៥% ក្នុងមួយឆ្នាំ ទោះជាត្រូវជួបប្រឈមនឹងភាពមិនប្រាកដប្រជា និងហានិភ័យជាច្រើនទាំងក្នុង និងក្រៅប្រទេសយ៉ាងណាក៏ដោយ។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងស្ថាប័នសកល បានចាត់ទុកកម្ពុជាថាជាប្រទេសមួយក្នុងចំណោមប្រទេសប្រាំបីដែលមានភាពធន់នៃកំណើនសេដ្ឋកិច្ចខ្ពស់បំផុត។

ការសម្រេចបាននូវសមិទ្ធផលទាំងអស់នេះ បានរុញច្រានកម្ពុជាឲ្យមកដល់ខ្លង់រាបថ្មីមួយទៀត គឺឈានដល់ដំណាក់កាលនៃការអភិវឌ្ឍថ្មីមួយ ដែលកំពុងប្រែក្លាយកម្ពុជាជាប្រទេសចំណូលមធ្យមកម្រិតទាប ហើយកម្ពុជាត្រូវធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់សម្រាប់ជាមូលដ្ឋាននៃការបង្កើតការងារ និងឱកាសរកប្រាក់ចំណូលសមរម្យ។

ក្នុងន័យនេះ វិស័យមូលបត្រត្រូវបានអភិវឌ្ឍ និងដើរតួជាមធ្យោបាយនៃការកៀរគរមូលធន និងការបែងចែកមូលធននៅកម្ពុជាឲ្យកាន់តែសម្បូរបែបសម្រាប់គម្រោងវិនិយោគនានា ដែលជាចលករនៃកំណើនសេដ្ឋកិច្ចជាតិ។

[11] គណៈកម្មការមូលបត្រកម្ពុជា, "អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ", ទំព័រទី ១០-១៥

រហូតមកដល់ពេលនេះ ហេដ្ឋារចនាសម្ព័ន្ធគន្លឹះនៃទីផ្សារមូលបត្រ ត្រូវបានដាក់ឲ្យដំណើរការជាបន្តបន្ទាប់ ដែលក្នុងនោះរួមមាន ហេដ្ឋារចនាសម្ព័ន្ធគតិយុត្ត ប្រព័ន្ធប្រតិបត្តិការ អ្នកចូលរួមក្នុងទីផ្សារ វិនិយោគិន និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាដើម។

ការអភិវឌ្ឍទីផ្សារមូលបត្រនឹងនាំមកនូវអត្ថប្រយោជន៍ដូចតទៅ៖

- រួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ

  នៅក្នុងទីផ្សារមូលបត្រ ភាគហ៊ុនរបស់ក្រុមហ៊ុនជាច្រើនត្រូវបានទិញ-លក់។ ដំណើរការទិញ-លក់ទាំងនេះអាចជួយក្នុងដំណើរការអនុវត្តគម្រោងវិនិយោគ ដែលមានផលិតភាពខ្ពស់ដែលអាចឈានទៅដល់ការបង្កើតមូលធន និងនាំឲ្យមានកំណើនសេដ្ឋកិច្ច។ ប្រភពដើមទុន និងសាច់ប្រាក់ដែលរាយប៉ាយ នឹងត្រូវប្រមូលចងក្រងយកទៅប្រើប្រាស់ចំទិសដៅ ហើយផ្តល់ជាប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ។ ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តន៍នូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។
- ជំរុញការវិនិយោគ និងបង្កើតការងារ

  តាមរយៈទីផ្សារមូលបត្រ ក្រុមហ៊ុនបោះផ្សាយនឹងមានលទ្ធភាពបង្កើនទុនសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន ដោយទទួលបានដើមទុនច្រើន និងមានរយៈពេលវែង។ បច្ច័យនេះនឹងជំរុញ ព្រមទាំងលើកទឹកចិត្តឲ្យក្រុមហ៊ុនធ្វើការវិនិយោគបន្ថែម ក៏ដូចជាបន្ថែមតម្រូវការបុគ្គលិកសម្រាប់បំពេញការងារក្នុងស្ថាប័នខ្លួនឯងផងដែរ។ ក្នុងន័យនេះ អត្រានិកម្មភាពក្នុងប្រទេសក៏នឹងត្រូវបានកាត់បន្ថយផងដែរ ប្រសិនក្រុមហ៊ុនមានដើមទុនសម្រាប់ធ្វើការវិនិយោគបន្ថែម។
- ទទួលបានការលើកទឹកចិត្តពន្ធដារ

  ដោយយល់ដឹងពីអត្ថប្រយោជន៍ និងដើម្បីជម្រុញវិស័យមូលបត្រកម្ពុជាឲ្យរីកចម្រើនកាន់តែឆាប់រហ័ស រាជរដ្ឋាភិបាលកម្ពុជា បានចេញអនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដោយផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងចុះបញ្ជីជួញដូរមូលបត្រនៅផ្សារមូលបត្រ បានជោគជ័យមុនដំណាច់ឆ្នាំ២០១៧ ឲ្យទទួលបានការអនុគ្រោះបំណុលពន្ធ និងកាត់បន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% រយៈពេល ៣ឆ្នាំ ព្រមទាំងលើកលែងការបង់ពន្ធរំលោះលើប្រាក់

ចំណេញ ១% ប្រចាំខែ។ ម្យ៉ាងទៀត វិនិយោគិនក៏ទទួលបានការលើកទឹកចិត្តពន្ធដារ ដោយកាត់បន្ថយពន្ធលើភាគលាភ ឬ ការប្រាក់ ៥០% ផងដែរ។

- ធានាស្ថេរភាពអាជីវកម្ម និងកាត់បន្ថយចំណាយប្រតិបត្តិការ
  ទីផ្សារមូលបត្រនឹងជួយសម្រួលដល់អាជីវកម្មឲ្យមានភាពយូរអង្វែង ដោយសារទីផ្សារមូលបត្រអនុញ្ញាតឲ្យក្រុមហ៊ុនកៀរគរ និងប្រមូលទុនបានច្រើន ដោយប្រើប្រាស់ថ្លៃដើមទាបមានរយៈពេលវែង និងពុំចាំបាច់ជាប់កាតព្វកិច្ចសង ហើយក្រុមហ៊ុនក៏អាចធ្វើការប្រមូលទុនបន្ថែមសម្រាប់ពង្រីកអាជីវកម្មបានច្រើនដង។ ដូចនេះ ទីផ្សារមូលបត្រ គឺជាឧបករណ៍ និងជាមធ្យោបាយដ៏ប្រសើរសម្រាប់ជួយធានាបន្ថែមដល់ស្ថេរភាពអាជីវកម្ម។
- ផ្តល់គុណតម្លៃកេរ្តិ៍ឈ្មោះ និងសុវត្ថិភាពដល់ប្រតិបត្តិការ
  នៅក្នុងទីផ្សារមូលបត្រ មានតែភាគហ៊ុនដែលបានចុះបញ្ជីតែប៉ុណ្ណោះ ដែលអាចជួញដូរបាន ហើយគណៈកម្មការមូលបត្រកម្ពុជាបានផ្តល់សិទ្ធិឲ្យចុះបញ្ជីសម្រាប់តែក្រុមហ៊ុនណាដែលមានភាពរឹងមាំផ្នែកហិរញ្ញវត្ថុ និងមានគុណវុឌ្ឍិគ្រាប់គ្រាន់តែប៉ុណ្ណោះ។ ក្រុមហ៊ុនដែលបានចុះបញ្ជីនៅទីផ្សារ ត្រូវប្រតិបត្តិទៅតាមច្បាប់ និងបទប្បញ្ញត្តិ ដើម្បីធានាបាននូវការទទួលស្គាល់កេរ្តិ៍ឈ្មោះ និងប្រសិទ្ធភាពនៃការគ្រប់គ្រងបានល្អប្រសើរ។
- ចែករំលែកព័ត៌មានដោយសមធម៌
  គណៈកម្មការមូលបត្រកម្ពុជា ការពារសាធារណជនដែលធ្វើការវិនិយោគជាមួយទីផ្សារមូលបត្រ ដោយការដាក់កម្រិតលើការបោះផ្សាយភាគហ៊ុនថ្មី ធ្វើឲ្យការអនុវត្តន៍ការជួញដូរកាន់តែល្អប្រសើរ និងធ្វើការអប់រំសាធារណជនអំពីការវិនិយោគ។ ក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រ ត្រូវបានត្រួតពិនិត្យ ទទួលស្គាល់ និងអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជាដែលជាអាជ្ញាធរមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុបោះផ្សាយត្រូវចេញផ្សាយរបាយការណ៍ទៅតាមពេលវេលាកំណត់ ព្រមទាំងបង្ហាញព័ត៌មានអំពីសកម្មភាពអាជីវកម្មរបស់ខ្លួន និងអភិបាលកិច្ចសាជីវកម្ម ដើម្បីផ្តល់នូវទំនុកចិត្តដល់វិនិយោគិន។
- ទទួលបានចំណូលពីការវិនិយោគក្នុងទីផ្សារមូលបត្រ
  មូលបត្រ គឺជាឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានគេបង្កើតឡើងសម្រាប់កសាងទ្រព្យសម្បត្តិ និងជាផ្នែកមួយនៃការវិនិយោគ។ ភាគហ៊ុន តំណាងឲ្យចំណែកនៃភាពជាម្ចាស់នៃក្រុមហ៊ុនមួយ។ ភាគហ៊ុន តំណាងឲ្យសិទ្ធិលើទ្រព្យសកម្ម និងប្រាក់ចំណូលរបស់ក្រុមហ៊ុន។

បើអ្នកកាន់កាប់ភាគហ៊ុនកាន់តែច្រើនក្នុងក្រុមហ៊ុនមួយ ភាពជាម្ចាស់របស់អ្នកនៅក្នុងក្រុមហ៊ុននោះក៏កាន់តែធំតាមនោះដែរ។ សារៈសំខាន់នៃការក្លាយជាម្ចាស់ភាគហ៊ុន គឺថាអ្នកមានសិទ្ធិទទួលបានចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុន។ ប្រាក់ចំណេញនឹងបង់ក្នុងទម្រង់ជាភាគលាភ ឬការប្រាក់។ បើអ្នកកាន់កាប់ភាគហ៊ុនកាន់តែច្រើន អ្នកនឹងទទួលបានចំណែកនៃប្រាក់ចំណេញកាន់តែច្រើនតាមនោះដែរ។ ក្នុងនាមជាម្ចាស់ភាគហ៊ុន អ្នកពុំចាំបាច់មានកាតព្វកិច្ចទទួលខុសត្រូវផ្ទាល់នោះទេ នៅពេលក្រុមហ៊ុនមិនអាចសងបំណុលម្ចាស់បំណុលបាន។ ទោះបីជាមានបញ្ហាអ្វីក៏ដោយ តម្លៃអតិបរមាដែលអ្នកអាចបោះបង់ គឺជាតម្លៃនៃការ វិនិយោគរបស់អ្នក។

- ជួយជំរុញទម្លាប់សន្សំ និងវិនិយោគ

ទីផ្សារមូលបត្រ ផ្តល់នូវឱកាសនៃការវិនិយោគដ៏ទាក់ទាញ តាមរយៈភាគហ៊ុនរបស់ក្រុមហ៊ុនជាច្រើននៅក្នុងទីផ្សារ។ ឱកាសវិនិយោគទាំងនេះ លើកទឹកចិត្តឲ្យប្រជាជនមានការសន្សំច្រើនជាងមុន និងធ្វើការវិនិយោគជាមួយវិស័យមូលបត្រ ជាជាងយកប្រាក់ទៅវិនិយោគជាមួយទ្រព្យដែលគ្មានផលិតកម្មដូចជា មាស ឬប្រាក់ជាដើម។ វិស័យមូលបត្រនឹងជួយបំពេញបន្ថែមគុណភាពនៃការសម្រេចចិត្តវិនិយោគរបស់ប្រជាជនខ្មែរ។

- ផ្តល់នូវសន្ទនីយភាព

មុខងារដ៏សំខាន់មួយទៀតនៃទីផ្សារមូលបត្រ គឺការផ្តល់នូវភាពត្រៀមជាស្រេចសម្រាប់ការលក់ និងការទិញមូលបត្រ។ វត្តមាននៃទីផ្សារមូលបត្រ បានជួយសម្រួលដល់វិនិយោគិនដោយការវិនិយោគរបស់ពួកគេអាចត្រូវបានប្តូរជាសាច់ប្រាក់បានគ្រប់ពេល នៅពេលដែលពួកគេត្រូវការ។ វិនិយោគិនអាចវិនិយោគជាមួយគម្រោងវិនិយោគរយៈពេលវែងដោយគ្មានភាពស្ទាក់ស្ទើរ ដោយសារគេអាចបម្លែងការវិនិយោគរយៈពេលវែងនេះទៅជាការវិនិយោគរយៈពេលខ្លី។

### ១.២.៥. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន

[12]តាមរយៈទីផ្សារមូលបត្រនេះ វិនិយោគិនទទួលបានអត្ថប្រយោជន៍ជាច្រើនដូចជា៖

- ប្រាក់ចំណេញមូលធន (Capital Gain)

អត្ថប្រយោជន៍ចម្បងនៃការវិនិយោគនៅក្នុងទីផ្សារភាគហ៊ុននេះ គឺជាឱកាសលូតលាស់ប្រាក់របស់អ្នក។ វិនិយោគិនទទួលបានអត្រាការប្រាក់ខ្ពស់ បើធៀបទៅនឹងការដាក់ប្រាក់

[12] ឆេក ច័ន្ទម៉ារីទី និង គន្ធា បូរ៉ានិត, ឆ្នាំ២០១៦, "ការលើកទឹកចិត្តក្នុងវិស័យមូលបត្រនៅកម្ពុជា", ទំព័រទី ២០

ក្នុងធនាគារ។ កន្លងមកទីផ្សារភាគហ៊ុននេះមាននិន្នាការថ្លៃកើនឡើង បើទោះជាតម្លៃហ៊ុនរបស់បុគ្គលម្នាក់ៗប្រចាំថ្ងៃមានការកើនឡើង ឬ ធ្លាក់ចុះក៏ដោយ។ ការវិនិយោគនៅក្នុងក្រុមហ៊ុន ដែលមានស្ថេរភាពដែលអាចធ្វើឲ្យប្រាក់ចំណេញរបស់វិនិយោគិនមានការកើនឡើង។

- ចំណូលភាគលាភ (Dividend)

ក្រៅពីប្រាក់ចំណេញមូលធន វិនិយោគិននឹងទទួលបានភាគលាភពីការវិនិយោគលើផ្សារមូលបត្រ។ ភាគលាភ គឺសំដៅដល់ការបែងចែកផ្នែកមួយនៃប្រាក់ចំណេញទៅឲ្យភាគហ៊ុនិកដែលបានសម្រេចពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ហើយជាធម្មតាត្រូវទូទាត់ក្នុងទម្រង់ជាសាច់ប្រាក់ ឬក៏ទទួលបានភាគហ៊ុនបន្ថែម ឬទ្រព្យផ្សេងៗទៀត។ ដូច្នេះវិនិយោគិននឹងទទួលបានផលចំណេញជាភាគលាភ បន្ទាប់ពីបានទិញមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយទៅតាមគោលការណ៍នយោបាយបែងចែកភាគលាភ។

- ពិពិធកម្ម (Diversification)

វិនិយោគិនដែលបានដាក់ប្រាក់វិនិយោគចូលទៅក្នុងប្រភេទផ្សេងៗគ្នា នៃការវិនិយោគលើផ្សារហ៊ុន នឹងទទួលបានផលប្រយោជន៍ជាច្រើនពីពិពិធកម្ម។ ពិពិធកម្ម មានន័យថាការយកទុនទៅវិនិយោគក្នុងទម្រង់ផ្សេងៗដូចជា មូលបត្រកម្មសិទ្ធិ មូលបត្របំណុល ក្នុងគោលបំណងធ្វើឲ្យហានិភ័យនៃមូលបត្រថយចុះ។

- ភាពជាម្ចាស់ (Ownership)

ការទិញភាគហ៊ុន មានន័យថាការទទួលយកបង្គោលកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនដែលអ្នកបានទិញនេះ។ ការវិនិយោគនៅក្នុងទីផ្សារភាគហ៊ុន ក៏បាននាំមកនូវផលប្រយោជន៍មួយនៃការធ្វើជាម្ចាស់កម្មសិទ្ធិដែលហៅថា ភាគហ៊ុនិក។ ភាគហ៊ុនិកមានសិទ្ធិបោះឆ្នោតរើស ឬដកហូតសមាជិកក្រុមប្រឹក្សាភិបាល និងការសម្រេចចិត្តផ្លាស់ប្តូរឯកសារចុះបញ្ជីរបស់ក្រុមហ៊ុន។

## ១.៣. ឆាតុផ្សំសំខាន់ៗនៅក្នុងទីផ្សារមូលបត្រ

[13]ទីផ្សារមូលបត្រ ត្រូវបានបង្កើតឡើងស្របតាមទិសដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុស៊ីជម្រៅ និងគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ រហូតមក

[13] ស៊ូ សុជា និង អ៊ួង នីតា, ឆ្នាំ២០១៥ "ការវិនិយោគលើមូលបត្រនៅផ្សារមូលបត្រកម្ពុជា និងការ វិនិយោគលើភាគហ៊ុន", ទំព័រទី ១០-១២

ដល់ពេលនេះ អត្ថិភាពនៃអង្គទាំង ៤ ជាសារវន្តដែលគាំទ្រដល់ដំណើរការនៃទីផ្សារមូលបត្រ ត្រូវបានកសាងជាបន្តបន្ទាប់រួមមាន៖

**១.៣.១. ហេដ្ឋារចនាសម្ព័ន្ធ** ( Infrastructure )

ហេដ្ឋារចនាសម្ព័ន្ធ គឺជាតួអង្គមួយដ៏សំខាន់ក្នុងដំណើរការទ្រទ្រង់ទីផ្សារមូលបត្រ។ ហេដ្ឋារចនាសម្ព័ន្ធ គឺសំដៅដល់ទីតាំងប្រព័ន្ធជួញដូរមូលបត្រ ក្របខណ្ឌច្បាប់ ក្របខណ្ឌគ្រប់គ្រងទីផ្សារមូលបត្រ និងធនធានមនុស្សសម្រាប់ទ្រទ្រង់ដល់ការអភិវឌ្ឍទីផ្សារមូលបត្រឲ្យមានដំណើរការល្អ ក្នុងគោលដៅបង្កើតទីផ្សារមូលបត្រមួយឲ្យប្រព្រឹត្តទៅដោយតម្លាភាពសន្ទនីយភាព ប្រសិទ្ធភាព សុវត្ថិភាព និងការពារវិនិយោគិន។

**១.៣.២. អន្តរការី** ( Intermediary )

អន្តរការីមូលបត្រ ជាផ្នែកមួយសំខាន់ដែលមិនអាចខ្វះបានក្នុងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទ្រទ្រង់ដល់ភាពជោគជ័យនៃដំណើរការទីផ្សារមូលបត្រ។ អន្តរការីមូលបត្រ ជាក្រុមហ៊ុនមូលបត្រដែលមានតួនាទីក្នុងការធ្វើប្រតិបត្តិការអាជីវកម្មមូលបត្រ ដើម្បីជួយសម្រួលដល់ដំណើរការនៃការទិញ-លក់មូលបត្រនៅលើទីផ្សារ។ អន្តរការីមូលបត្ររួមមាន ៖

- **ក្រុមហ៊ុនធានាទិញមូលបត្រ (Securities Underwriters)**

  ក្រុមហ៊ុនធានាទិញមូលបត្រ ឬ ធនាគារវិនិយោគ គឺជាក្រុមហ៊ុនដែលធ្វើការផ្តល់ការប្រឹក្សា និងចាត់ចែងការបោះផ្សាយមូលបត្រជាសាធារណៈដល់ក្រុមហ៊ុនបោះផ្សាយ ហើយធានាទិញមូលបត្រទទួលបានកម្រៃពីក្រុមហ៊ុនបោះផ្សាយ តាមរយៈការប្រឹក្សាយោបល់លើប្រភេទមូលបត្រដែលត្រូវបោះផ្សាយ នីតិវិធី និងពេលវេលានៃការបោះផ្សាយ និងការកំណត់តម្លៃលក់។ លើសពីនេះ ប្រភពចំណូលមួយផ្សេងទៀតរបស់ក្រុមហ៊ុនធានាទិញមូលបត្រ គឺប្រាក់ចំណេញដែលបានមកពីការលក់មូលបត្រដែលខ្លួនបានទិញពីក្រុមហ៊ុនបោះផ្សាយ។

- **ក្រុមហ៊ុនពាណិជ្ជករមូលបត្រ (Securities Dealers)**

  មានតួនាទីដ៏សំខាន់ក្នុងការជួញដូរមូលបត្រនៅក្នុងទីផ្សារបន្ទាប់តាមរយៈ ប្រព័ន្ធជួញដូរមូលបត្រលើគណនីផ្ទាល់ខ្លួន ដោយរ៉ាប់រងលើហានិភ័យដោយខ្លួនឯងទៀតផង។ មានន័យថា ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ដើរតួជាម្ចាស់នៅក្នុងការធ្វើប្រតិបត្តិការទិញ-លក់មូលបត្រ។

- **ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ** (Securities Brokers)

  ជាអន្តរការីទីផ្សារមូលបត្រដែលដើរតួនាទីជាឈ្មួញកណ្តាលរវាងអ្នកលក់ និងអ្នកទិញក្នុងប្រតិបត្តិការទិញ-លក់មូលបត្រ និងធ្វើការដាក់បញ្ជាតាមអតិថិជនខ្លួនដោយទទួលបានកម្រៃជើងសារ។

- **ក្រុមហ៊ុនផ្តល់ប្រឹក្សាវិនិយោគមូលបត្រ** (Investment Advisors)

  ជាក្រុមហ៊ុនដែលផ្តល់សេវាប្រឹក្សាផ្នែកវិនិយោគ ឬ ផ្តល់ជាការវិភាគមូលបត្រឲ្យទៅអតិថិ-ជនដើម្បីទទួលបានកម្រៃ។ ការផ្តល់ប្រឹក្សានេះអាចធ្វើឡើងតាមរយៈការជួបផ្ទាល់ជាមួយអតិថិជន ឬធ្វើការបោះផ្សាយសេចក្តីវិភាគដែលមានដូចជា ព្រឹត្តិបត្រវិភាគអំពីស្ថានភាពសេដ្ឋកិច្ច ស្ថានភាពទូទៅរបស់ទីផ្សារមូលបត្រ ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះ-ផ្សាយជាដើម។

**១.៣.៣. ក្រុមហ៊ុនបោះផ្សាយ** ( Issuer )

ក្រុមហ៊ុនបោះផ្សាយមូលបត្រ គឺជាស្ថាប័នស្របច្បាប់ដែលបានចុះបញ្ជីលក់មូលបត្រក្នុងគោលបំណងទទួលបានហិរញ្ញប្បទានដើម្បីទ្រទ្រង់ ឬពង្រីកប្រតិបត្តិការរបស់ខ្លួន។ ក្រុមហ៊ុនបោះផ្សាយអាចជាសហគ្រាសសាធារណៈ ឬក្រុមហ៊ុនសាជីវកម្ម ដែលជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត (Public Limited Company) គឺជាក្រុមហ៊ុនដែលបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មក្នុងគោលបំណងបោះ-ផ្សាយលក់មូលបត្រជាសាធារណៈ។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវមានកាតព្វកិច្ចផ្តល់របាយ-ការណ៍ហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធនានាដែលតម្រូវតាមច្បាប់។

**១.៣.៤. វិនិយោគិន** ( Investors )

វិនិយោគិន គឺជាអ្នកដែលដាក់ទុនធ្វើវិនិយោគក្នុងវិស័យមូលបត្រក្នុងគោលបំណងទទួលបានប្រាក់ចំណេញ ឬភាគលាភនៅពេលដែលលក់មូលបត្រទៅវិញនាពេលអនាគត។ វិនិយោគិនអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល។ ជាទូទៅវិនិយោគិនមាន ២ ប្រភេទគឺ៖

- ❖ **វិនិយោគិនជារូបវន្តបុគ្គល ឬឯកត្តជន** (Individual Investors)

  សំដៅដល់អ្នកវិនិយោគដែលចាត់ចែង និងគ្រប់គ្រងមូលនិធិផ្ទាល់ខ្លួនរួមមាន បុគ្គលធម្មតាដែលវិនិយោគិនប្រភេទនេះ ជាទូទៅធ្វើការទិញ ឬលក់មូលបត្រក្នុងទំហំមួយតូច ដែលគេហៅថា អ្នកវិនិយោគរាយ។

- **វិនិយោគិនជានីតិបុគ្គល (Institutional Investors)**

ជាប្រភេទនៃអ្នកវិនិយោគប្រកបដោយវិជ្ជាជីវៈ ដែលគ្រប់គ្រង និងចាត់ចែងមូលនិធិសម្រាប់ស្ថាប័នរួមមាន ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង មូលនិធិរួម (Mutual fund) និងមូលនិធិសោធនិវត្តន៍ (Pension Fund) ដែលវិនិយោគិនប្រភេទនេះធ្វើការវិនិយោគជាលក្ខណៈទ្រង់ទ្រាយធំ។

# ជំពូក ២

# ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

## ២.១. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)

### ២.១.១. ប្រវត្តិរបស់ ផ.ម.ក.

[14]ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រទេសកម្ពុជា ដោយឈរលើគោលដៅក្នុងការជំរុញកំនើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធន ការវិនិយោគ និង ការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែវិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបើកអោយដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជា នៅខែកញ្ញា ឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ អនុស្សរណៈយោគយល់មួយទៀត ស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែមីនា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ "ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្ម នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០។ ស្របតាមកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានទទួលអាជ្ញាបណ្ណជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

[14] http://www.csx.com.kh/kh/about/profile.jsp?MNCD=10301ប្រវត្តិ ផ.ម.ក.

កាលបរិច្ឆេទសំខាន់ៗអំពីប្រវត្តិ ផ.ម.ក. ៖

- **ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៦** ៖ ការចុះអនុស្សរណៈយោគយល់អំពីការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា។
- **ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៧** ៖ ការដាក់ឲ្យដំណើរការគម្រោងបង្កើតផ្សារមូលបត្រនៅកម្ពុជា។
- **ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨** ៖ ការចុះអនុស្សរណៈយោគយល់អំពីការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា។
- **ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩** ៖ ការចុះកិច្ចព្រមព្រៀង "ក្រុមហ៊ុនចម្រុះ" រវាងរាជរដ្ឋាភិបាលកម្ពុជាតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។
- **ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០** ៖ ចុះបញ្ជីពាណិជ្ជកម្ម
- **ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១** ៖ ការទទួលបានការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រពី គ.ម.ក.
- **ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១** ៖ ការសម្ពោធដាក់ឲ្យដំណើរការក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាធ្វើឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា។
- **ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២** ៖ ពិធីប្រកាសបើកការជួញដូរមូលបត្រនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

## ២.១.២. រូបសញ្ញា និងនាមករណ៍របស់ ផ.ម.ក.

### រូបសញ្ញា

រូបភាពទី៨៖ រូបសញ្ញាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ប្រភព៖ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

- ផ្នែកខាងលើ មានអក្សរពណ៌ខៀវថា ផ្សារមូលបត្រកម្ពុជា ដែលជាឈ្មោះតំណាងក្រុមហ៊ុន។
- ផ្នែកខាងស្តាំ មានរូបហង្សពណ៌មាសមួយ ឈរបែរមុខទៅស្តាំ។
- ផ្នែកខាងឆ្វេង មានអក្សរពណ៌ខៀវជាភាសាអង់គ្លេសថា CSX ដែលជាអក្សរកាត់មកពីពាក្យថា Cambodia Securities Exchange។

### នាមករណ៍

រូបសញ្ញារបស់ក្រុមហ៊ុនមាននាមករណ៍ជាភាសាខ្មែរថា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលហៅកាត់ថា ផ.ម.ក. និងជាភាសាអង់គ្លេសថា Cambodia Securities Exchange ដែលហៅកាត់ថា CSX។

### ២.១.៣. រចនាសម្ព័ន្ធរបស់ ផ.ម.ក.

រូបភាពទី៥៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ ផ.ម.ក.




ប្រភព៖ http://www.csx.com.kh/kh/about/org.jsp?MNCD=10302

## ការតែងតាំងក្រុមប្រឹក្សាភិបាលនៃ ផ.ម.ក.

រូបភាពទី៦៖ ក្រុមប្រឹក្សាភិបាលនៃ ផ.ម.ក.




ប្រភព៖ http://www.csx.com.kh/kh/about/director.jsp?MNCD=10303

❖ ក្រុមប្រឹក្សាភិបាលនៃ ផ.ម.ក. រួមមានសមាជិកចំនួន ៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល (ដែលជាអគ្គនាយករងផងដែរ) និងអគ្គ-នាយក។ ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំណែកឯអនុប្រធានក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

❖ សមាជិកចំនួន ៤រូបផ្សេងទៀត គឺជាអភិបាលមិនអចិន្ត្រៃយ៍ ដោយក្នុងនោះ ២រូបត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២រូបទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

សមាជិកក្រុមប្រឹក្សាភិបាលទាំង ៧រូបរួមមាន៖

- **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប**
  ជាប្រធានក្រុមប្រឹក្សាភិបាល និងជារដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **ឯកឧត្តម ហុង សុហួរ**
  ជាសមាជិក និងជាអគ្គនាយកនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- Mr. HA Jong Weon
  ជាអនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយករងនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- **លោក វ័ត្ន សារុធ**
  ជាសមាជិក និងជាអគ្គនាយករងនៃធនាគារជាតិនៃកម្ពុជា
- **លោក ហ៊ីម ហ៊ាន**
  ជាសមាជិក និងជាប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម
- Mr. SONG Young Hun
  ជាសមាជិក
- Mr. KWON Chankoog
  ជាសមាជិក

## ២.២. ចក្ខុវិស័យ និងបេសកម្មរបស់ ផ.ម.ក.

ចក្ខុវិស័យរបស់ ផ.ម.ក. គឺ "ដើម្បីកសាងនូវមហាវិថីហិរញ្ញវត្ថុសម្រាប់កម្ពុជា" មានន័យថា ធ្វើឲ្យវិស័យហិរញ្ញវត្ថុនៅកម្ពុជាមានដំណើរការយ៉ាងរលូន និងទទួលបានជោគជ័យជាលំដាប់ ព្រមទាំងមានបំណងធ្វើឲ្យក្រុមហ៊ុនរបស់ខ្លួនដំណើរការប្រព្រឹត្តទៅយ៉ាងល្អ។

បេសកម្មចម្បងរបស់ ផ.ម.ក. រួមមាន៖

- បង្កើតឡើងនូវបរិយាកាសជួញដូរដែលប្រកបដោយភាពយុត្តិធម៌ តម្លាភាព និងភាពមានអំណោយផលដល់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស។
- ដើម្បីសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា។
- ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់អ្នកវិនិយោគិនទាំងក្នុង និងក្រៅប្រទេស។
- ដើម្បីបង្កើតនូវផលិតផល និងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួមទីផ្សារទាំងអស់។
- ដើម្បីដាក់ឲ្យដំណើរការនូវសហគ្រាសជាសាធារណៈមួយ ដែលមានស្វ័យចីរភាពក្រោមមគ្គុទេសក៍ដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

## ២.៣. ប្រតិបត្តិករនាំងបីរបស់ ផ.ម.ក.

[15]ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបានផ្តល់ការអនុញ្ញាតឲ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា ក្រោមប្រកាសលេខ ០១១គ.ម.ក. ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១។

- **ប្រតិបត្តិករទីផ្សារមូលបត្រ**

  មានតួនាទី ផ្តល់នូវសេវាសម្របសម្រួលដល់អ្នកចូលរួមក្នុងទីផ្សារ ដើម្បីធ្វើសកម្មភាពជួញដូរមូលបត្រ ឬដើម្បីឲ្យអ្នកចូលរួមក្នុងទីផ្សារ អាចទទួលបាននូវការបន្សុំលើប្រតិបត្តិការបញ្ជាទិញ លក់មូលបត្ររបស់ខ្លួន តាមរយៈទីកន្លែង ប្រព័ន្ធ ឬមធ្យោបាយសម្រាប់ជួញដូរមូលបត្រជារូបវន្ត ឬអេឡិចត្រូនិក និងសកម្មភាពអាជីវកម្មផ្សេងទៀតដែលកំណត់ដោយ គ.ម.ក.។

[15] ប្រកាសស្តីពី ការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

- **ប្រតិបត្តិករជាត់ទាត់ និងទូទាត់មូលបត្រ**

មានតួនាទី ផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ បំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមកដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការឲ្យបានច្បាស់លាស់ និងធានាឲ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឲ្យអ្នកទិញ។

- **ប្រតិបត្តិកររក្សាទុកមូលបត្រ**

បុគ្គលមួយយល់ព្រមជាមួយបុគ្គលមួយផ្សេងទៀត ដែលជាអតិថិជនរបស់ខ្លួនថាផ្តល់សេវាកម្មដូចខាងក្រោមនេះ ទោះបីជាអតិថិជននោះធ្វើសកម្មភាពក្នុងនាមខ្លួនឯង ឬធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយ៖

ក- កាន់កាប់ ឬចុះបញ្ជីសិទ្ធិស្របច្បាប់លើមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀតក្នុងនាម ជាអតិថជន ឬជាបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។

ខ- ទទួលរក្សាទុកនូវមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ទោះបីមានរូបភាពជាវិញ្ញាបនបត្រកម្មសិទ្ធិ ឬជាទម្រង់អរូបីក្តី ដោយស្របទៅតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ ក្នុងនាមជាអតិថិជន ឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។

គ- ផ្តល់សេវាកម្ម និងលក្ខណៈងាយស្រួលផ្សេងៗទៀត ដែលទាក់ទិននឹងការផ្តល់សេវាកម្ម ដូចមានចែងក្នុងកថាខណ្ឌ(ក) និង(ខ) ។

## ២.៤. សមាជិករបស់ ផ.ម.ក.

### ២.៤.១. ក្រុមហ៊ុនធានាទិញមូលបត្រ

តារាងទី១៖ បញ្ជីក្រុមហ៊ុនធានាទិញមូលបត្រ

| ស្លាកសញ្ញាក្រុមហ៊ុន | នាមករណ៍ក្រុមហ៊ុន | គេហទំព័រ |
|---|---|---|
| | ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី<br>Phnom Penh Securities Plc. | www.pps.com.kh |
| | អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី ម.ក<br>RHB Indochina Securities PLC. | www.rhbgroup.com |
| | កាណា ស៊ីឃ្យូរីធី អិលធីឌី<br>Cana Securities Ltd. | www.canasecurities.com.kh |
| | កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី<br>Campu Securities Plc. | www.campusecurities.com.kh |
| | យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី<br>Yuanta Securities (Cambodia) Plc. | www.yuantacambodia.com |
| | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី<br>SBI Royal Securities Plc. | www.sbiroyal.com |

### ២.៤.២. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ

តារាងទី២៖ បញ្ជីក្រុមហ៊ុនពាណិជ្ជករមូលបត្រ

| | | |
|---|---|---|
| | ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី<br>Golden Fortune (Cambodia) Securities Plc. | www.goldenfortune.com.kh |

### ២.៤.៣. ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ

តារាងទី៣៖ បញ្ជីក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ

| | | |
|---|---|---|
| | អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី<br>ACLEDA Securities Plc. | www.acledasecurities.com.kh |
| | ខេប ស៊ីឃ្យូរីធី លីមីធីត<br>CAB Securities Limites. | www.cab.com.kh |
| | ខេមបូឌា - វៀតណាម ស៊ីឃ្យូរីធី ភីអិលស៊ី<br>Cambodia-Vietnam Securities Plc. | www.cvs.com.kh |

## ២.៥. អ្នកចូលរួមរបស់ ផ.ម.ក.

### ២.៥.១. ភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ

តារាងទី៤៖ បញ្ជីភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ

| | | |
|---|---|---|
| | អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី<br>ACLEDA Securities Plc. | www.acledasecurities.com.kh |
| | ធនាគារវិនិយោគ និង<br>អភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី<br>Bank for Investment and Development<br>of Cambodia | www.bidc.com.kh |
| | ធនាគារកាណាឌីយ៉ា<br>Canadia Bank Plc. | www.canadiabank.com.kh |

### ២.៥.២. ភ្នាក់ងារបញ្ជិកាមូលបត្រ និងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ

តារាងទី៥៖ បញ្ជីភ្នាក់ងារបញ្ជិកាមូលបត្រ និងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ

| | | |
|---|---|---|
| | ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>Acleda Bank Plc. | www.acledabank.com.kh |
| | ត្រាយខ័រ ស៊ីឃ្យូរីធី សឺវីស ភីអិលស៊ី<br>Tricor Securities Services Plc. | www.tricorcambodia.com |
| | ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី<br>Phnom Penh Securities Plc. | www.pps.com.kh |

## ២.៦. ព័ត៌មានអំពី ផ.ម.ក.

អាសយដ្ឋាន ៖ អគារ ផ.ម.ក. វិថីព្រះមហាក្សត្រីយានី កុសុមៈ (ផ្លូវ ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា[16]

ទូរស័ព្ទ ៖ ០២៣ ៩៥៨ ៨៨៨

ទូរសារ ៖ ០២៣ ៩៥៥ ៥៥៨

គេហទំព័រ ៖ www.csx.com.kh

ហ្វេសបុក ៖ https://www.facebook.com/cambodia.csx/

ក្រសួង និងស្ថាប័នពាក់ព័ន្ធ ៖ info@csx.com.kh

[16] www.csx.com.kh

# ជំពូកទី ៣
# ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

## ៣.១. ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.

### ៣.១.១. លក្ខខណ្ឌចម្បងនៃការចុះបញ្ជីនៃមូលបត្រកម្មសិទ្ធិ

#### ៣.១.១.១. លក្ខខណ្ឌតម្រូវជាតួលេខ

- **ទីផ្សារគោល (Main Board)**

[17]ផ្សារមូលបត្រកម្ពុជា(ផ.ម.ក.) ជាប្រតិបត្តិករទីផ្សារតែមួយគត់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមាននាទីចម្បងក្នុងការធានាតម្លាភាព និងបង្កើតបរិយាកាសការងារដែលមានភាពល្អប្រសើរ ដល់អ្នកចូលរួមក្នុងទីផ្សារ ជាពិសេសក្រុមហ៊ុនក្នុងស្រុក ដែលត្រូវការមូលធនដើម្បីពង្រីកអាជីវកម្ម ព្រមជាមួយនឹងការការពារផលប្រយោជន៍របស់វិនិយោគិនជាតិ និងអន្តរជាតិផងដែរ។ ក្នុងនោះផងដែរ ទីផ្សារគោល គឺជាផ្សារដំបូងបង្អស់ត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការសម្រាប់ការចុះបញ្ជីរបស់ក្រុមហ៊ុនចុះបញ្ជីសក្តានុពលដែលមានស្តង់ដារ និងទំហំធំ។ ទីផ្សារនេះនឹងអនុញ្ញាតឲ្យក្រុមហ៊ុននាំយកភាគហ៊ុនទាំងអស់ក្រោយការបោះផ្សាយមកចុះបញ្ជី និងជួញដូរនៅក្នុងប្រព័ន្ធរបស់ ផ.ម.ក. ។

តារាងទី៦៖ លក្ខខណ្ឌតម្រូវជាតួលេខសម្រាប់ទីផ្សារគោល

| | |
|---|---|
| មូលធនភាគហ៊ុនិក | ≥ ៣០ពាន់លានរៀល (៧,៥លានដុល្លារ) |
| ប្រាក់ចំណេញសុទ្ធ | ≥ ២ពាន់លានរៀល (៥០០.០០០ដុល្លារ) នៃឆ្នាំសារពើពន្ធចុងក្រោយ និង<br>≥ ៣ពាន់លានរៀល (៧៥០.០០០ដុល្លារ) នៃប្រាក់ចំណេញសរុបសម្រាប់ រយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ |
| ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% | ≥២០០នាក់ និង<br>≥ ៧% នៃភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប |
| របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម | ២ឆ្នាំ |

ប្រភព៖ http://www.csx.com.kh/kh/product/mainboard.jsp?MNCD=30102

[17] http://www.csx.com.kh/kh/product/mainboard.jsp?MNCD=30102ទីផ្សារគោល

- [18]ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិចចំនួន ៣០.០០០.០០០.០០០ (សាមសិបពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។
- ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងប្រាក់ចំណេញសរុបចំនួន ៣.០០០.០០០.០០០ (បីពាន់លាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។
- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ២០០ (ពីររយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយ ផ.ម.ក.។
- ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ៧ (ប្រាំពីរ) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងៗពីនេះដោយ ផ.ម.ក. ។

- **ទីផ្សារកំណើន (Growth Board)**

[19]ផ្អែកតាមអង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ ២០១៤ (CIES 2014) របស់ក្រសួងផែនការ ចំនួនសហគ្រាសអាជីវកម្មសរុបនៅប្រទេសកម្ពុជា គិតត្រឹមខែមីនា ឆ្នាំ២០១៤ មានប្រមាណ ៥១៣.៧៥៩ ដែលក្នុងនោះប្រហែល ៩៧% គឺជាសហគ្រាសខ្នាតតូច (មានបុគ្គលិកក្រោម ១០នាក់) ហើយមួយភាគបីនៃសហគ្រាសទាំងអស់មានអាយុកាលតិចជាង៣ឆ្នាំ។ ទីផ្សារថ្មីសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានផ្តួចផ្តើមឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបន្ថែមនូវជម្រើសហិរញ្ញប្បទានមួយទៀត សម្រាប់ក្រុមហ៊ុនអាជីវកម្មទាំងនោះ ដែលមានផលរបរសរុបប្រចាំឆ្នាំលើសពី ១០ពាន់លានដុល្លារអាមេរិក និងបង្កើតការងារចំនួន ១,៣ លានផងដែរ។ ដោយពិនិត្យឃើញអំពីសក្តានុពលនៃកំណើនរបស់សហគ្រាសទាំងនេះ យើងបានឲ្យឈ្មោះទីផ្សារថ្មីថា "ទីផ្សារកំណើន"។

[18] ឧបសម្ព័ន្ធប្រកាសលេខ ០០៩/១៨ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ស្តីពី "ការកែប្រែវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា", ទំព័រទី ១

[19] http://www.csx.com.kh/kh/product/growthboard.jsp?MNCD=30103ទីផ្សារកំណើន

តារាងទី៧៖ លក្ខខណ្ឌតម្រូវជាតួលេខសម្រាប់ទីផ្សារកំណើន

| | |
|---|---|
| មូលធនភាគហ៊ុនិក | ≥ ២ពាន់លានរៀល (៥០០.០០០ដុល្លារ) |
| ប្រាក់ចំណេញសុទ្ធ | - ត្រូវមានប្រាក់ចំណេញសុទ្ធនៃឆ្នាំសារពើពន្ធចុងក្រោយ ឬ<br>- ត្រូវមានលំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន និងត្រូវមានអត្រាប្រាក់ចំណេញដុល ≥ ១០% |
| ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% | ≥ ១០០នាក់ និង<br>≥ ១០% នៃភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប |
| របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម | ១ឆ្នាំ |

ប្រភព៖ http://www.csx.com.kh/kh/product/growthboard.jsp?MNCD=30103

- [20]ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ជ.ម.ក.។
- ត្រូវបំពេញលក្ខខណ្ឌប្រាក់ចំណេញណាមួយដូចខាងក្រោម៖
  - ✓ ត្រូវមានប្រាក់ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ ឬ
  - ✓ ត្រូវមានលំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន (Positive Operating Cash Flow) និងត្រូវមានអត្រាប្រាក់ចំណេញដុលយ៉ាងហោចណាស់ ១០ (ដប់) ភាគរយ។
- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ១០០ (មួយរយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ ។
- ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ១០ (ដប់) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។

[20] ឧបសម្ព័ន្ធប្រកាសលេខ ០០៩/១៨ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ស្តីពី "ការកែប្រែវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា", ទំព័រទី ១, ២

#### ៣.១.១.២. លក្ខខណ្ឌមិនមែនជាតួលេខ

តារាងទី៨៖ លក្ខខណ្ឌមិនមែនជាតួលេខសម្រាប់ក្រុមហ៊ុនចុះបញ្ជី

| | |
|---|---|
| ការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនជាងគេ | មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនជាងគេក្នុងរយៈពេល ១ឆ្នាំ រហូតដល់កាលបរិច្ឆេទចុះបញ្ជីជាផ្លូវការ។ |
| ការរក្សាទុកមូលបត្រ | មូលបត្រទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើនៅប្រតិបត្តិ-កររក្សាទុកមូលបត្រនៃផ្សារមូលបត្រកម្ពុជា |
| ឡុកអាប់ភាគហ៊ុន | • ១ឆ្នាំសម្រាប់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (អនុញ្ញាតឲ្យលក់ភាគហ៊ុនក្នុងកម្រិតអតិ-បរមា ៥០% សម្រាប់រយៈពេល៦ខែចុងក្រោយ)<br>• ៦ខែ សម្រាប់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១៥% និងភាគហ៊ុនិកយុទ្ធសាស្ត្រ |

ប្រភព៖ http://www.csx.com.kh/kh/product/mainboard.jsp?MNCD=30102

**ឡុកអាប់ភាគហ៊ុន** សំដៅដល់ការបង្ខាំងមិនឲ្យភាគហ៊ុនិកកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ លក់ ឬផ្ទេរមូលបត្រកម្មសិទ្ធិដែលកាន់កាប់យ៉ាងហោចណាស់សម្រាប់រយៈពេល ១ឆ្នាំ និងបង្ខាំងភាគហ៊ុនិកដែលកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតចាប់ពី ១៥% ឡើងទៅ មិនឲ្យលក់ ឬផ្ទេរមូលបត្រកម្មសិទ្ធិដែលកាន់កាប់យ៉ាងហោចណាស់សម្រាប់រយៈពេល ០៦ខែ បន្ទាប់ពីចុះបញ្ជីលក់មូលបត្រដំបូង។

#### ៣.១.១.៣. អភិបាលកិច្ចសាជីវកម្ម

- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត
  - សមាជិកក្រុមប្រឹក្សាភិបាល ពី ៥ -១៥នាក់
  - អភិបាលឯករាជ្យ ≥ ១/៥ នៃអភិបាលសរុប
  - ប្រសិនបើអភិបាលឯករាជ្យជាជនបរទេស ≥៦ខែនៃបទពិសោធន៍ការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- សហគ្រាសសាធារណៈ:
  - សមាជិកក្រុមប្រឹក្សាភិបាល ≤ ៧នាក់
  - អភិបាលឯករាជ្យ ≥ ១នាក់
  - អភិបាលមិនប្រតិបត្តិ (តំណាងឲ្យភាគហ៊ុនិកឯកជន) ≥១នាក់
- គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល
  - គណៈកម្មាធិការសវនកម្ម
  - គណៈកម្មាធិការគ្រប់គ្រងហានិភ័យសម្រាប់ ទ្រព្យសកម្ម ≥២០០ពាន់លានរៀល (៥០លានដុល្លារ)
  - គណៈកម្មាធិការតែងតាំងក្រុមប្រឹក្សាភិបាល អាចពិចារណាបង្កើតគណៈកម្មាធិការតែងតាំង និងគណៈកម្មាធិការដទៃទៀត ប្រសិនបើចាំបាច់ និងតាមការស្នើសុំរបស់ គ.ម.ក.។

### ៣.១.២. ដំណើរការនៃការចុះបញ្ជី

រូបភាពទី៧៖ ដំណើរការនៃការចុះបញ្ជី




ប្រភព៖ http://www.csx.com.kh/kh/product/mainboard.jsp?MNCD=30102

### ៣.១.២.១. ដំណាក់កាលរៀបចំរបស់ក្រុមហ៊ុន

➤ [21]ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ
បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈអាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូន គ.ម.ក. ដែលលិខិតមានខ្លឹមសារ ០៣ ចំណុចដូចខាងក្រោម៖

- គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Purpose of IPO)
- គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Expected Timetable)
- ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងដែលរំពឹងទុក (Expected IPO Team) រួមមាន៖
  - **ក្រុមហ៊ុនធានាទិញមូលបត្រ**
    ក្រុមហ៊ុនដែលមានបំណងចុះបញ្ជី អាចចាប់ផ្តើមដំណើរការរៀបចំចុះបញ្ជីដោយតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ។ ក្រុមហ៊ុនចុះបញ្ជីត្រូវជ្រើសរើសក្រុមហ៊ុនណាមួយក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក. ដែលជាសមាជិកនៃ ផ.ម.ក.។ ក្រុមហ៊ុនធានាទិញមូលបត្រ គឺដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយក្រុមហ៊ុនឲ្យសម្រេចបានការចុះបញ្ជីនៅលើទីផ្សារ។ ក្រៅពីនេះ ក្រុមហ៊ុនធានាទិញមូលបត្រថែមទាំងជួយសម្រួល និងសហការជាមួយសមាជិកក្រុមការងារបោះផ្សាយលក់មូលបត្រផ្សេងទៀត ក្នុងការរៀបចំឯកសារពាក់ព័ន្ធ និងត្រួតពិនិត្យដំណើរការចុះបញ្ជីទាំងស្រុង រួមទាំងដំណាក់កាលនៃការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ផងដែរ។
  - **ក្រុមមេធាវី ឬមេធាវី**
    ជាផ្នែកមួយដ៏សំខាន់នៃដំណើរការចុះបញ្ជី ក្នុងការផ្តល់ប្រឹក្សាយោបល់លើបញ្ហាផ្លូវច្បាប់ទាំងអស់ ដែលទាក់ទងនឹងពាក់ស្នើសុំ និងឯកសារផ្តល់

[21] ឧបសម្ព័ន្ធប្រកាសលេខ ០០១គ.ម.ក/គ.ណ.ន ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ ស្តីពី "យន្តការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង"

ព័ត៌មាន។ ក្រុមការងារនេះនឹងធ្វើការពិនិត្យលើការបំពេញកាតព្វកិច្ចតាមច្បាប់របស់ក្រុមហ៊ុនដែលមានបំណងចង់ចុះបញ្ជី និងធ្វើការផ្ទៀងផ្ទាត់ឯកសារផ្សេងៗឲ្យបានត្រឹមត្រូវតាមការតម្រូវរបស់ច្បាប់។ ក្រុមហ៊ុនដែលមានបំណងចង់ចុះបញ្ជី ត្រូវជ្រើសរើសក្រុមហ៊ុនមេធាវី ដែលមានការទទួលស្គាល់ដោយ គ.ម.ក. ដើម្បីបំពេញតួនាទីនេះ។

- **ក្រុមហ៊ុនគណនេយ្យជំនាញ**

  ក្រុមហ៊ុនគណនេយ្យជំនាញ ជួយក្រុមហ៊ុនចុះបញ្ជីក្នុងការរៀបចំរបាយ-ការណ៍ហិរញ្ញវត្ថុ និងព័ត៌មានតាមលក្ខខណ្ឌតម្រូវក្នុងឯកសារផ្តល់ព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ។ ដូចគ្នានឹងអ្នកជំនាញប្រឹក្សាផ្សេងទៀតដែរ ក្រុមហ៊ុនចុះបញ្ជីត្រូវជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ ដែលមានការទទួលស្គាល់ដោយ គ.ម.ក.។

- **ក្រុមហ៊ុនវាយតម្លៃ**

  ក្រុមហ៊ុនចុះបញ្ជីចាំបាច់ត្រូវជ្រើសរើសក្រុមហ៊ុនវាយតម្លៃ ឬបុគ្គលវាយតម្លៃឯករាជ្យ ប្រសិនបើក្រុមហ៊ុនកាន់កាប់ទ្រព្យសម្បត្តិ ដីធ្លី ឬបរិក្ខារដែលត្រូវវាយតម្លៃឡើងវិញ។ ក្រុមហ៊ុនវាយតម្លៃត្រូវរៀបចំរបាយការណ៍វាយតម្លៃដែលជាផ្នែកមួយនៃដំណើរការចុះបញ្ជី។ ក្រុមហ៊ុនដែលមានបំណងចុះបញ្ជីត្រូវជ្រើសរើសក្រុមហ៊ុនវាយតម្លៃមួយក្នុងចំណោមក្រុមហ៊ុន ដែលមានការទទួលស្គាល់ដោយ គ.ម.ក. ។

➢ ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះ-ផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រ ក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រដែលទទួលអាជ្ញាបណ្ណពីគ.ម.ក.។

➢ ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO Team)

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការតែងតាំងបុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលមានការទទួលស្គាល់ដោយ គ.ម.ក. ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារៈ-ណៈស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយ ត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជា សាធារណៈលើកដំបូង។

➢ ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence)

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធា- រណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលដឹកនាំដោយក្រុមហ៊ុនធានាទិញ មូលបត្រ។

### ៣.១.២.២. ពិនិត្យលទ្ធភាពអាចចុះបញ្ជី

➢ ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

➢ ការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

### ៣.១.២.៣. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

- ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍ លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក.

  ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូល-បត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមកាន់ គ.ម.ក.។ គ.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មាន មុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈជូនក្រុមហ៊ុនបោះផ្សាយ។

- ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង (Book Building)

  ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍ លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក. ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺ ការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

- ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

  ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាត្រូវបញ្ជាក់ថា ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបត្របានដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូល-បត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិ-ការ។

- ការស្នើសុំអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ (Term of Offer) និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក.

  ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូន គ.ម.ក. ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

- ការធ្វើបរិវិសកម្មមូលបត្រ (Subscription)

  ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក. ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ៣ និងជំពូកទី ៤ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

- ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ

  ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះភ្លាមជូន គ.ម.ក.។

### ៣.១.២.៤. ការចុះបញ្ជីជាផ្លូវការនៅ ផ.ម.ក.

- ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

  ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិ ទៅឲ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជាផ្លូវការដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ៣.១.៣. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

### ៣.១.៣.១.ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជី

- ថ្លៃសេវាលើការពិនិត្យលទ្ធភាពអាចចុះបញ្ជីសម្រាប់ទីផ្សារគោល ចំនួន ៤.០០០.០០០ រៀល
- ថ្លៃសេវាលើការពិនិត្យលទ្ធភាពអាចចុះបញ្ជីសម្រាប់ទីផ្សារកំណើន ចំនួន ២.០០០.០០០ រៀល

### ៣.១.៣.២. ថ្លៃសេវាសម្រាប់ការចុះបញ្ជី

តារាងទី៩៖ ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

| មូលធនូបនីយកម្មទីផ្សារសរុប | ថ្លៃសេវា |
|---|---|
| ពី ០ ៛ ដល់ ១២.០០០.០០០.០០០ ៛ | ១០.០០០.០០០ ៛ |
| ពី ១២.០០០.០០០.០០១ ៛ ដល់ ៤០.០០០.០០០.០០០ ៛ | ០,០៣០% |
| ពី ៤០.០០០.០០០.០០១ ៛ ដល់ ២០០.០០០.០០០.០០០ ៛ | ០,០២៥% |
| ពី ២០០.០០០.០០០.០០១ ៛ ដល់ ៤០០.០០០.០០០.០០០ ៛ | ០,០១៥% |
| លើសពី ៤០០.០០០.០០០.០០០ ៛ | ០,០១០% |

ប្រភព៖ http://www.csx.com.kh/kh/product/mainboard.jsp?MNCD=30102

### ៣.១.៣.៣. ថ្លៃសេវាចុះបញ្ជីប្រចាំឆ្នាំ

តារាងទី១០៖ ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ

| មូលធនូបនីយកម្មទីផ្សារសរុប | ថ្លៃសេវា |
|---|---|
| ពី ០ ៛ ដល់ ១២.០០០.០០០.០០០ ៛ | ៣.០០០.០០០ ៛ |
| ពី ១២.០០០.០០០.០០១ ៛ ដល់ ៤០.០០០.០០០.០០០ ៛ | ០,០២០% |
| ពី ៤០.០០០.០០០.០០១ ៛ ដល់ ២០០.០០០.០០០.០០០ ៛ | ០,០១៥% |
| លើសពី ២០០.០០០.០០០.០០០ ៛ | ០,០០៥% |

ប្រភព៖ http://www.csx.com.kh/kh/product/mainboard.jsp?MNCD=30102

#### ៣.១.៣.៤. ថ្លៃសេវាផ្សេងៗ

- កម្រៃសេវាធានាទិញមូលបត្រ
- កម្រៃសេវាសវនកម្ម
- កម្រៃសេវាវាយតម្លៃទ្រព្យសកម្ម
- កម្រៃសេវាផ្នែកច្បាប់
- ផ្សេងៗ

## ៣.២. ការផ្តល់ព័ត៌មានបន្ទាប់ពីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.

### ៣.២.១. ព័ត៌មានទាន់ពេល

ព័ត៌មានទាន់ពេល សំដៅដល់ព័ត៌មានទាំងឡាយណាដែលអាចមានផលប៉ះពាល់ដល់ថ្លៃ ឬការជួញដូរមូលបត្ររបស់បុគ្គលបោះផ្សាយ ហើយនៅពេលដែលព័ត៌មានទាំងនោះកើតមានឡើង បុគ្គលបោះផ្សាយត្រូវធ្វើការបង្ហាញព័ត៌មានទាំងនោះភ្លាម។

បុគ្គលដែលចុះបញ្ជី ត្រូវបង្ហាញព័ត៌មានទាន់ពេលនៅពេលៈ

- បុគ្គលបោះផ្សាយត្រូវផ្តល់ព័ត៌មានជូន គ.ម.ក. ភ្លាម ប្រសិនបើមានព្រឹត្តិការណ៍ណាមួយដូចដែលបានចែងក្នុងមាត្រា៥ នៃប្រកាសស្តីពី ការបង្ហាញព័ត៌មានសាជីវកម្មបានកើតឡើងក្នុងរយៈពេល ១ (មួយ) ម៉ោងមុន ឬក្នុងកំឡុងពេលជួញដូរ។
- ក្នុងករណីព្រឹត្តិការណ៍កើតឡើងក្រៅពីម៉ោងជួញដូរ ប៉ុន្តែក្នុងម៉ោងធ្វើការ បុគ្គលបោះផ្សាយត្រូវផ្តល់ព័ត៌មានក្នុងម៉ោងធ្វើការនៃថ្ងៃដែលព្រឹត្តិការណ៍កើតមានឡើង។
- ក្នុងករណីមានព្រឹត្តិការណ៍ផ្សេងទៀត បុគ្គលបោះផ្សាយត្រូវផ្តល់ព័ត៌មានក្នុងអំឡុងពេលយ៉ាងតិច១ម៉ោង មុនម៉ោងជួញដូរនៃថ្ងៃអាជីវកម្មបន្ទាប់។

### ៣.២.២. របាយការណ៍សមាជិក

សំដៅដល់របាយការណ៍ដែលត្រូវបានរៀបចំសម្រាប់រយៈពេលនៃការរាយការណ៍ជាក់លាក់ណាមួយរួមមាន របាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

បុគ្គលបោះផ្សាយត្រូវបញ្ជូនរបាយការណ៍ទៅ គ.ម.ក. ដូចខាងក្រោម៖

- របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់អោយក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធ។
- របាយការណ៍ប្រចាំត្រីមាស ត្រូវផ្តល់អោយក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីបញ្ចប់ត្រីមាសនៃឆ្នាំសារពើពន្ធ។

### ៣.២.៣. ព័ត៌មានពិសេស

សំដៅដល់ព័ត៌មានដូចជា ការទិញមកវិញ និងលុបចោលមូលបត្រកម្មសិទ្ធិ សំណើទិញផែនដ៏រ ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក និងការទទួលកាន់កាប់បន្ត។

មុនពេលព្រឹត្តិការណ៍កើតឡើង៖

- ការទិញមកវិញ និងការលុបចោលមូលបត្រកម្មសិទ្ធិ និងសំណើទិញផែនដ៏រ៖ បុគ្គលបោះផ្សាយត្រូវផ្តល់ព័ត៌មានជូន គ.ម.ក. ក្នុងអំឡុងពេល ៣ (បី) ថ្ងៃ បន្ទាប់ពីការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។
- ការទទួលកាន់កាប់បន្ត និងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក៖ បុគ្គលបោះផ្សាយត្រូវផ្តល់ព័ត៌មាន និងផ្តល់ឯកសារដែលជាប់ពាក់ព័ន្ធជូន គ.ម.ក. ភ្លាម បន្ទាប់ពីមានការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

ក្រោយពេលព្រឹត្តិការណ៍កើតឡើង៖

- បុគ្គលបោះផ្សាយត្រូវផ្តល់របាយការណ៍លទ្ធផលនៃការទិញមកវិញ និងការលុបចោលមូលបត្រកម្មសិទ្ធិ ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក និងការទទួលកាន់កាប់បន្ត ជូន គ.ម.ក. ក្នុងអំឡុងពេល ៣ (បី) ថ្ងៃ បន្ទាប់ពីបានបញ្ចប់ប្រតិបត្តិការណ៍ទាំងនោះ។
- ករណីប្រតិបត្តិការណ៍ប្រព្រឹត្តទៅមិនបានសម្រេច បុគ្គលបោះផ្សាយត្រូវផ្តល់ព័ត៌មានជូន គ.ម.ក. ភ្លាម។

### ៣.២.៤. ព័ត៌មានតាមការស្នើសុំ

សំដៅដល់ព័ត៌មានទាំងឡាយណាដែល គ.ម.ក. តម្រូវឲ្យបុគ្គលបោះផ្សាយធ្វើការបង្ហាញ។ បុគ្គលបោះផ្សាយត្រូវផ្តល់ព័ត៌មានភ្លាម នៅពេលដែលមានការស្នើសុំពីអគ្គនាយកនៃ គ.ម.ក.។

- **បុគ្គលបោះផ្សាយត្រូវបង្ហាញព័ត៌មាន និងគោរពតាមបែបបទដូចជា ៖**
  - ✓ បុគ្គលបោះផ្សាយត្រូវចាត់តាំងបុគ្គលិកយ៉ាងតិច ១ (មួយ) រូប ដើម្បីទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន។
  - ✓ ធ្វើចំណាត់ថ្នាក់ប្រភេទព័ត៌មាន "សម្រាប់ផ្សព្វផ្សាយជាសាធារណៈ" ឬ "មិនសម្រាប់ផ្សព្វផ្សាយជាសាធារណៈ" ។
  - ✓ ព័ត៌មានដែលត្រូវបង្ហាញ ត្រូវដាក់ជូនអគ្គនាយកនៃ គ.ម.ក. ដើម្បីពិនិត្យផ្ទៀងផ្ទាត់មុននឹងសម្រេចបញ្ជូនទៅទីផ្សារមូលបត្រប្រតិស្រុត ដើម្បីធ្វើការផ្សព្វផ្សាយភ្លាមដល់វិនិយោគិន និងសារធារណជន។
  - ✓ បុគ្គលបោះផ្សាយអាចបង្ហាញព័ត៌មានទៅទីផ្សារមូលបត្រប្រតិស្រុត និងសារធារណជន តាមរយៈគេហទំព័ររបស់បុគ្គលបោះផ្សាយ និង/ឬតាមរយៈសារព័ត៌មាននានា បន្ទាប់ពីទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.។

រូបភាពទី៨៖ ដ្យាក្រាមនៃការបង្ហាញព័ត៌មាន




ប្រភព៖ http://www.csx.com.kh/kh/product/disclosure.jsp?MNCD=30104

## ៣.៣. ព័ត៌មានក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.

### ៣.៣.១. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រទសភ)

- ឈ្មោះក្រុមហ៊ុន ៖ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- ឈ្មោះជាអក្សរកាត់ ៖ រទសភ (ជាភាសាអង់គ្លេសគឺ PWSA)
- ប្រភេទភាគហ៊ុនចុះបញ្ជី ៖ ភាគហ៊ុនធម្មតា
- ចំនួនភាគហ៊ុនចុះបញ្ជី ៖ ៨៦,៩៧៣,១៦២
- កាលបរិច្ឆេទចុះបញ្ជី ៖ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២
- ព័ត៌មានក្រុមហ៊ុន ៖ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) ត្រូវបានបង្កើតឡើងជាគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ស្ថិតក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ រ.ទ.ស.ភ បានចុះបញ្ជីជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដោយបានបោះផ្សាយលក់មូលបត្រជាសាធារណៈចំនួន ១៣.០៤៥.៩៧៥ភាគហ៊ុន ដែលស្មើនឹង ១៥% នៃចំនួនភាគហ៊ុនធម្មតាសរុប ។ បេសកកម្មរបស់ រ.ទ.ស.ភ គឺធានាផ្គត់ផ្គង់ទឹកស្អាតគ្មានមេរោគ ២៤ ម៉ោងក្នុងមួយថ្ងៃ ៧ ថ្ងៃក្នុងមួយសប្តាហ៍ មានសម្ពាធគ្រប់គ្រាន់ និងក្នុងតម្លៃមួយសមស្របជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្តាលដែលជាប់នឹងរាជធានីភ្នំពេញ ដោយមិនមើលរំលងប្រជាពលរដ្ឋក្រីក្រ។ ក្រៅពីនេះ រ.ទ.ស.ភ បាននឹងកំពុងចែករំលែកពិសោធន៍ការងាររបស់ខ្លួនដល់បណ្តារដ្ឋាករទឹក ខេត្ត-ក្រុងមួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបណ្តាអង្គភាពទឹកស្អាតក្នុងតំបន់ និងក្នុងពិភពលោកបានសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក៏ដូចជាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ពិភពលោក។

### ៣.៣.២. ក្រុមហ៊ុន ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលសុី (ហាធអ)

- ឈ្មោះក្រុមហ៊ុន ៖ ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលសុី
- ឈ្មោះជាអក្សរកាត់ ៖ ហាធអ (ជាភាសាអង់គ្លេសគឺ GTI)
- ប្រភេទភាគហ៊ុនចុះបញ្ជី ៖ ភាគហ៊ុនធម្មតា
- ចំនួនភាគហ៊ុនចុះបញ្ជី ៖ ៤០,០០០,០០០
- កាលបរិច្ឆេទចុះបញ្ជី ៖ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤

- ព័ត៌មានក្រុមហ៊ុន ៖ ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ីនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី គឺជាក្រុមហ៊ុនផលិតសម្លៀកបំពាក់ ដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៧។ ក្រុមហ៊ុន ហ្គ្រេនធ្វីន គឺជារោងចក្រម៉ៅការបន្ត និងជារោងចក្រផលិតសម្លៀកបំពាក់ផ្ទាល់សម្រាប់នាំចេញ។ សព្វថ្ងៃ ផលិតផលរបស់ក្រុមហ៊ុន ហ្គ្រេនធ្វីនរួមមាន ម៉ាកសម្លៀកបំពាក់កីឡាល្បីៗដូចជា ម៉ាក Adidas, Reebok, Taylor Made, Salomon, New Balance (NB), Kohl's, Nautica, North Face, Russell Athletic។ល។ គោលដៅនាំចេញរបស់ក្រុមហ៊ុន ហ្គ្រេនធ្វីនមានដូចជា បណ្តាប្រទេសក្នុងតំបន់អឺរ៉ុប (៤៩%នៃប្រាក់ចំណូលសរុបក្នុងឆ្នាំ២០១៦) សហរដ្ឋអាមេរិក (២៣%នៃប្រាក់ចំណូល សរុបក្នុងឆ្នាំ២០១៦) តំបន់អាស៊ី និងបណ្តាប្រទេសដទៃទៀត (២៨%នៃប្រាក់ចំណូលសរុបក្នុងឆ្នាំ២០១៦)។

**៣.៣.៣. កំពង់ផែស្វយ័តភ្នំពេញ** (**ក.ស.ភ**)

- ឈ្មោះក្រុមហ៊ុន ៖ កំពង់ផែស្វយ័តភ្នំពេញ
- ឈ្មោះជាអក្សរកាត់ ៖ ក.ស.ភ (ជាភាសាអង់គ្លេសគឺ PPAP)
- ប្រភេទភាគហ៊ុនចុះបញ្ជី ៖ ភាគហ៊ុនមានសិទ្ធិបោះឆ្នោត
- ចំនួនភាគហ៊ុនចុះបញ្ជី ៖ ២០,៦៨៤,៣៦៥
- កាលបរិច្ឆេទចុះបញ្ជី ៖ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥
- ព័ត៌មានក្រុមហ៊ុន ៖ កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) គឺប្រតិបត្តិករមួយក្នុងចំណោមប្រតិបត្តិករកំពង់ផែកុងតឺន័រអន្តរជាតិពីរនៅកម្ពុជា ហើយក៏ជាប្រតិបត្តិករកំពង់ផែទន្លេធំជាងគេបំផុត និងជាអាជ្ញាធរគ្រប់គ្រងផែនៅក្នុងមណ្ឌលអាជីវកម្មផែ ។ មណ្ឌលអាជីវ-កម្មផែមានប្រវែង ១៦០គីឡូម៉ែត្រ លាតសន្ធឹងពីខេត្តត្បូងឃ្មុំទៅដល់ព្រំប្រទល់កម្ពុជា-វៀតណាម នៅឯក្អមសំណ។ នៅឆ្នាំ២០១៥ ក.ស.ភ. ទទួលបានសិទ្ធផ្តាច់មុខជាប្រតិបត្តិករកំពង់ផែនៅក្នុងមណ្ឌលអាជីវកម្មផែ។ ក.ស.ភ. មានចំណតផែចម្បងៗចំនួន ៤ គឺ៖ ទី១: ចំណតផែកុងតឺន័រ LM១៧, ទី២: ចំណតផែពហុបំណង TS៣, ទី៣: ចំណតផែអ្នកដំណើរ និងទេសចរណ៍ TS១, ទី៤: ចំណតផែទន្លេបិទ UM២។

**៣.៣.៤. ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ( ភីភីអេសភី )**

- ឈ្មោះក្រុមហ៊ុន ៖ ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី
- ឈ្មោះជាអក្សរកាត់ ៖ ភីភីអេសភី (ជាភាសាអង់គ្លេសគឺ PPSP)
- ប្រភេទភាគហ៊ុនចុះបញ្ជី ៖ ភាគហ៊ុនមានសិទ្ធិបោះឆ្នោត
- ចំនួនភាគហ៊ុនចុះបញ្ជី ៖ ៧១,៨៧៥,០០០
- កាលបរិច្ឆេទចុះបញ្ជី ៖ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ (ដំបូង) និង
  ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ (បន្ថែម)
- ព័ត៌មានក្រុមហ៊ុន ៖ ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី គឺជាអ្នកអភិវឌ្ឍ និងជាប្រតិបត្តិករនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (PPSEZ) និងប៉ោយប៉ែត ភីភី-អេសអ៊ីហ្សិត (Poipet PPSEZ)។ នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ក្រុមហ៊ុនទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីក្លាយខ្លួនជាអ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសដែលអាចធ្វើប្រតិបត្តិការអាជីវកម្មច្រើនប្រភេទ ហើយបច្ចុប្បន្ននេះ ភីភីអេសភី ជាតំបន់សេដ្ឋកិច្ចពិសេស ដែលកំពុងធ្វើប្រតិបត្តិការនៅជិតទីប្រជុំជននៃរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលមានអាជីវកម្មចម្បងក្នុងការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់ និង/ឬ ជួល។ ក្រុមហ៊ុនក៏មានផ្តត់ផ្គង់សេវាកម្មដែលពាក់ព័ន្ធព្រមជាមួយបរិក្ខារចាំបាច់នានា នៅក្នុងបរិវេណ PPSEZ ដែលរួមមាន ប្រព្រឹត្តកម្មទឹកសំណល់ ការផ្គត់ផ្គង់ និងចែកចាយទឹកស្អាត សេវាជួល ការថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សេវាផ្តល់ប្រឹក្សាយោបល់ និងជំនួយកិច្ចការរដ្ឋបាល សេវាសន្តិសុខ ការផលិត និងចែកចាយថាមពលអគ្គីសនី ព្រមទាំងសេវាផែស្ងួតជូនដល់អ្នកដែលបានជួលក្នុង PPSEZ។ ក្រុមហ៊ុនរក្សាបាននូវចំនួនវិនិយោគិនតំបន់ច្រើនជាងគេក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសទាំង ៣៨ ជាមួយនឹងផ្ទៃដីរបស់ PPSEZ ដែលមានប្រមាណ ៣៥៧.៣២ហិចតា។

**៣.៣.៥. កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស)**

- ឈ្មោះក្រុមហ៊ុន ៖ កំពង់ផែស្វយ័តក្រុងព្រះសីហនុ
- ឈ្មោះជាអក្សរកាត់ ៖ ក.ស.ស (ជាភាសាអង់គ្លេសគឺ PAS)
- ប្រភេទភាគហ៊ុនចុះបញ្ជី ៖ ភាគហ៊ុនមានសិទ្ធិបោះឆ្នោត
- ចំនួនភាគហ៊ុនចុះបញ្ជី ៖ ៨៥,៧៧១,៩៦៧
- កាលបរិច្ឆេទចុះបញ្ជី ៖ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧
- ព័ត៌មានក្រុមហ៊ុន ៖ ក.ស.ស ជាក្រុមហ៊ុនរដ្ឋ ដែលបានបង្កើតឡើងដើម្បីធ្វើអាជីវកម្មសេវាកម្មមូលដ្ឋានលើការងារៈ កណ្ណធារកិច្ច នាំនាវាចេញ-ចូល និងផ្តល់ព័ស្តុភារដល់នាវា, លើកដាក់ ផ្ទេរ ផ្ទុកទំនិញ, ស្តុកទំនិញនៅឃ្លាំង និងទីលាន ព្រមទាំងដឹកជញ្ជូនទំនិញ។ បច្ចុប្បន្ន ក.ស.ស ក៏កំពុងផ្តល់សេវាកម្មផ្សេងទៀតដូចជា សេវាក្នុងតំបន់សេដ្ឋកិច្ចពិសេសដូចជាជួលឃ្លាំងនិងថែរក្សាទំនិញ លើកដាក់ និងដឹកជញ្ជូនទំនិញ រួមទាំងសេវាសន្តិសុខក្នុងកំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេស។ ក.ស.ស ជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់នៅកម្ពុជា ដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីទំហំប្រមាណ ១២៥ហិចតា នៅខេត្តព្រះសីហនុ ហើយត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះរួមមាន បណ្តាញផ្លូវគោក (ផ្លូវជាតិលេខ ៣ និងលេខ ៤), បណ្តាញផ្លូវរថភ្លើង (តភ្ជាប់ទៅរាជធានីភ្នំពេញ និងខេត្តកំពត) និងបណ្តាញផ្លូវអាកាស (តភ្ជាប់ទៅខេត្តសៀមរាម និងរាជធានីភ្នំពេញ)។

## ៣.៤. ទិន្នន័យក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.

### ៣.៤.១. ការវិភាគទិន្នន័យនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (គិតជា រៀល)

តារាងទី១១៖ ការវិភាគទិន្នន័យនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (គិតជា រៀល)

| ក្រុមហ៊ុនបោះផ្សាយ | ចំនួនភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូង | តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង (រៀល) | ទឹកប្រាក់ដែលទទួលបានពីការបោះផ្សាយ (រៀល) |
|---|---|---|---|
| រទសភ ២០១២ | ១៣,០៤៥,៩៧៥ | ៦,៣០០ | ៨២,១៨៩,៦៤២,៥០០ |
| ហាធអ ២០១៤ | ៨,០០០,០០០ | ៩,៦៤០ | ៧៧,១២០,០០០,០០០ |
| ក.ស.ភ ២០១៥ | ៤,១៣៦,៨៧៣ | ៥,១២០ | ២១,១៨០,៧៨៩,៧៦០ |
| ភីភីអេសភី ២០១៦ | ១១,៥៧៥,០០០ | ២,៨៦០ | ៣៣,១០៤,៥០០,០០០ |
| ក.ស.ស ២០១៧ | ២១,៤៤២,៩៩២ | ៥,០៤០ | ១០៨,០៧២,៦៧៩,៦៨០ |
| សរុប | ៥៨,២០០,៨៤០ | - | ២១៣,៧៧៥,០០៤,៩៤០ |

ប្រភព៖ http://csx.com.kh/data/lstcom/listPosts.do?MNCD=50101

- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រទសភ) មានភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូងចំនួន ១៣,០៤៥,៩៧៥ភាគហ៊ុន បោះផ្សាយលក់ក្នុងតម្លៃ ៦,៣០០រៀល ហើយទឹកប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្ររបស់ក្រុមហ៊ុន រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានចំនួន ៨២,១៨៩,៦៤២,៥០០រៀល (គិតក្នុងឆ្នាំ ២០១២)។
- ក្រុមហ៊ុន ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (ហាធអ) មានភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូងចំនួន ៨,០០០,០០០ភាគហ៊ុន បោះផ្សាយលក់ក្នុងតម្លៃ ៩,៦៤០រៀល ហើយទឹកប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្ររបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ីមានចំនួន ៧៧,១២០,០០០,០០០ រៀល (គិតក្នុងឆ្នាំ ២០១៤)។

- កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) មានភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូង ចំនួន ៤,១៣៦,៨៧៣ភាគហ៊ុន បោះផ្សាយលក់ក្នុងតម្លៃ ៥,១២០រៀល ហើយទឹកប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្ររបស់កំពង់ផែស្វយ័តភ្នំពេញមានចំនួន ២១,១៨០,៧៨៩,៧៦០ រៀល (គិតក្នុងឆ្នាំ ២០១៥)។
- ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី) មានភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូងចំនួន ១១,៥៧៥,០០០ភាគហ៊ុន បោះផ្សាយលក់ក្នុងតម្លៃ ២,៨៦០រៀល ហើយទឹកប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្ររបស់ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី) មានចំនួន ៣៣,១០៤,៥០០,០០០ រៀល (គិតក្នុងឆ្នាំ ២០១៦)។
- កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) មានភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូងចំនួន ២១,៤៤២,៩៩២ភាគហ៊ុន បោះផ្សាយលក់ក្នុងតម្លៃ ៥,០៤០រៀល ហើយទឹកប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្ររបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ មានចំនួន ១០៨,០៧២,៦៧៩,៦៨០រៀល (គិតក្នុងឆ្នាំ ២០១៧)។

ដូចនេះ ភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូងនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានចំនួន **៥៨,២០០,៨៤០ភាគហ៊ុន** ហើយទឹកប្រាក់ដែលទទួលបានពីការបោះផ្សាយលក់ មូលបត្រសរុបមានចំនួន **២១៣,៧៧៥,០០៤,៩៤០រៀល**។

ក្រាហ្វិកទី១៖ ចំនួនភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូង



ក្រាហ្វិកទី២៖ ទឹកប្រាក់ដែលទទួលបានពីការបោះផ្សាយ (រៀល)




តាមរយៈក្រាហ្វិកទាំងពីរខាងលើ យើងឃើញថា កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) ទទួលបានទឹកប្រាក់ពីការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងច្រើនជាងគេនៅ ផ.ម.ក. គឺមានចំនួន ១០៨,០៧២,៦៧៩,៦៨០រៀល ដោយបានបោះផ្សាយលក់ភាគហ៊ុនចំនួន ២១,៤៤២,៩៩២ភាគហ៊ុន ក្នុងតម្លៃ ៥,០៤០រៀលក្នុង១ភាគហ៊ុន។ ចំណែកកំពង់ផែស្វយ័តក្រុងភ្នំពេញ (ក.ស.ភ) វិញ ទទួលបានទឹកប្រាក់ពីការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងតិចជាងគេនៅក្នុង ផ.ម.ក. គឺមានចំនួន ២១,១៨០,៧៨៩,៧៦០រៀល ដោយបានបោះ-ផ្សាយលក់ភាគហ៊ុនចំនួន ៤,១៣៦,៨៧៣ភាគហ៊ុន ក្នុងតម្លៃ ៥,១២០រៀលក្នុង១ភាគហ៊ុន។

### ៣.៤.២. ការវិភាគទិន្នន័យនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (គិតជា %)

តារាងទី១២៖ ការវិភាគទិន្នន័យនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (គិតជា %)

| ក្រុមហ៊ុនបោះផ្សាយ | ចំនួនភាគហ៊ុនចុះបញ្ជីសរុប | ចំនួនភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូង | ភាគរយនៃចំនួនភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូង |
|---|---|---|---|
| រទសភ ២០១២ | ៨៦,៩៧៣,១៦២ | ១៣,០៤៥,៩៧៥ | ១៥% |
| ហាធអ ២០១៤ | ៤០,០០០,០០០ | ៨,០០០,០០០ | ២០% |
| ក.ស.ភ ២០១៥ | ២០,៦៨៤,៣៦៥ | ៤,១៣៦,៨៧៣ | ២០% |
| ភីភីអេសភី ២០១៦ | ៧១,៨៧៥,០០០ | ១១,៥៧៥,០០០ | ១៦% |
| ក.ស.ស ២០១៧ | ៨៥,៧៧១,៩៦៧ | ២១,៤៤២,៩៩២ | ២៤% |
| សរុប | ៣០៥,៣០៤,៥០៣ | ៥៨,២០០,៨៤០ | - |

ប្រភព៖ http://csx.com.kh/data/lstcom/listPosts.do?MNCD=50101

- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រទសភ) មានភាគហ៊ុនចុះបញ្ជីសរុបចំនួន ៨៦,៩៧៣,១៦២ ភាគហ៊ុននៅ ផ.ម.ក. ដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងចំនួន ១៣,០៤៥,៩៧៥ភាគហ៊ុន គិតជាភាគរយស្មើនឹង ១៥% (គិតក្នុងឆ្នាំ ២០១២)។
- ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (ហាធអ) មានភាគហ៊ុនចុះបញ្ជីសរុបចំនួន ៤០,០០០,០០០ភាគហ៊ុន ដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងចំនួន ៨,០០០,០០០ភាគហ៊ុន គិតជាភាគរយស្មើនឹង ២០% (គិតក្នុងឆ្នាំ ២០១៤)។
- កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) មានភាគហ៊ុនចុះបញ្ជីសរុបចំនួន ២០,៦៨៤,៣៦៥ ភាគហ៊ុន ដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងចំនួន ៤,១៣៦,៨៧៣ ភាគហ៊ុន គិតជាភាគរយស្មើនឹង ២០% (គិតក្នុងឆ្នាំ ២០១៥)។

- ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី) មានភាគហ៊ុនចុះបញ្ជីសរុបចំនួន ៧១,៨៧៥,០០០ភាគហ៊ុន ដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ចំនួន ១១,៥៧៥,០០០ភាគហ៊ុន គិតជាភាគរយស្មើនឹង ១៦% (គិតក្នុងឆ្នាំ ២០១៦)។
- កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) មានភាគហ៊ុនចុះបញ្ជីសរុបនៅ ផ.ម.ក. ចំនួន ៨៥,៧៧១,៨៦៧ភាគហ៊ុន ដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ចំនួន ២១,៤៤២,៩៩២ភាគហ៊ុន គិតជាភាគរយស្មើនឹង ២៥% (គិតក្នុងឆ្នាំ ២០១៧)។

ដូចនេះ ភាគហ៊ុនដែលបានចុះបញ្ជីសរុបនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានចំនួន **៣០៥,៣០៤,៥០៣ភាគហ៊ុន** ហើយភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូងសរុបមាន ចំនួន **៥៨,២០០,៨៤០ភាគហ៊ុន**។

ក្រាហ្វិកទី៣៖ ប្រៀបធៀបចំនួនភាគហ៊ុននៅក្នុងក្រុមហ៊ុននីមួយៗ




ក្រាហ្វិកទី៤៖ ភាគរយនៃចំនួនភាគហ៊ុនបោះផ្សាយជាសាធារណៈលើកដំបូង



តាមក្រាហ្វិកទី៣ និងទី៤ បានបង្ហាញថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រទសភ) មានភាគហ៊ុនចុះបញ្ជីសរុបនៅ ផ.ម.ក. ច្រើនជាងគេចំនួន ៨៦,៩៧៣,១៦២ភាគហ៊ុន ប៉ុន្តែភាគហ៊ុនដែលបានបោះផ្សាយលក់ជាសាធារណៈមានចំនួនត្រឹមតែ ១៣,០៤៥,៩៧៥ភាគហ៊ុន ដែលស្មើនឹង ១៥% នៃភាគហ៊ុនចុះបញ្ជីសរុបនៅ ផ.ម.ក. ។ ចំណែកឯកំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) មានភាគហ៊ុនចុះបញ្ជីសរុបចំនួន ៨៥,៧៧១,៩៦៧ភាគហ៊ុន ដែលមានភាគហ៊ុនបោះ-ផ្សាយជាសាធារណៈលើកដំបូងច្រើនជាងគេនៅ ផ.ម.ក. គឺ ២១,៤៤២,៩៩២ភាគហ៊ុន ដែលស្មើនឹង ២៤% នៃភាគហ៊ុនចុះបញ្ជីសរុបនៅ ផ.ម.ក. ។ ផ្ទុយទៅវិញ កំពង់ផែស្វយ័តក្រុងភ្នំពេញ (ក.ស.ភ) មានចំនួនភាគហ៊ុនចុះបញ្ជីសរុបនៅ ផ.ម.ក. តិចជាងគេ គឺ ២០,៦៨៤,៣៦៥ភាគហ៊ុន ដែលភាគហ៊ុនបោះផ្សាយលក់ជាសាធារណៈមានចំនួន ៤,១៣៦,៨៧៣ភាគហ៊ុន ដែលស្មើនឹង ២០% នៃភាគហ៊ុនចុះបញ្ជីសរុបនៅផ.ម.ក. ។

## ៣.៥. អត្ថប្រយោជន៍នៃការចុះបញ្ជីនៅ ផ.ម.ក.

- [22]ដឹងពីតម្លៃនៃការវិនិយោគរបស់ក្រុមហ៊ុន

  នៅពេលចុះបញ្ជី ភាគហ៊ុនរបស់ក្រុមហ៊ុននឹងត្រូវដាក់ឲ្យជួញដូរលើទីផ្សារជាសាធារណៈ។ ដូចគ្នានឹងទីផ្សារដទៃទៀតដែរ ភាគហ៊ុននីមួយៗនឹងមានថ្លៃជាក់លាក់។ ដូច្នេះតាមរយៈការចុះបញ្ជី ក្រុមហ៊ុននឹងអាចដឹងពីតម្លៃភាគហ៊ុននៃក្រុមហ៊ុនរបស់ខ្លួន។ ស្របពេលជាមួយគ្នានេះដែរ ការជួញដូរភាគហ៊ុននៅទីផ្សារសាធារណៈនេះ ព្រមទាំងដឹងអំពីទំហំនៃការវិនិយោគរបស់ខ្លួន។

- ពង្រឹងទំនុកចិត្តលើសាជីវកម្ម

  ជាមួយនឹងលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន និងគោរពបទប្បញ្ញត្តិក្រោមបទដ្ឋានគតិ-យុត្តិ ហានិភ័យរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ជាទូទៅមានកម្រិតទាប បើធៀបនឹងក្រុមហ៊ុនឯកជន។ ឧទាហរណ៍ ក្រុមហ៊ុនចុះបញ្ជីនឹងមានភាពងាយស្រួលក្នុងការទាក់ទងជាមួយនឹងធនាគារដើម្បីទទួលបានកម្ចី ដោយសារធនាគារស្គាល់ក្រុមហ៊ុនចុះបញ្ជីជាងក្រុមហ៊ុនដែលមិនចុះបញ្ជីតាមរយៈឯកសារផ្តល់ព័ត៌មានអនុលោមទៅតាមច្បាប់ និងបទ-ប្បញ្ញត្តិក្នុងវិស័យមូលបត្រ។ កត្តានេះនឹងផ្តល់នូវឧត្តមភាពប្រកួតប្រជែងក្នុងការងារអាជីវ-កម្មរបស់ក្រុមហ៊ុន។

[22] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, "សៀវភៅមគ្គុទេសក៍សម្រាប់ការចុះបញ្ជី", ទំព័រទី២-៦

- ការលើកទឹកចិត្តបុគ្គលិក និងផលិតភាពការងារ

  ក្រុមហ៊ុនចុះបញ្ជី អាចបង្កើតផែនការលៃបម្រុងទុកភាគហ៊ុនសម្រាប់និយោជិករបស់ខ្លួន ដែលជាការលើកទឹកចិត្តដ៏មានប្រសិទ្ធិភាព ក្នុងការផ្សារភ្ជាប់អត្ថប្រយោជន៍របស់និយោជិក ទៅនឹងគោលដៅរបស់ក្រុមហ៊ុន។ ការធ្វើឲ្យប្រសើរឡើងនៃទំនាក់ទំនងរវាងថ្នាក់ដឹកនាំ និងនិយោជិកគ្រប់ជាន់ថ្នាក់ ព្រមទាំងភាពស្មោះត្រង់របស់និយោជិកអាចជួយពង្រឹងផលិតភាពរបស់ក្រុមហ៊ុនបាន។ គម្រោងផែនការនេះ ក៏អាចទាក់ទាញ និងរក្សាធនធានមនុស្ស ដែលមានសមត្ថភាពឲ្យបន្តបម្រើការងារនៅក្រុមហ៊ុនយូរអង្វែង និងបង្កើនការតាំងចិត្តក្នុងការបំពេញការងារសម្រាប់ក្រុមហ៊ុន។

- ពង្រីកមូលដ្ឋាននៃភាគហ៊ុនិក និងវិនិយោគិន

  តាមរយៈការចុះបញ្ជីមូលបត្រ ក្រុមហ៊ុនបានបង្កើតនូវទីផ្សារសម្រាប់ជួញដូរភាគហ៊ុនជាសាធារណៈ។ ទីផ្សារនេះនឹងបង្កើតឲ្យមានសន្ទនីយភាពភាគហ៊ុនរបស់ក្រុមហ៊ុន ដែលបង្កភាពងាយស្រួលក្នុងការទិញ និងលក់ដោយវិនិយោគិនជាតិ និងបរទេស។ លើសពីនេះទៅទៀត ក្រុមហ៊ុនចុះបញ្ជីក៏អាចទាក់ទាញវិនិយោគិនវិជ្ជាជីវៈ ឬ វិនិយោគិនស្ថាប័នដែលមានកេរ្តិ៍ឈ្មោះដែលអាចជួយពង្រីកបណ្តាញទំនាក់ទំនង និងកាលានុវត្តភាពអាជីវកម្មដល់ក្រុមហ៊ុនផងដែរ។

- ទទួលបានប្រភពហិរញ្ញប្បទានរយៈពេលវែង

  នៅពេលគិតគូរអំពីគម្រោងពង្រីកអាជីវកម្មរបស់ខ្លួន សហគ្រាសខ្នាតតូច និងមធ្យម ជានិច្ចកាលតែងជួបប្រទះបញ្ហាខ្វះខាតទុនសម្រាប់វិនិយោគ និងសម្រាប់ប្រើប្រាស់ជាទុនបង្វិល។ សហគ្រាស ជាទូទៅមានប្រភពហិរញ្ញប្បទានច្រើនពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ប៉ុន្តែភាគច្រើននៃប្រភពហិរញ្ញប្បទានទាំងនោះ ជាហិរញ្ញប្បទានរយៈពេលខ្លី ដែលអាចជារនាំងនៃការអភិវឌ្ឍផែនការអាជីវកម្មរយៈពេលវែងរបស់ក្រុមហ៊ុន។ ផ្ទុយទៅវិញ ជាមួយនឹងទីផ្សារ មូលបត្រសហគ្រាសទាំងនេះអាចទទួលបានហិរញ្ញប្បទានរយៈពេលវែង តាមរយៈការ បោះផ្សាយភាគហ៊ុន និងលក់ទៅឲ្យសាធារណជន ហើយទទួលបាននូវមូលនិធិសម្រាប់រួមចំណែក ក្នុងការអនុវត្តផែនការអាជីវកម្មរយៈពេលវែងរបស់សហគ្រាស ដោយសហគ្រាសគ្រាន់តែទូទាត់ត្រលប់ទៅវិនិយោគិនវិញជាភាគលាភ ដែលអាស្រ័យទៅតាមផលចំណេញជាក់ស្តែងរបស់សហគ្រាស និងលទ្ធភាពក្នុងការដកសាច់ប្រាក់។

- ទទួលបានការលើកទឹកចិត្តពន្ធ

  នេះគឺជាការលើកទឹកចិត្តសំខាន់មួយសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ដែលកំពុងសំឡឹងមើលការប្រមូលមូលនិធិតាមរយៈការបោះផ្សាយ និងលក់ភាគហ៊ុននៅលើក្រុម-ហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ។ ក្រុមហ៊ុនទាំងអស់ដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ និងចុះបញ្ជីលក់នៅ ផ.ម.ក. នឹងទទួលបានការកាត់បន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% ក្នុងរយៈពេលបីឆ្នាំ ហើយការលើកទឹកចិត្តនេះនឹងត្រូវផ្តល់ជូនចំពោះការចុះបញ្ជីនៅមុនខែមករា ឆ្នាំ២០១៨។ ស្របពេលជាមួយគ្នានេះផងដែរ ក្រុមហ៊ុនក៏ទទួលបានការលើកលែងទាំងស្រុងចំពោះបំណុលពន្ធលើប្រាក់ចំណេញសម្រាប់រយពេល ១០ ឆ្នាំសារពើពន្ធកន្លងទៅ ដែលបានរកឃើញដោយស្ទង់ការសវនកម្មឯករាជ្យ ក្រោយការធ្វើសវនកម្មពេញលេញរបស់អគ្គនាយកដ្ឋានពន្ធដារ។ បន្ថែមលើនេះទៀត ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ១% ប្រចាំខែ ត្រូវបានព្យួរជាបណ្តោះអាសន្នរយៈពេល៣ឆ្នាំ។

- ទទួលបាននិរន្តភាពអាជីវកម្មជាមួយនឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងដែលរឹងមាំជាងមុន

  ការបង្កើតសហគ្រាសអាជីវកម្មមួយ គឺត្រូវប្រឈមនឹងបញ្ហាជាច្រើន ប៉ុន្តែការរក្សាអាជីវកម្មឲ្យមានចេរភាព គឺរឹតតែជាការងារដ៏លំបាកមួយ និងជាការប្រឈមដ៏ធំសម្រាប់ម្ចាស់អាជីវកម្ម។ សហគ្រាសខ្នាតតូច និងមធ្យមតែងតែជាកម្មវត្ថុនៃការបារម្ភនានាអំពីអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន។ យ៉ាងណាមិញ នៅពេលដែលសហគ្រាសទាំងនេះបានក្លាយជាក្រុមហ៊ុនចុះបញ្ជី ពួកគេនឹងអាចធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចសាជីវកម្ម តាមរយៈការរៀបចំឲ្យមានរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល ដែលនឹងមានតួនាទី ពិនិត្យលើការបំពេញមុខងាររបស់ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន។ បន្ថែមលើសនេះទៀត ម្ចាស់អាជីវកម្មអាចពង្រឹងយន្តការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន ដែលអាចកាត់បន្ថយការអនុវត្តការងារមិនត្រឹមត្រូវ ឬការកែបន្លំផ្សេងៗក្នុងដំណើរការអាជីវកម្មប្រចាំថ្ងៃ។ ជាលទ្ធផល អភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងនឹងជួយដល់សហគ្រាសខ្នាតតូច និងមធ្យមឲ្យមានការរីកចំរើនប្រកបដោយនិរន្តរភាព។ ការទទួលយកការអនុវត្តអភិបាលកិច្ចសាជីវកម្ម នឹងអាចជួយដល់ការត្រៀមខ្លួនរបស់សហគ្រាសខ្នាតតូច និងមធ្យម ក្នុងការប្រកួតប្រជែងជាមួយគូប្រកួតប្រជែងក្នុងតំបន់អាស៊ានដទៃទៀត ដែលនឹង

មកដល់ក្នុង ក្របខណ្ឌនៃសហគមន៍សេដ្ឋកិច្ចអាស៊ានដែលនឹងចាប់បដិសន្ធិនៅចុងឆ្នាំ ២០១៥ ខាងមុខនេះ។

- ការធ្វើឲ្យប្រសើរឡើងនូវកេរ្តិ៍ឈ្មោះ និងភាពមើលឃើញរបស់ក្រុមហ៊ុន
  ក្រុមហ៊ុនចុះបញ្ជីមួយ ជាទូទៅទាក់ទាញចំណាប់អារម្មណ៍របស់វិនិយោគិនទាំងក្នុង និងក្រៅប្រទេសតាមរយៈប្រព័ន្ធព័ត៌មាន និងសាធារណជន ហើយកិច្ចប្រតិបត្តិការអាជីវកម្ម ឬហិរញ្ញវត្ថុ តែងត្រូវបានផ្សព្វផ្សាយតាមរយៈកាសែត និងទូរទស្សន៍ ព្រមទាំងត្រូវបានលើកឡើងទាំងក្នុង និងក្រៅប្រទេសផងដែរ។ ប្រការនេះអាចជួយកែលម្អនូវរូបភាព និងកេរ្តិ៍-ឈ្មោះរបស់ក្រុមហ៊ុនដែលអាចឲ្យសាធារណជនស្គាល់កាន់តែច្រើនអំពីផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន។ តាមរយៈនេះ ក្រុមហ៊ុនក៏អាចពង្រឹងនូវឧត្តមភាពប្រកួតប្រជែងរបស់ខ្លួនចំពោះដៃគូប្រកួតប្រជែងដែលមិនមែនជាក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ នៅក្នុងបរិបទនៃសេដ្ឋកិច្ចសកលភាវូបនីយកម្មដែលពោរពេញដោយការប្រកួតប្រជែង។
- ការត្រៀមខ្លួនជាមុនចំពោះបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល
  ក្រុមហ៊ុនទាំងអស់ កំពុងតែត្រូវបានឃ្លាំមើលដោយរាជរដ្ឋាភិបាល អំពីការអនុវត្តកាតព្វកិច្ចផ្លូវច្បាប់របស់ពួកគេដែលរួមទាំងការអនុវត្តពន្ធ ការកាន់បញ្ជីគណនី និងការធ្វើសវនកម្មជាដើម។ សេរីភាពដែលកំពុងថមថយនេះ នឹងជម្រុញឲ្យចាប់ផ្តើមអនុវត្តឲ្យបានឆាប់នូវកាតព្វកិច្ចច្បាប់នានា និងការក្លាយខ្លួនជាក្រុមហ៊ុនចុះបញ្ជីនៅក្នុងទីផ្សារមូលបត្រ។ ដូច្នេះ សូមចាប់យកឱកាសនេះ ដើម្បីទទួលបានអត្ថប្រយោជន៍ក្នុងនាមជាក្រុមហ៊ុននាំមុខគេ។

## ៣.៦. ការវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយ

យោងទៅតាមការសិក្សាស្រាវជ្រាវលើរបាយការណ៍សិក្សាមួយច្បាប់នេះ ធ្វើឲ្យយើងខ្ញុំទាញបាននូវចំណុចខ្លាំង និងចំណុចខ្សោយនៃការចុះបញ្ជីនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាដូចខាងក្រោម៖

❖ **ចំណុចខ្លាំង**

- ព័ត៌មាននៃការចុះបញ្ជីនៅ ផ.ម.ក. មានភាពទូលំទូលាយ និងច្បាស់លាស់
- មានច្បាប់ បទប្បញ្ញត្តិ និងលក្ខខណ្ឌតម្រូវច្បាស់លាស់សម្រាប់ក្រុមហ៊ុនដែលមានបំណងចង់ចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក.
- ក្រុមហ៊ុនដែលបានចុះបញ្ជីនៅ ផ.ម.ក. សុទ្ធសឹងជាក្រុមហ៊ុនរដ្ឋ និងឯកជនធំៗ ដែលមានស្ថានភាពហិរញ្ញវត្ថុនឹងនរ និងមានចក្ខុវិស័យច្បាស់លាស់ ក្នុងការជួយទ្រទ្រង់សេដ្ឋកិច្ចជាតិ
- ផ.ម.ក. មានរៀបចំនូវពិព័រណ៌ផ្សារភាគហ៊ុនជារៀងរាល់ឆ្នាំ ដើម្បីផ្សព្វផ្សាយនូវចំណេះដឹង និងព័ត៌មានទាក់ទងនឹងមូលបត្រ រួមទាំងវិធីសាស្ត្រនៃការជួញដូរមូលបត្រ
- ផ.ម.ក. មានរៀបចំនូវសិក្ខាសិលា និងវគ្គបណ្តុះបណ្តាលផ្សេងៗពាក់ព័ន្ធនឹងវិស័យមូលបត្រ ដើម្បីជាព័ត៌មានដល់សាធារណជន
- លើកស្ទួយប្រាក់រៀល ដោយសារតែការចរាចរមូលបត្រប្រើប្រាស់រូបិយប័ណ្ណជាតិ
- បានកំណែទម្រង់ច្បាប់ ប្រកាស និងអនុក្រឹត្យថ្មី ដើម្បីជាដំណោះស្រាយក្នុងការអនុវត្តការងារឲ្យកាន់តែមានប្រសិទ្ធិភាព។

❖ **ចំណុចខ្សោយ**

- ដំណើរការនៃការចុះបញ្ជីនៅ ផ.ម.ក. មានរយៈពេលវែង និងចំណាយចរិការច្រើន
- សមាជិក និងអ្នកចូលរួមរបស់ ផ.ម.ក. នៅមានចំនួនតិចនៅឡើយ
- ការវិនិយោគលើវិស័យមូលបត្រពីសាធារណជននៅមិនទាន់មានសន្ទុះខ្លាំងក្លានៅឡើយ
- ក្រុមហ៊ុនដែលចុះបញ្ជីនៅ ផ.ម.ក. មានចំនួនតិចតួច។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ឆ្លងកាត់ការសិក្សាស្រាវជ្រាវ និងចុះកម្មសិក្សាដោយផ្ទាល់នៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជារយៈពេលពីរខែរួចមកលើប្រធានបទ "ការចុះបញ្ជីលក់មូលបត្រនៅក្នុងក្រុមហ៊ុនផ្សារមូល-បត្រកម្ពុជា" យើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនទាក់ទងទៅនឹងវិស័យមូលបត្រនេះ រួមមានទាំងច្បាប់ បទប្បញ្ញត្តិ និងនិតីវិធីផ្សេងៗក្នុងការជួញដូរមូលបត្រ។ លើសពីនេះទៅទៀត យើងខ្ញុំបានសិក្សាស្វែងយល់យ៉ាងលម្អិតអំពីដំណើរការនៃការចុះបញ្ជីលក់មូលបត្រ ដើម្បីផ្តល់ជាចំណេះដឹង ក៏ដូចជាព័ត៌មានដល់ក្រុមហ៊ុន និងសហគ្រាសដែលមានបំណងចង់ចុះបញ្ជីលក់មូលបត្ររបស់ខ្លួននៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ដើម្បីត្រៀមខ្លួនរួចជាស្រេចក្នុងដំណើរការចុះបញ្ជីលក់មូលបត្រ ក្រុមហ៊ុន ឬសហគ្រាសត្រូវស្វែងយល់ពីលទ្ធភាពនៃការចុះបញ្ជី លក្ខខណ្ឌតម្រូវចាំបាច់ដែល ក្រុមហ៊ុនត្រូវមាន រយៈពេលនៃដំណើរការ និងថ្លៃសេវាកម្មសម្រាប់ដំណើរការទាំងមូល។

ក្រឡេកទៅមើលទិដ្ឋភាពជាក់ស្តែងនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា យើងសង្កេតឃើញថា ទោះបីជាការដាក់ឲ្យដំណើរការនៃផ្សារមូលបត្រកម្ពុជានៅក្នុងឆ្នាំ២០១១ ពុំសូវទទួលបានការចាប់អារម្មណ៍ពីសំណាក់សាធារណជនទូទៅ និងវិនិយោគិនយ៉ាងណាក្តី ក៏ប៉ុន្តែនៅក្នុងអំឡុងឆ្នាំ ២០១៨-២០១៩ សន្ទុះនៃការវិនិយោគ ក៏ដូចជាកំនើននៃក្រុមហ៊ុនចុះបញ្ជីមានការកើនឡើងគួរឲ្យកត់សម្គាល់។ យើងឃើញថា ក្រុមហ៊ុន និងសហគ្រាសធំៗ ជាពិសេសមីក្រូហិរញ្ញវត្ថុកំពុងតែនឹងត្រៀមខ្លួនក្នុងការចុះបញ្ជីលក់ប័ណ្ណភាគហ៊ុនរបស់ខ្លួននៅលើទីផ្សារ ស្របពេលដែលវិនិយោគិនបរទេសមួយចំនួនធំ បាននឹងកំពុងងាកមកចាប់អារម្មណ៍លើការវិនិយោគក្នុងវិស័យមូលបត្រនៅកម្ពុជាផងដែរ។

សរុបសេចក្តីមក ជាលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា ទោះបីជាវិស័យមូលបត្រជាវិស័យថ្មីមួយដែលទើបនឹងកកើតមិនយូរប៉ុន្មាន ក៏ប៉ុន្តែវិស័យនេះបានវិវត្តខ្លួនយ៉ាងឆាប់រហ័ស និងដើរតួជាកាតាលីករដ៏មានសក្តានុពលក្នុងការកៀរគរមូលធនពីសាធារណជនទាំងក្នុង និងក្រៅប្រទេស។ លើសពីនេះទៅទៀត ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ពិតជាបានចូលរួមជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការជម្រុញល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យមានភាពរីកចម្រើនលូតលាស់ទៅមុខយ៉ាងឆាប់រហ័ស។

## ២. អនុសាសន៍

ដោយសារក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ជាទីផ្សារមូលបត្រដំបូងបង្អស់នៅកម្ពុជា និងដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូច្នេះ យើងខ្ញុំសូមផ្តល់ជាអនុសាសន៍មួយចំនួនក្នុងការចូលរួមចំណែកអភិវឌ្ឍការរីកចំរើនក្នុងវិស័យមូលបត្រនៅកម្ពុជា ដូចខាងក្រោម៖

- ផ.ម.ក. គួរតែរៀបចំនូវសេវាកម្ម និងអនុវត្តដំណើរការនៃការចុះបញ្ជីឲ្យមានភាពរហ័ស និងប្រើរយៈពេលខ្លី
- រៀបចំវិធីសាស្ត្រក្នុងការទាក់ទាញអ្នកវិនិយោគបន្ថែមទៀត ពីព្រោះទំហំនៃការជួញដូរនៅ ផ.ម.ក. នៅមានចំនួនតិចនៅឡើយ
- ដោយសារបច្ចុប្បន្ននេះ វិនិយោគិនបរទេស មានការចាប់អារម្មណ៍លើការវិនិយោគមូល-បត្រនៅកម្ពុជា ដូច្នេះ ផ.ម.ក. គួរតែរៀបចំឯកសារផ្សព្វផ្សាយព័ត៌មានជាភាសាបរទេស និងសេវាកម្មឲ្យកាន់តែមានភាពទូលំទូលាយ និងមានប្រសិទ្ធិភាព ដើម្បីជាផ្នែកមួយក្នុងការជំរុញកំនើនវិនិយោគនៅលើទីផ្សារ
- ដោយសារតែការយល់ដឹងពីវិស័យមូលបត្រ និងការវិនិយោគលើមូលបត្រនៅមានកម្រិតនៅឡើយសម្រាប់សាធារណជនទូទៅ ដូច្នេះ ផ.ម.ក. គួរតែបង្កើនការផ្សព្វផ្សាយបន្ថែមតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដូចជា បណ្តាញសង្គម វិទ្យុ ទូរទស្សន៍ កាសែតជាដើម ដើម្បីបញ្ជ្រៀបព័ត៌មានដល់សាធារណជនឲ្យកាន់តែទូលំទូលាយ។

# ឯកសារយោង

## អនុក្រឹត្យ គោលការណ៍ណែនាំ និងប្រកាស

- គោលការណ៍ណែនាំស្តីពី យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង
- ប្រកាសស្តីពី ការដាក់ឲ្យអនុវត្តនូវការកែប្រែវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
- ប្រកាសស្តីពី ការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិករក្សាទុកមូលបត្រ

## សៀវភៅ


- សាស្ត្រាចារ្យ សួន ចំរើន, "រូបិយវត្ថុ និងធនាគារ ២០១៧-២០១៨"
- សាស្ត្រាចារ្យ សួន ចំរើន, "ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១ ២០១៨-២០១៩"
- គណៈកម្មការមូលបត្រកម្ពុជា, "អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ"
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, "សៀវភៅមគ្គុទេសក៍សម្រាប់ការចុះបញ្ជី"
- គឹម ច័ន្ទសុវណ្ណលក្ខិណា, ឆ្នាំ ២០១៧ "ការជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជា"
- ឆេក ច័ន្ទម៉ារីទី និង គន្ធា បូរ៉ានិត, ឆ្នាំ២០១៦, "ការលើកទឹកចិត្តក្នុងវិស័យមូលបត្រនៅកម្ពុជា"
- ស៊ូ សុជា និង អ៊ួង នីតា, ឆ្នាំ២០១៥ "ការវិនិយោគលើមូលបត្រនៅផ្សារមូលបត្រកម្ពុជា និងការវិនិយោគលើភាគហ៊ុន"


## គេហទំព័រ

- http://www.secc.gov.khគណៈកម្មការមូលបត្រកម្ពុជា
- www.csx.com.khក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- http://www.csx.com.kh/kh/product/equities.jsp?MNCD=4020មូលបត្រកម្មសិទ្ធិ
- http://www.csx.com.kh/kh/product/bond.jsp?MNCD=4040មូលបត្របំណុល
- http://siborann.blogspot.com/2011/09/blog-post_09.htmlប្រវត្តិទីផ្សារមូលបត្រ
- http://www.csx.com.kh/kh/about/profile.jsp?MNCD=10301ប្រវត្តិ ផ.ម.ក.
- http://www.csx.com.kh/kh/product/mainboard.jsp?MNCD=30102ទីផ្សារគោល
- http://www.csx.com.kh/kh/product/growthboard.jsp?MNCD=30103ទីផ្សារកំណើន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:......០០២..........គ.ម.ក/ស.ណ.ន

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១១*

# គោលការណ៍ណែនាំ
# ស្តីពី
# យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសលេខ ០០១ គ.ម.ក.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង ធានាឱ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង គណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក)** សូមធ្វើការណែនាំនូវយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមាន ដូចខាងក្រោម÷

*១- ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ*

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក **គ.ម.ក.** ដែលលិខិតមានខ្លឹមសារ ០៣ ចំណុចដូចខាងក្រោម:

១- គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Purpose of IPO)

២- គម្រោងពេលវេលារំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Expected Timetable)

៣- ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរំពឹងទុក (Expected IPO Team) រួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

### ២- *ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ*

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រ ក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.**។

### ៣- *ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO Team)*

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការតែងតាំង បុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក** ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយ ត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

### ៤- *ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence)*

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះ ត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ ។

### ៥- *ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារ ស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ។

*៦- ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក*

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមក គ.ម.ក.។ គ.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មាន មុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ជូនក្រុមហ៊ុនបោះផ្សាយ។

*៧- ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង (Book Building)*

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក. ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

*៨- ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

*៩- ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ (Term of Offer) និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក*

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូនគ.ម.ក. ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**១០**- *ការធ្វើបរិវិសកម្មមូលបត្រ (Subscription)*

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី **គ.ម.ក.** ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ៣ និង ជំពូកទី ៤ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**១១**- *ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ*

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះ ភ្ជាមជូន **គ.ម.ក.**។

**១២**- *ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិ ទៅឱ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីផ្ញូវមូលបត្រជាផ្លូវការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**គណៈកម្មការមូលបត្រកម្ពុជា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ: ០០៤ / ១៨ គ.មូ.ក./ប្រ.ក.

## ប្រកាស

## ស្ដីពី

## ការដាក់ឱ្យអនុវត្តនូវការកែប្រែ

## វិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

* * * * *

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការផ្ដល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រក ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១០ ស្ដីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

- បានឃើញប្រកាសលេខ ០០៥/១៥ គ.ម.ក./ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- បានឃើញប្រកាសលេខ០០៦/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
- យោងតាមសំណើសុំអនុម័តលើវិសោធនកម្មនៃវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨

**សម្រេច**

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ ៨ ថ្មី នៃវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ ៨ នៃវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០០៦/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១២ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៨
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
- "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ ០០៤/១៨......

ចុះថ្ងៃទី១៥ ខែ ៥ ឆ្នាំ២០១៨

ស្តីពី

## ការកែប្រែវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

## របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

### ប្រការ ៨ ថ្មី.- លក្ខខណ្ឌតម្រូវជាតួលេខ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ ផ.ម.ក. ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. លក្ខខណ្ឌសម្រាប់ទីផ្សារគោល (Main Board)

ក- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៣០.០០០.០០០.០០០ (សាមសិបពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ- ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងប្រាក់ចំណេញសរុបចំនួន ៣.០០០.០០០.០០០ (បីពាន់លាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ២០០ (ពីររយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយ ផ.ម.ក.។

ឃ- ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ៧ (ប្រាំពីរ) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយផ.ម.ក.។

២. លក្ខខណ្ឌសម្រាប់ទីផ្សារកំណើន (Growth Board)

ក- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ- ត្រូវបំពេញលក្ខខណ្ឌប្រាក់ចំណេញណាមួយដូចខាងក្រោម៖

- ត្រូវមានប្រាក់ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ ឬ
- ត្រូវមានលំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន (positive Opetating Cash Flow) និងត្រូវមានអត្រាប្រាក់ចំណេញដុលយ៉ាងហោចណាស់ ១០ (ដប់) ភាគរយ។

ឍ-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ១០០ (មួយរយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

ឃ-ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ១០ (ដប់) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។

ក្នុងអំឡុងពេល ៣ (បី) ឆ្នាំដំបូងបន្ទាប់ពីការដាក់ឱ្យអនុវត្តប្រការ ៨ ថ្មីនេះ គ.ម.ក. អាចសម្រេចលើកលែងលក្ខខណ្ឌដូចបានចែងនៅក្នុងចំណុចទី២ នៃប្រការ ៨ ថ្មីនេះ តាមការចាំបាច់។

* * *

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ: ០១១ គ ម ក

# ប្រកាស

## ស្តីពី

## ការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និង ប្រតិបត្តិករក្សាទុកមូលបត្រ

*****

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

Phone: [illegible] Fax: [illegible]
E-mail: [illegible]

- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់នូវលក្ខខណ្ឌតម្រូវ និតិវិធីដើម្បីផ្តល់ការអនុញ្ញាតឱ្យបុគ្គលធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬ ប្រតិបត្តិកររក្សាទុកមូលបត្រ និងកំណត់អំពីកាតព្វកិច្ចរបស់រាល់ប្រតិបត្តិករ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

-ច្បាប់ (Law) សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-អនុក្រឹត្យ (Anukret) សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-ប្រព័ន្ធជាត់ទាត់និងទូទាត់ (Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធដែលផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ បំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមកបាន ដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការឱ្យបានច្បាស់លាស់ និងធានាឱ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឱ្យអ្នកទិញ។ ប្រព័ន្ធជាត់ទាត់និងទូទាត់ រួមមាន ៖

ក-ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ (Securities Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធជាត់ទាត់និងទូទាត់ដើម្បីធ្វើការផ្ទាស់ប្តូរកម្មសិទ្ធិលើមូលបត្រ រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

ខ-ប្រព័ន្ធជាត់ទាត់និងទូទាត់សាច់ប្រាក់ (Cash Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធជាត់ទាត់និងទូទាត់ ដើម្បីធ្វើការផ្ទេរ ឬបង្វែរសាច់ប្រាក់រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

-បុគ្គលិកជាន់ខ្ពស់ (Senior Staff) សំដៅដល់បុគ្គលិកដែលមានឋានៈចាប់ពីអគ្គនាយករហូតដល់នាយកឬប្រធានផ្នែក រួមទាំងសវនករផ្ទៃក្នុង។

-ភាគហ៊ុនិកភាគតិច (Minority shareholder) សំដៅដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតតិចជាង ០៥ (ប្រាំ) ភាគរយ។

-អភិបាល (Director) សំដៅដល់ប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាលរបស់បុគ្គលដាក់ពាក្យស្នើសុំ ឬរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ។

## ជំពូកទី ២

## លក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាត

**ប្រការ ៣.-**

បុគ្គលដែលមានបំណងធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវដាក់ពាក្យស្នើសុំ និងត្រូវទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ក្រោយពីទទួលបានការសម្រេចពីការប្រជុំពេញអង្គរបស់ **គ.ម.ក.** ដោយអនុលោមតាមជំពូកទី៤នៃច្បាប់ ជំពូកទី៣នៃអនុក្រឹត្យ និងប្រកាសនេះ។

**ប្រការ ៤.-**

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវតែជាក្រុមហ៊ុនមូលធនដែលបង្កើត និងចុះបញ្ជីស្របតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឬជាក្រុមហ៊ុនដែលស្ថិតក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។ លក្ខន្តិកៈរបស់បុគ្គលដាក់ពាក្យស្នើសុំ ត្រូវគោរពតាមលក្ខខណ្ឌតម្រូវដែលកំណត់ក្នុងមាត្រា ១៩ នៃអនុក្រឹត្យ និងលក្ខខណ្ឌដូចខាងក្រោម ៖

១-នាមករណ៍ និងទម្រង់របស់ក្រុមហ៊ុន។

២-ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនត្រូវមានទីតាំងក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-កម្មវត្ថុអាជីវកម្ម។

៤-ដើមទុនជារូបិយវត្ថុជាតិ ៖

ក-ក្នុងករណីស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវមានចំនួនមិនតិចជាង ៤០.០០០.០០០.០០០ (សែសិបពាន់លាន) រៀល។

ខ-ក្នុងករណីស្នើសុំធ្វើជាប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវមានចំនួនមិនតិចជាង ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល។

គ-ក្នុងករណីស្នើសុំធ្វើជាប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវមានចំនួនមិនតិចជាង ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល។

ឃ-ក្នុងករណីស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ និងប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវមានចំនួនមិនតិចជាង ៨០.០០០.០០០.០០០ (ប៉ែតសិបពាន់លាន) រៀល។

៥-ចំណាត់ប្រភេទនិងចំនួនភាគហ៊ុន រួមទាំងតម្លៃចារឹកក្នុងមួយភាគហ៊ុន ដោយបញ្ជាក់ឱ្យបានច្បាស់នូវនីតិវិធី និងលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃដើមទុនដែលបង់ចូលជាភាគទុនរបស់ភាគហ៊ុនិកនីមួយៗ។

៦-ឈ្មោះ អាសយដ្ឋានពិតប្រាកដ និងចំណែកហ៊ុនរបស់ភាគហ៊ុនិកស្ថាបនិក ឬភាគហ៊ុនិកដែលមានសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើន។

៧-សិទ្ធិ និងកាតព្វកិច្ចរបស់ភាគហ៊ុនិក ពិសេសរបស់ភាគហ៊ុនិកភាគតិច។

៨-ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ដោយបញ្ជាក់ពីតួនាទីនិងការទទួលខុសត្រូវរបស់អភិបាលម្នាក់ៗ។ ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនត្រូវមានអភិបាលយ៉ាងតិចបំផុតចំនួន ០៥ (ប្រាំ) រូប។

៩-វិធាន និងយន្តការនៃការត្រួតពិនិត្យនិងដោះស្រាយទំនាស់ផលប្រយោជន៍ដែលអាចកើតមាននៅក្នុងក្រុមហ៊ុន។

១០-នីតិវិធីនៃការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានដែលពាក់ព័ន្ធ។

១១-នីតិវិធីនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងមហាសន្និបាតភាគហ៊ុនិក។

**ប្រការ ៥.-**

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវ ៖

១-មានធនធានគ្រប់គ្រាន់ ដែលរួមមាន ៖

ក-ទ្រព្យគ្រប់គ្រាន់ និងត្រូវបានគ្រប់គ្រងត្រឹមត្រូវសម្រាប់ធ្វើប្រតិបត្តិការ។

ខ-ធនធានមនុស្សប្រកបដោយចំណេះដឹង សមត្ថភាព និងបទពិសោធន៍ខ្ពស់ សមស្របនឹងមុខតំណែងនីមួយៗរបស់ក្រុមហ៊ុន។

គ-ប្រព័ន្ធ និងយន្តការសម្រាប់ធ្វើប្រតិបត្តិការដែលទទួលបានការអនុញ្ញាត។

ឃ-ប្រព័ន្ធទ្រទ្រង់ (Back-up System) សមស្រប ដើម្បីធានាបាននូវប្រតិបត្តិការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

២-មានរចនាសម្ព័ន្ធគ្រប់គ្រងក្រុមហ៊ុនមួយ ដែលអាចធានាបាននូវគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងអភិបាលកិច្ចសាជីវកម្មល្អ។ ក្នុងករណីស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ និងប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រងប្រតិបត្តិការនីមួយៗដាច់ដោយឡែកពីគ្នា។

៣-មានសវនកម្មផ្ទៃក្នុង រួមទាំងវិន័យនិងនីតិវិធីនៃការអនុវត្តសវនកម្មផ្ទៃក្នុង និងគណៈកម្មាធិការសវនកម្ម។

**ប្រការ ៦.-**

បុគ្គលដាក់ពាក្យស្នើសុំ បុគ្គលដែលត្រូវតែងតាំងជាអភិបាលនិងបុគ្គលិកជាន់ខ្ពស់របស់បុគ្គលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម ៖

១-មានលក្ខណសម្បត្តិនិងអត្តចរិតល្អ ដូចមានចែងក្នុងមាត្រា៤២ នៃអនុក្រឹត្យ។

២-មិនធ្លាប់ត្រូវបានប្រកាសក្ស័យធន ឬមិនធ្លាប់បង្កឱ្យក្រុមហ៊ុនមួយឬច្រើនឈានទៅរកភាពក្ស័យធននៅក្នុងឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៣-មិនធ្លាប់ប្រព្រឹត្តអំពើអ្វីដែលនាំឱ្យប៉ះពាល់ដល់ដំណើរការទីផ្សារមូលបត្រ ឬនៅក្នុងវិស័យហិរញ្ញវត្ថុ។

៤-មិនធ្លាប់ត្រូវបានដកហូតតំណែង ឬបណ្តេញចេញពីតំណែងឬពីទីផ្សារ ដោយយោងតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធ។

៥-មិនធ្លាប់ប្រព្រឹត្តអ្វីដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ។

**ប្រការ ៧.-**

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រត្រូវ ៖

១-មានចំនួនភាគហ៊ុនភាគច្រើនដាច់ខាតកាន់កាប់ដោយប្រតិបត្តិករទីផ្សារមូលបត្រ។

២-មានភាគហ៊ុនដទៃទៀតដែលកាន់កាប់ដោយក្រុមហ៊ុនមូលបត្រ ស្ថាប័នហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** ក្នុងករណីដែលប្រតិបត្តិករទីផ្សារមូលបត្រជាភាគហ៊ុនិកភាគច្រើនដាច់ខាត។

ភាគហ៊ុនរបស់បុគ្គលដាក់ពាក្យស្នើសុំ ធ្វើជាប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ អាចផ្ទេរបានតែទៅក្នុងរង្វង់ប្រតិបត្តិករទីផ្សារមូលបត្រ ក្រុមហ៊ុនមូលបត្រ ស្ថាប័នហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។ ប៉ុន្តែប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវរក្សាចំនួនភាគហ៊ុនអប្បបរមាក្នុងកម្រិតភាគច្រើនដាច់ខាត។

**ប្រការ ៨.-**

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវបំពេញបែបបទនៃពាក្យស្នើសុំទៅតាមទម្រង់ដែលបានកំណត់ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖

១-វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

២-វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម និងប័ណ្ណប៉ាតង់ ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៣-លក្ខន្តិកៈក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៤-លិខិតបញ្ជាក់ពីដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ។

៥-បញ្ជីរាយនាមភាគហ៊ុនិក ដោយបញ្ជាក់ពីចំនួនហ៊ុន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនថតចម្លង ដោយមានចុះហត្ថលេខាឬស្នាមម្រាមដៃរបស់ភាគហ៊ុនិកនីមួយៗ។

៦-បញ្ជីរាយនាមអភិបាលក្រុមហ៊ុន ដោយបញ្ជាក់ពីតួនាទីនិងបទពិសោធន៍ការងារ និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនថតចម្លង ដោយមានចុះហត្ថលេខាឬស្នាមម្រាមដៃរបស់អភិបាលនីមួយៗ ព្រមទាំងលិខិតថ្កោលទោស។

៧-បញ្ជីរាយនាមបុគ្គលិកជាន់ខ្ពស់ទាំងអស់របស់ក្រុមហ៊ុន ដោយបញ្ជាក់ពីតួនាទី និងបទពិសោធន៍ការងារ និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនថតចម្លង ដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃរបស់បុគ្គលិកជាន់ខ្ពស់នីមួយៗ ព្រមទាំងលិខិតថ្កោលទោស។

៨-បញ្ជីរាយនាមបុគ្គលដែលមានបំណងធ្វើជាសមាជិក ឬអ្នកចូលរួមក្នុងទីផ្សាររបស់បុគ្គលដាក់ពាក្យស្នើសុំ។

៩-ផែនការអាជីវកម្មសម្រាប់រយៈពេលយ៉ាងតិច ០៣ (បី) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ។

១០-ផែនការគ្រប់គ្រងហានិភ័យ និងផែនការយថាភាព (Contingency Plan)។

១១-វិធានប្រតិបត្តិការ ដែលក្នុងនោះមានចែងនូវវិធាននិងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ប្រតិបត្តិករ វិធាននិងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាពនិងការចូលរួមក្នុងទីផ្សារ និងលក្ខខ័ណ្ឌ (លក្ខន្តិកៈ) របស់ប្រតិបត្តិករដែលបុគ្គលស្នើសុំធ្វើប្រតិបត្តិការ។ ករណីស្នើសុំធ្វើប្រតិបត្តិករទីផ្សារមូលបត្រ វិធានប្រតិបត្តិការត្រូវចែងបន្ថែមនូវវិធាននៃការចុះបញ្ជីនៅទីផ្សារមូលបត្រ។

**ប្រការ ៩.-**

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ផ្តល់ឯកសារនិងបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងទៀតតាមការចាំបាច់ ដើម្បីធានាថាបុគ្គលដាក់ពាក្យស្នើសុំបំពេញបានគ្រប់លក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ ១០.-**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើពាក្យស្នើសុំការអនុញ្ញាតដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

១-បុគ្គលដាក់ពាក្យស្នើសុំមិនបានបំពេញនូវលក្ខខណ្ឌណាមួយ ដែលមានចែងក្នុងប្រកាសនេះ ឬសេចក្តីណែនាំផ្សេងទៀតដែលធ្វើនៅក្រោមប្រកាសនេះ ឬបទប្បញ្ញត្តិជាធរមានដែលពាក់ព័ន្ធផ្សេងទៀត។

២-ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ទៅ **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស។

៣-បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ ឬរំលាយអាជីវកម្ម។

៤-សេចក្ដីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំខូចខាតសងបំណុល មិនត្រូវបានអនុវត្តទាំងស្រុងឬមួយផ្នែកដោយបុគ្គលដាក់ពាក្យស្នើសុំនោះ។

៥-បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់បុគ្គលដាក់ពាក្យស្នើសុំ ៖

ក-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ខ-បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិ ដែលការពារសាធារណជនឱ្យចៀសផុតពីការខាតបង់ផ្នែកហិរញ្ញវត្ថុ ដោយសារតែភាពមិនស្មោះត្រង់ ឬអសមត្ថភាព ឬការប្រព្រឹត្តមិនត្រឹមត្រូវរបស់បុគ្គលនោះក្នុងការផ្ដល់សេវាហិរញ្ញវត្ថុឬក្នុងការគ្រប់គ្រងក្រុមហ៊ុន។

គ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀត ដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្ដីសម្រេចរបស់ខ្លួន។

ឃ-ស្ដែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្ដីសុចរិត និងភាពដែលអាចទុកចិត្តបានផ្នែកហិរញ្ញវត្ថុរបស់បុគ្គលទាំងនោះ។

ង-ស្ដែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌនៃការអនុញ្ញាត ប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។

៦-អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុងឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ)ឆ្នាំ ចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-នៅពេលកើតមានហេតុការណ៍ណាមួយដែលអាច ៖

ក-នាំឱ្យបុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំមិនអាចធ្វើអាជីវកម្មបានត្រឹមត្រូវ។

ខ-ឆ្លុះបញ្ចាំងពីភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្ម របស់បុគ្គលដាក់ពាក្យស្នើសុំ។

៨-បុគ្គលដាក់ពាក្យស្នើសុំ មាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ និង

ហិរញ្ញប្បទានការវិកម្ម ឬការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំ អាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវបដិសេធផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំ ដោយមិនបានផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងមិនបានផ្តល់នឹកាសឱ្យបុគ្គលដាក់ពាក្យស្នើសុំធ្វើការពន្យល់។

## ជំពូកទី ៣
## ការផ្តល់ការអនុញ្ញាត

**ប្រការ ១១.-**

បន្ទាប់ពីបុគ្គលដាក់ពាក្យស្នើសុំបានបំពេញតាមគ្រប់លក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ បទប្បញ្ញត្តិជាធរមាននិងប្រកាសនេះ ក្នុងរយៈពេលហាសិបថ្ងៃ ០៦ (ប្រាំមួយ) ខែ **គ.ម.ក.** ត្រូវពិនិត្យនិងសម្រេចលើការស្នើសុំនោះ។ អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ការអនុញ្ញាត ឬជូនដំណឹងអំពីការបដិសេធ ដល់បុគ្គលដាក់ពាក្យស្នើសុំតាមការសម្រេចរបស់ **គ.ម.ក.**។ ក្នុងករណីអគ្គនាយកនៃ **គ.ម.ក.** ស្នើសុំឱ្យបុគ្គលដាក់ពាក្យស្នើសុំកែប្រែ ឬផ្តល់ព័ត៌មានបន្ថែម នោះលក្ខខណ្ឌពេលវេលាក្នុងការពិនិត្យនិងសម្រេចត្រូវគិតសាឡើងវិញ ចាប់តាំងពីកាលបរិច្ឆេទដែលព័ត៌មានទាំងនោះត្រូវបានផ្តល់ជូនដល់ **គ.ម.ក.**។

**ប្រការ ១២.-**

សុពលភាពនៃការអនុញ្ញាតមានរយៈពេលមិនកំណត់។

**ប្រការ ១៣.-**

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវបង់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ១០.០០០.០០០ (ដប់លាន) រៀល នៅពេលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករនីមួយៗ។ ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាមានការបដិសេធលើពាក្យស្នើសុំក៏ដោយ។

បុគ្គលដែលទទួលបានការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវបង់ថ្លៃការអនុញ្ញាតប្រចាំឆ្នាំ

ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល សម្រាប់ប្រតិបត្តិករនីមួយៗ។ សម្រាប់ឆ្នាំសារពើពន្ធដំបូងនៃការអនុញ្ញាត ប្រតិបត្តិករនីមួយៗត្រូវបង់ថ្លៃការអនុញ្ញាតនៅពេលទទួលបានការអនុញ្ញាត។ សម្រាប់ឆ្នាំសារពើពន្ធបន្តបន្ទាប់ ប្រតិបត្តិករនីមួយៗត្រូវបង់ថ្លៃការអនុញ្ញាតប្រចាំឆ្នាំ យ៉ាងយូរនៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំសារពើពន្ធចាស់។

## ជំពូកទី ៤
## ភារកិច្ចរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

**ប្រការ ១៤.-**

បន្ទាប់ពីទទួលបានការអនុញ្ញាត ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវចាប់ផ្តើមសកម្មភាពអាជីវកម្មរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ ដោយគិតចាប់ពីថ្ងៃដែលប្រតិបត្តិករបានទទួលការអនុញ្ញាត។

**ប្រការ ១៥.-**

ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រត្រូវ ៖

១-ធ្វើប្រតិបត្តិការរបស់ខ្លួនឱ្យដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

២-ត្រួតពិនិត្យ និងគ្រប់គ្រងដោយប្រុងប្រយ័ត្នខ្ពស់រាល់ហានិភ័យដែលកើតឡើងពីអាជីវកម្ម ឬប្រតិបត្តិការណាមួយ។

៣-បំពេញឱ្យអស់ពីសមត្ថភាពនូវកាតព្វកិច្ច ដែលមានចែងនៅក្នុងច្បាប់ អនុក្រឹត្យប្រកាសនេះ និងបទប្បញ្ញត្តិនានា ដោយមិនត្រូវប្រព្រឹត្តអ្វីដែលផ្ទុយពីផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍វិនិយោគិន។

៤-អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានប្រតិបត្តិការរបស់ខ្លួន និងបទប្បញ្ញត្តិជាធរមាន ដែលកំណត់ដោយ **គ.ម.ក.** ធនាគារជាតិនៃកម្ពុជា និងក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

៥-ផ្តល់ភាពងាយស្រួលដល់ការប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការរបស់ខ្លួន និងប្រាកដថាសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារគោរពតាមវិធានប្រតិបត្តិការ ដើម្បីធានាឱ្យបាននូវសុវត្ថិភាពនិងប្រសិទ្ធភាពនៃប្រតិបត្តិការ និងការពារផលប្រយោជន៍វិនិយោគិន។

**ប្រការ ១៦.-**

ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវធានាឱ្យបាននូវនិរន្តរភាពនៃដំណើរការទីផ្សារមូលបត្រ និងបំពេញនូវកាតព្វកិច្ចជូនដំណឹង ផ្តល់ព័ត៌មាន និងរក្សាទុកនូវឯកសារ ដូចដែលមានចែងក្នុងជំពូកទី៣ នៃអនុក្រឹត្យ។

**ប្រការ ១៧.-**

អនុលោមតាមមាត្រា ២៧ នៃអនុក្រឹត្យ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវផ្តល់របាយការណ៍ដែលធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មដែលធ្វើអាជីវកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងដែលទទួលស្គាល់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១៨.-**

ក្រៅពីកាតព្វកិច្ចផ្តល់របាយការណ៍ដូចមានចែងក្នុងជំពូកទី៣នៃអនុក្រឹត្យ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍ផ្សេងទៀត តាមការកំណត់របស់ **គ.ម.ក.**។

**ប្រការ ១៩.-**

អភិបាល និងបុគ្គលិកគ្រប់រូបរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់ និងមិនត្រូវប្រព្រឹត្តអាកប្បកិរិយាដែលត្រូវបានហាមឃាត់ដូចមានចែងក្នុងជំពូកទី៧ នៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ប្រការ ២០.-**

អភិបាលរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រទាំងឡាយណាដែលមានការពាក់ព័ន្ធពីផលប្រយោជន៍តាមគ្រប់រូបភាព ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ក្នុងការធ្វើសេចក្តីសម្រេចណាមួយ ឬក្នុងការអនុម័តកិច្ចសន្យាណាមួយដែលធ្វើឡើងដោយកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រកាសព័ត៌មាននេះឱ្យបានទូលំទូលាយ ដល់សមាជិកផ្សេងទៀតរបស់ក្រុមប្រឹក្សាភិបាល តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលមួយសមស្របមុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដែលនឹងសម្រេចទាក់ទងនឹងបញ្ហានោះ។ អភិបាលដែលមានផលប្រយោជន៍ពាក់ព័ន្ធដូចដែលបានរៀបរាប់នេះ មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចប្រជុំ

ក្រុមប្រឹក្សាភិបាល និងមិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតធ្វើសេចក្តីសម្រេចឬក្នុងការអនុម័តកិច្ចសន្យានោះឡើយ។

**ប្រការ ២១.-**

អភិបាល និងបុគ្គលិកគ្រប់រូបរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ សហព័ទ្ធ បុព្វញាតិ ឬបច្ឆាញាតិរបស់ខ្លួនគិតត្រឹមថ្នាក់ទី៣ មិនត្រូវទទួលអំណោយឬផលប្រយោជន៍តាមគ្រប់រូបភាពពីបុគ្គលដែលខ្លួនមានទំនាក់ទំនងអាជីវកម្មឬហិរញ្ញវត្ថុជាមួយ នៅក្នុងការបំពេញមុខងារនិងតួនាទីរបស់ខ្លួន។

**ប្រការ ២២.-**

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវបង្កើតឱ្យមានមូលនិធិធានាការទូទាត់សងមួយដាច់ដោយឡែក ដើម្បីធានាការទូទាត់សងនូវរាល់ប្រតិបត្តិការទូទាត់មិនបានសម្រេច។ នីតិវិធីនៃការបង្កើត ការកំណត់ចំនួនទឹកប្រាក់ ការថែរក្សា និងការចាត់ចែងប្រើប្រាស់មូលនិធិនេះត្រូវកំណត់ដោយ **គ.ម.ក.**។

**ប្រការ ២៣.-**

មុននឹងតែងតាំង ឬផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់ណាមួយ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

ប្រសិនបើតំណែងរបស់បុគ្គលិកជាន់ខ្ពស់ណាមួយនៅទំនេរ ប្រតិបត្តិករត្រូវតែជ្រើសរើសបេក្ខជនថ្មីក្នុងរយៈពេលយ៉ាងយូរ ០២ (ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវឆ្លើយតបទៅនឹងសំណើសុំតែងតាំងបុគ្គលិកជាន់ខ្ពស់នៃប្រតិបត្តិករក្នុងរយៈពេល ០២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំពេញលេញ។ ករណីហួសរយៈពេលកំណត់នេះ សំណើសុំតែងតាំងត្រូវសន្មតថាបានទទួលការយល់ព្រម។

**ប្រការ ២៤.-**

អនុលោមតាមមាត្រា ២៧ នៃច្បាប់ អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិពិនត្យកែតម្រូវ ដាក់លក្ខខណ្ឌ ឬដាក់កំហិតបន្ថែម ព្យួរ ឬដកហូតការអនុញ្ញាត ក្នុងករណីដែលប្រតិបត្តិករ ៖

១-ទទួលបានការអនុញ្ញាតដោយមធ្យោបាយក្លែងបន្លំណាមួយ។

២-ល្មើសនឹងលក្ខខណ្ឌនៃការអនុញ្ញាត។

៣-ល្មើសនឹងកាតព្វកិច្ចដែលចែងក្នុងប្រកាសនេះ។

៤-មិនធ្វើតាមការណែនាំរបស់ អគ្គនាយកនៃ **គ.ម.ក.** ក្នុងការកែតម្រង់ផ្សេងៗ។

៥-នៅតែបន្តប្រតិបត្តិការក្នុងអំឡុងពេលព្យួរការអនុញ្ញាត។

៦-ផ្អាកប្រតិបត្តិការដោយមិនបានរាយការណ៍ជាមុនទៅអគ្គនាយកនៃ **គ.ម.ក.**។

៧-មិនអាចអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យសងបំណុលមួយភាគ ឬទាំងស្រុងទៅបុគ្គលពាក់ព័ន្ធ។

៨-កំពុងស្ថិតនៅក្នុងស្ថានភាពបង្វែកទេស និង/ឬហិរញ្ញវត្ថុទន់ខ្សោយ ឬកំពុងត្រូវរំលាយដោយគ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត ឬដោយការវិនិច្ឆ័យរបស់តុលាការទៅតាមមូលហេតុស្របច្បាប់។

៩-ប្រព្រឹត្តល្មើសនឹងច្បាប់ អនុក្រឹត្យ ប្រកាសនេះ និងបទប្បញ្ញត្តិផ្សេងទៀត។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**ប្រការ ២៥.-**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិ ដូចមានចែងក្នុងប្រកាសនេះ នឹងត្រូវផ្តន្ទាទោសស្របតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រ-កម្ពុជា។

**ប្រការ ២៦.-**

ករណីមានការយឺតយ៉ាវក្នុងការបង់ថ្លៃការអនុញ្ញាត ដូចមានចែងក្នុងប្រការ ១៣ នៃប្រកាសនេះ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវទទួលការដាក់ពិន័យអន្តរការណ៍ជាប្រាក់ ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ០១ (មួយ) ថ្ងៃ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ ២៧.-**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំ ដើម្បីសម្រួលការយល់ដឹងនិងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

**ប្រការ ២៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ២៩.-**

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១[illegible] ខែ [illegible] ឆ្នាំ២០០៩

**គាត ឈន់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា និងសមាជិក **គ.ម.ក.**
- ដូចប្រការ ២៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

SECURITIES AND EXCHANGE COMMISSION OF CAMBODIA

# ប្រកាស

# ស្តីពី

# ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

# PRAKAS

# ON

# THE PUBLIC ISSUANCE OF EQUITY SECURITIES

២០១០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ: ០០១..............គ ម ក

# ប្រកាស
## ស្តីពី
## ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៩

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

# ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងចែងអំពីបែបបទ យន្តការ នីតិវិធី និងការអនុញ្ញាតពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ៖

១-ច្បាប់ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

២-អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៣-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ឬការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ ៖

ក-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មី ឬលើកដំបូងជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

ខ-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលធ្វើឡើងដោយក្រុមហ៊ុនធ្លាប់បានបោះផ្សាយលក់មូលបត្រជាសាធារណៈរួចហើយ។

៤-ប្រាក់បង់លើស (Premium) សំដៅដល់ទឹកប្រាក់ដែលបានទទួលពីការលក់មូលបត្រកម្មសិទ្ធិលើសពីតម្លៃចារឹក។

៥-ភាគហ៊ុនបុរិមា (Preference Share) សំដៅដល់ភាគហ៊ុនដែលអ្នកកាន់កាប់គ្មានសិទ្ធិបោះឆ្នោត និងមានសិទ្ធិជាអាទិភាពក្នុងការទទួលភាគលាភ។

៦-ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.គ.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការកត់ត្រាមូលបត្រដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈដោយក្រុមហ៊ុនបោះផ្សាយ។

៧-ភ្នាក់ងារវាយតម្លៃ សំដៅដល់ក្រុមហ៊ុនដែលមានសកម្មភាពធុរកិច្ចក្នុងការវាយតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។

៨-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Securities Transfer Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.គ.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការផ្ទេរមូលបត្រ។

៩-ភ្នាក់ងារទូទាត់ជំនួស (Paying Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.គ.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការទូទាត់ជំនួសឱ្យក្រុមហ៊ុនបោះផ្សាយ។

១០-មូលបត្រកម្មសិទ្ធិ សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត រួមទាំងនីតិបុគ្គលបរទេសប្រហាក់ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។

១១-មូលធនភាគហ៊ុនិក (Shareholders' Equity) សំដៅដល់មូលធនសរុបរបស់ក្រុមហ៊ុនដែលវិនិយោគដោយភាគហ៊ុនិក រួមទាំងប្រាក់ចំណេញរក្សាទុក។

១២-របាយការណ៍ហិរញ្ញវត្ថុ សំដៅដល់របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ ដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលក្នុងនោះរួមមាន របាយការណ៍របស់អភិបាល របាយការណ៍របស់សវនករឯករាជ្យ និងរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មរួច។

១៣-សិទ្ធិបរិវត្តន៍ (Conversion Rights) សំដៅដល់សិទ្ធិក្នុងការផ្ទេរពីភាគហ៊ុនបុរិមាទៅជាមូលបត្រកម្មសិទ្ធិធម្មតា។

**ប្រការ ៣.-**

សំណើលក់មូលបត្រកម្មសិទ្ធិ អាចជាសំណើលក់ជាឯកជន ឬសំណើលក់ជាសាធារណៈ។

សំណើលក់មូលបត្រកម្មសិទ្ធិដែលបំពេញលក្ខខណ្ឌដូចខាងក្រោម ត្រូវចាត់ទុកថាជាសំណើលក់មូលបត្រកម្មសិទ្ធិជាឯកជន ៖

១-សំណើលក់មូលបត្រដែលធ្វើឡើង ចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប) រូប និង

២-សំណើលក់មូលបត្រមិនត្រូវផ្សព្វផ្សាយជាសាធារណៈ ទោះបីតាមមធ្យោបាយណាក៏ដោយ រួមទាំងការផ្សព្វផ្សាយក្នុងគោលបំណងគ្រាន់តែឱ្យមកសាកសួរព័ត៌មាន ឬសុំពិគ្រោះយោបល់ អំពីការធ្វើវិនិយោគលើមូលបត្រ។

បុគ្គលដែលមានបំណងធ្វើសំណើលក់មូលបត្រជាឯកជន ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងសំណើលក់នោះមក **គ.ម.ក.** ហើយនៅពេលដែលសំណើលក់ជាឯកជននោះបានបញ្ចប់ បុគ្គលត្រូវរាយការណ៍ពីលទ្ធផលឱ្យបានឆាប់ជូន **គ.ម.ក.**។ ចំពោះបុគ្គលដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយមានសំណើធ្វើប្រតិបត្តិការដាក់លក់ជាឯកជន បុគ្គលត្រូវរាយការណ៍ពីលទ្ធផលភ្លាមជូន **គ.ម.ក.**។

សំណើលក់មូលបត្រកម្មសិទ្ធិទាំងឡាយណាដែលខុសពីលក្ខខណ្ឌខាងលើ គឺជាសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលតម្រូវឱ្យអនុវត្តតាមនីតិវិធីដូចមានចែងក្នុងច្បាប់ ក្នុងអនុក្រឹត្យ និងក្នុងប្រកាសនេះ។

## ជំពូកទី ២
## ការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

**ប្រការ ៤.-**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម ៖

១-ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៥.០០០.០០០.០០០ (ប្រាំពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

២-ត្រូវបោះផ្សាយលក់មូលបត្រកម្មសិទ្ធិយ៉ាងតិច ២០ (ម្ភៃ) ភាគរយនៃមូលធនភាគហ៊ុនិកសរុប សម្រាប់ក្រុមហ៊ុនដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០

(ម្ភៃពាន់លាន) រៀល និងត្រូវបោះផ្សាយលក់មូលបត្រកម្មសិទ្ធិយ៉ាងតិច ១៥ (ដប់ប្រាំ) ភាគរយនៃមូលធនភាគហ៊ុនិកសរុប សម្រាប់ក្រុមហ៊ុនដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ។

៣-ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ៥០០.០០០.០០០ (ប្រាំរយលាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងមានផលចំណេញសរុបសម្រាប់រយៈពេល ០៣ (បី) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយចំនួន ១.០០០.០០០.០០០ (មួយពាន់លាន) រៀល។

៤-ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

៥-ត្រូវទទួលបានការបញ្ជាក់ជាមុនដោយទីផ្សារមូលបត្រប្រតិស្រុតលើការដាក់តម្លៃមូលបត្រដែលធ្វើសំណើលក់។

## ប្រការ ៥.-

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវ ៖

១-ដាក់ពាក្យស្នើសុំតាមទម្រង់កំណត់ដោយ **គ.ម.ក.**។

២-ដាក់ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ **គ.ម.ក.**។

៣-ដាក់ឯកសារភ្ជាប់ដូចមានកំណត់ក្នុងប្រកាសនេះ។

## ប្រការ ៦.-

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវសុំការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅ **គ.ម.ក.** ដោយអនុលោមតាមមាត្រា ១២ នៃច្បាប់ និងមាត្រា ៩ មាត្រា ១០ មាត្រា ១១ និងមាត្រា ១៣ នៃអនុក្រឹត្យ។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចមានកំណត់ពីប្រការ ៧ ដល់ប្រការ ២៧ នៃប្រកាសនេះ។ ឯកសារផ្តល់ព័ត៌មានត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាលនាយកប្រតិបត្តិរបស់ក្រុមហ៊ុនបោះផ្សាយ និងនាយកហិរញ្ញវត្ថុ។

## ប្រការ ៧.-

ឯកសារផ្តល់ព័ត៌មានត្រូវមានមាតិកាដូចខាងក្រោម ៖

១-ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

២-ព័ត៌មានស្តីពីកត្តាហានិភ័យ

៣-ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

៤-ផែនការវិនិយោគ

៥-ការពិពណ៌នាអំពីធុរកិច្ច

៦-ការពិពណ៌នាអំពីអចលកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

៧-ផែនការប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ

៨-ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ

៩-ព័ត៌មានពាក់ព័ន្ធនឹងអភិបាល និងបុគ្គលិកជាន់ខ្ពស់

១០-ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

១១-ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

១២-ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

១៣-សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឱ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

១៤-ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក

១៥-ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ

១៦-កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

១៧-ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់

១៨-ការពិពណ៌នាពីមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់

១៩-ព័ត៌មានហិរញ្ញវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុ

២០-ព័ត៌មានហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុរួម។

## ប្រការ ៨.–

ករណីសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ពាក់ព័ន្ធនឹងផែនការវិនិយោគ ឬមានការពាក់ព័ន្ធនឹងផែនការវិនិយោគលើសពី ០១ (មួយ) ផែនការនីមួយៗ ត្រូវបង្ហាញដាច់ពីគ្នាជាទម្រង់ពេញលេញក្នុងឯកសារផ្តល់ព័ត៌មាន។

## ប្រការ ៩.–

ឯកសារផ្តល់ព័ត៌មាន ត្រូវមានព័ត៌មានទូទៅដូចខាងក្រោម ៖

១-ឈ្មោះក្រុមហ៊ុនដាក់ពាក្យស្នើសុំ

២-ចំនួន និងប្រភេទមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយ

៣-តម្លៃលក់មូលបត្រកម្មសិទ្ធិក្នុងមួយឯកតា និងតម្លៃសរុប

៤-ថ្ងៃបើក និងថ្ងៃបិទការធ្វើបរិវិសកម្ម

៥-ឈ្មោះ និងអាសយដ្ឋានក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញ

៦-កាលបរិច្ឆេទចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

៧-សេចក្តីបញ្ជាក់ថា "ព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលពាក់ព័ន្ធ ក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាននេះ"។

**ប្រការ ១០.-**

ឯកសារផ្តល់ព័ត៌មាន ត្រូវមានព័ត៌មានស្តីពីកត្តាហានិភ័យដូចខាងក្រោម ៖

១-ហានិភ័យអត្រាការប្រាក់

២-ហានិភ័យអត្រាប្តូរប្រាក់

៣-ហានិភ័យក្នុងវិស័យធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ

៤-ហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

៥-ហានិភ័យពាក់ព័ន្ធនឹងសកម្មភាពមិនមែនប្រតិបត្តិការធុរកិច្ចរបស់ក្រុមហ៊ុន

៦-ហានិភ័យពាក់ព័ន្ធនឹងទីផ្សារ និងបច្ចេកវិទ្យា

៧-ហានិភ័យពាក់ព័ន្ធនឹងការវិវត្តនៃបទប្បញ្ញត្តិ

៨-ហានិភ័យពាក់ព័ន្ធនឹងការវិវត្តនៃបរិការណ៍ជាតិ និងអន្តរជាតិ។

**ប្រការ ១១.-**

ឯកសារផ្តល់ព័ត៌មាន ត្រូវបង្ហាញពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីចំនួនទឹកប្រាក់ដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនីមួយៗ។

ឯកសារផ្តល់ព័ត៌មាន ត្រូវបង្ហាញពីដំណាក់កាលនានានៃការអនុវត្ត និងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

ប្រសិនបើសាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវប្រើប្រាស់ សម្រាប់ធានាចំណាយលើកិច្ចសន្យានៃសកម្មភាពណាមួយរបស់ក្រុមហ៊ុន

បោះផ្សាយ ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីរយៈពេលសុពលភាពនៃកិច្ចសន្យាទាំងនោះ និងត្រូវភ្ជាប់កិច្ចសន្យានោះជាឧបសម្ព័ន្ធរបស់ឯកសារផ្តល់ព័ត៌មានដែលស្នើសុំចុះបញ្ជីនេះ។

**ប្រការ ១២.-**

ឯកសារផ្តល់ពត៌មានត្រូវបញ្ជាក់ពីកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម និងកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការ របស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខណៈនៃធុរកិច្ចដែលក្រុមហ៊ុនបោះផ្សាយ និងសាខាក្រុមហ៊ុនបោះផ្សាយបានចូលរួម ឬនឹងចូលរួម។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ ដូចជា ៖

១-ផលិតផលដែលផាទំនិញ ឬសេវាស្នូលរបស់ក្រុមហ៊ុនបោះផ្សាយ និងទីផ្សាររបស់ផលិតផលទាំងនោះនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

២-ទំហំនៃការលក់ផលិតផលផ្សេងទៀតដែលមិនមែនជាផលិតផលស្នូល ហើយទទួលបានប្រាក់ចំណូលលើសពី ១០ (ដប់) ភាគរយនៃប្រាក់ចំណូលសរុបរបស់ក្រុមហ៊ុនបោះផ្សាយ។

៣- ឈ្មោះក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនរួមលើងរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងធុរកិច្ចស្នូលរបស់ក្រុមហ៊ុនទាំងនោះ។

៤-វិធីសាស្ត្រចែកចាយផលិតផល។

៥-ស្ថានភាពប្រកួតប្រជែងនៃធុរកិច្ចក្នុងទីផ្សារ។

៦-វត្ថុធាតុដើម ឬធាតុចូលផ្សេងៗដែលធានាដល់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងប្រភព និងអ្នកផ្គត់ផ្គង់។

៧-តម្រូវការថាមពល ឥន្ធនៈ ទឹក ឬសម្ភារៈប្រើប្រាស់ផ្សេងៗទៀតដែលចាំបាច់សម្រាប់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុន ដោយបញ្ជាក់ពីប្រភព។

៨-ឈ្មោះអតិថិជនដែលទិញផលិតផល ឬសេវារបស់ក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃផលិតផល ឬសេវាសរុប ដោយបញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើ រួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

៩-ឈ្មោះអ្នកផ្គត់ផ្គង់ដែលលក់ផលិតផល ឬផ្តល់សេវាឱ្យក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃផលិតផល ឬសេវាសរុបរបស់អ្នកផ្គត់ផ្គង់នោះ ដោយបញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើ រួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១០-ការពិពណ៌នាពីប្រកាសនីយបត្រតក្កកម្ម ម៉ាក ពាណិជ្ជនាម សិទ្ធិអាជីវកម្ម ឬកិច្ចព្រមព្រៀងផ្សេងទៀតពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិបញ្ញា។

១១-ចំនួនបុគ្គលិកសរុប និងចំនួនបុគ្គលិកធ្វើការពេញម៉ោង។

១២-សក្តានុភាពនៃសមត្ថភាពផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ និងបញ្ជាក់ពីកម្រិតសមត្ថភាពដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។

១៣-ប្រសិនបើក្រុមហ៊ុនបោះផ្សាយជាក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឯកសារផ្តល់ពត៌មានត្រូវមានព័ត៌មានពេញលេញស្តីពីប្រតិបត្តិការសំខាន់រវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីង ដោយបញ្ជាក់ពីលក្ខណៈនៃប្រតិបត្តិការ និងចំនួនទឹកប្រាក់ដែលបានធ្វើ ក្នុងរយៈពេល ០៣ (បី) ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**ប្រការ ១៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ពាក់ព័ន្ធនឹងអចលកម្ម្យបីរបស់ក្រុមហ៊ុនបោះផ្សាយ ដូចខាងក្រោម ៖

១-ទីតាំងប្រតិបត្តិការ និងទីតាំងអចលកម្ម្យបីរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខខណ្ឌនៃអចលកម្ម្យបីទាំងនោះ។

២-សេចក្តីបញ្ជាក់អំពីកម្មសិទ្ធិលើអចលកម្ម្យបីរបស់ក្រុមហ៊ុនបោះផ្សាយ។ ប្រសិនបើអចលកម្ម្យបីទាំងនោះទទួលបានមកតាមរយៈការជួល ត្រូវមានការបញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់នៃការជួល ព្រមទាំងឈ្មោះម្ចាស់អចលកម្ម្យបី។

៣-ការវាយតម្លៃលើអចលកម្ម្យបីរបស់ក្រុមហ៊ុនបោះផ្សាយធ្វើឡើងដោយភ្នាក់ងារវាយតម្លៃដែលបានចុះបញ្ជីនៅ **គ.ម.គ.** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ។

៤-ប្រសិនបើអចលកម្ម្យបីដែលក្រុមហ៊ុនបោះផ្សាយកំពុងប្រើប្រាស់ ជាប់នូវប្រាតិភោគភណ្ឌិក ក្រុមហ៊ុនបោះផ្សាយត្រូវបញ្ជាក់ពីអត្តសញ្ញាណរបស់ម្ចាស់ទ្រព្យនោះ ព្រមទាំងតម្លៃដើម និងតម្លៃបច្ចុប្បន្នរបស់ប្រាតិភោគភណ្ឌិក។

**ប្រការ ១៤.-**

នៅក្នុងឯកសារផ្តល់ព័ត៌មាន បុគ្គលដាក់ពាក្យស្នើសុំត្រូវបង្ហាញផែនការប្រតិបត្តិការសង្ខេបសម្រាប់រយៈពេល ០៣ (បី) ឆ្នាំ ដូចខាងក្រោម ៖

១-ការប៉ាន់ស្មានចំណេញភាព និងចលនាសាច់ប្រាក់រយៈពេល ១២ (ដប់ពីរ) ខែ ដែលត្រូវបានពិនិត្យឡើងវិញ និងរាយការណ៍ដោយសវនករឯករាជ្យ។

២-ការរំពឹងទុកអំពីការផ្លាស់ប្តូរបុគ្គលិកចំនួនច្រើន។

៣-ប្រភពសាច់ប្រាក់ខាងក្នុង និងខាងក្រៅ។

៤-ការចំណាយមូលធនសំខាន់ៗ និងប្រភពមូលនិធិសម្រាប់ការចំណាយនោះ។

៥-បុព្វហេតុដែលបណ្តាលឱ្យមានការប្រែប្រួលពីពេលមួយទៅពេលមួយនៃប្រាក់ចំណូល ថ្លៃដើមទំនិញដែលបានលក់ ចំណាយប្រតិបត្តិការផ្សេងៗ និងចំណេញសុទ្ធ។

៦-ទិដ្ឋភាពតាមរដូវកាលនៃធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ។

៧-និន្នាការ ព្រឹត្តិការណ៍ ឬភាពមិនប្រក្រតីណាមួយ ដែលមានផលប៉ះពាល់ខ្លាំងលើធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយក្នុងពេលអនាគត។

៨-រាល់ការផ្លាស់ប្តូរចំពោះទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយ ដែលត្រូវប្រើប្រាស់សម្រាប់ទូទាត់បំណុល។

៩-សេចក្តីបញ្ជាក់ពីកម្ចីសំខាន់ៗ រវាងក្រុមហ៊ុនហូលឌីង និងក្រុមហ៊ុនបុត្រសម្ព័ន្ធ នៅពេលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

១០-រាល់កិច្ចសន្យាពាក់ព័ន្ធនឹងបំណុលនាពេលអនាគតដែលអាចកើតមាន និងផលប៉ះពាល់នៃបំណុលនោះលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ។

១១-ចំណាយមូលធនប៉ាន់ស្មាន។

១២-រាល់អាករលើតម្លៃបន្ថែម ពន្ធលើប្រាក់ចំណេញ ពន្ធគយ ឬបំណុលពន្ធផ្សេងៗ ដែលមិនទាន់បានទូទាត់ រួមទាំងបំណុលជាយថាហេតុ ដោយបញ្ជាក់ពីមូលហេតុនៃការមិនទាន់បានទូទាត់មុនពេលចេញផ្សាយឯកសារផ្តល់ព័ត៌មាន។

១៣-សេចក្តីលម្អិតអំពីភតិសន្យាប្រតិបត្តិការសំខាន់ ដែលក្រុមហ៊ុនបោះផ្សាយបានចុះកិច្ចសន្យា ដោយបញ្ជាក់ឱ្យបានច្បាស់នូវលក្ខខណ្ឌនៃភតិសន្យា។

១៤-សេចក្តីលម្អិតអំពីបញ្ញត្តិនានាពាក់ព័ន្ធនឹងបុគ្គលិកក្រុមហ៊ុនបោះផ្សាយ។

១៥-សេចក្តីលម្អិតអំពីចំណាយទាំងអស់ ដែលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយបង្ហាញជាពិសេសនូវកម្រៃសម្រាប់ក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញមូលបត្រ។

១៦-របាយការណ៍របស់សវនករពាក់ព័ន្ធនឹងគោលនយោបាយលើកទឹកចិត្តរបស់ក្រុមហ៊ុនបោះផ្សាយតាមរយៈការបែងចែកជាមូលបត្រកម្មសិទ្ធិ តម្លៃតបស្នង ឬជាសាច់ប្រាក់ដូចមានកំណត់ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។

**ប្រការ ១៥.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ស្តីពីការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ។ ក្រុមហ៊ុនបោះផ្សាយត្រូវបង្ហាញឈ្មោះ គុណវុឌ្ឍិរបស់ភ្នាក់ងារវាយតម្លៃ និងហេតុផលនៃការវាយតម្លៃ ឬការវាយតម្លៃឡើងវិញ ដោយបង្ហាញពីតម្លៃទ្រព្យសកម្មមុនពេលធ្វើការវាយតម្លៃឡើងវិញ សមាសធាតុនៃទ្រព្យដែលបានវាយតម្លៃឡើងវិញ ត្រូវដាក់ដោយឡែកក្នុងលក្ខណៈមួយដែលជួយសម្រួលដល់ការប្រៀបធៀបរវាងតម្លៃចាស់ និងតម្លៃដែលបង្ហាញក្រោយពីបានវាយតម្លៃឡើងវិញ និងត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ។

**ប្រការ ១៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីអភិបាល និងបុគ្គលិកជាន់ខ្ពស់ ដូចខាងក្រោម ៖

១-ជីវប្រវត្តិសង្ខេប ដោយមានបញ្ជាក់ពីឈ្មោះ អាយុ គុណវុឌ្ឍិ បទពិសោធន៍ និងតំណែងរបស់អភិបាលម្នាក់ៗរបស់ក្រុមហ៊ុនបោះផ្សាយ និងបុគ្គលដែលត្រូវបានតែងតាំងជាអភិបាល ដោយបង្ហាញពីអាណត្តិនៃការតែងតាំង និងស្ថាប័នដែលបានតែងតាំងអភិបាលនោះ។

២-កាលបរិច្ឆេទក្លាយជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយជាលើកដំបូង និងកាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន។

៣-ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត ត្រូវបង្ហាញឈ្មោះក្រុមហ៊ុនពាក់ព័ន្ធទាំងនោះ។

៤-ទំនាក់ទំនងសាច់ញាតិ ក្នុងចំណោមអភិបាល និងបុគ្គលិកជាន់ខ្ពស់។

៥-សេចក្តីបញ្ជាក់អំពីអសាធនភាពរបស់ភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅ ប្រសិនបើមាន។

៦-ឈ្មោះ រួមទាំងតំណែង គុណវុឌ្ឍិអប់រំ កាលបរិច្ឆេទចូលរួមជាមួយក្រុមហ៊ុនបោះផ្សាយ បទពិសោធន៍ ០៥ (ប្រាំ) ឆ្នាំចុងក្រោយរបស់អគ្គនាយក អគ្គនាយករង នាយកប្រតិបត្តិ នាយកហិរញ្ញវត្ថុ លេខាធិការក្រុមហ៊ុន អ្នកប្រឹក្សាយោបល់ និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

ឯកសារដូចខាងក្រោម ត្រូវភ្ជាប់ទៅក្នុងឯកសារផ្តល់ព័ត៌មាន ៖

១-ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ។

២-របាយការណ៍របស់អភិបាលស្តីពីការវាយតម្លៃស្ថានភាពរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញទូវព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងរយៈពេល ១០ (ដប់) ឆ្នាំចុងក្រោយ ដូចខាងក្រោម ៖

១-បណ្តឹងពាក់ព័ន្ធនឹងក្ស័យធន ធ្វើឡើងចំពោះក្រុមហ៊ុនដែលបុគ្គលិកជាន់ខ្ពស់ ឬអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់ជាអភិបាល បុគ្គលិក ឬជាសហកម្មសិទ្ធិករ។

២-ការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬកំពុងស្ថិតនៅក្នុងនីតិវិធីតុលាការចំពោះអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៣-ការសម្រេចជាស្ថាពរ ឬជាបណ្តោះអាសន្នរបស់តុលាការមានសមត្ថកិច្ច ចំពោះអភិបាល បុគ្គលិកជាន់ខ្ពស់ ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយល្បួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះ នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

៤-ការសម្រេចរបស់គណៈកម្មការមូលបត្រកម្ពុជា ឬគណៈកម្មការមូលបត្របរទេស ឬនិយ័តករនៃវិស័យផ្សេងទៀត ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយល្បួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

**ប្រការ ១៨.-**

ឯកសារផ្តល់ព័ត៌មានត្រូវពិពណ៌នាអំពីប្រតិបត្តិការសំខាន់ៗ ក្នុងរយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ ដោយផ្តល់ឈ្មោះ ទំនាក់ទំនង ទំហំ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងរវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងបុគ្គលជាប់ពាក់ព័ន្ធដូចខាងក្រោម ៖

១-អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាមួយ។

២-បុគ្គលដែលមានភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរនៅក្នុងទីផ្សារ។

៣-សមាជិកគ្រួសារផ្ទាល់ (រួមមាន ប្តី ប្រពន្ធ កូន ឪពុកម្តាយ បងប្អូនប្រុស ឬបងប្អូនស្រី) របស់បុគ្គលដែលចែងក្នុងចំណុចទី ១ និងទី ២ ខាងលើ។

៤-បុគ្គលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហ្វូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនេះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយ ដែលបានធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ។

៥-បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងកើតឡើងក្នុងក្របខ័ណ្ឌប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៦-អភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីក្រុមហ៊ុនបោះផ្សាយ។

៧-អភិបាលដែលទទួលបានផលប្រយោជន៍ពីក្រុមហ៊ុនបោះផ្សាយ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ។

**ប្រការ ១៩.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដូចខាងក្រោម ៖

១-ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបានបើកឱ្យបុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ០៥ (ប្រាំ) រូបរបស់ក្រុមហ៊ុនបោះផ្សាយ នៅឆ្នាំសារពើពន្ធចុងក្រោយ ដោយមានរាយនាម និងមុខតំណែងរបស់បុគ្គលិកជាន់ខ្ពស់បំផុតនោះ។

២-ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបើកឱ្យអភិបាលមិនប្រតិបត្តិ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៣-ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៤-ចំនួនប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៥-ប្រសិនបើក្រុមហ៊ុនបោះផ្សាយមានបំណងបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិករបស់ក្រុមហ៊ុន នៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធក្នុងការបង្កើននោះ។

**ប្រការ ២០.-**

ព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិទិញមូលបត្រកម្មសិទ្ធិរបស់អភិបាល ឬបុគ្គលិក ត្រូវមាននៅក្នុងឯកសារផ្តល់ព័ត៌មាន ដោយត្រូវបញ្ជាក់នូវ ៖

១-កាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

២-ថ្ងៃនៃមូលបត្រដែលត្រូវអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៣-ចំនួនមូលបត្រកម្មសិទ្ធិដែលពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៤-ថ្ងៃទីផ្សាររបស់មូលបត្រកម្មសិទ្ធិនៅកាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

៥-កាលបរិច្ឆេទអស់សុពលភាពនៃសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

**ប្រការ ២១.-**

ករណីក្រុមហ៊ុនបោះផ្សាយមានប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក ក្រុមហ៊ុនបោះផ្សាយត្រូវពិពណ៌នាក្នុងឯកសារផ្តល់ព័ត៌មាន នូវឈ្មោះរបស់អភិបាល និងភាគហ៊ុនិក ប្រភេទនិងតម្លៃនៃទ្រព្យសកម្ម សេវាកម្ម ប្រាក់បំណាច់ ឬលាភការដែលបានទទួល ឬផ្តល់ឱ្យក្រុមហ៊ុនបោះផ្សាយ ដោយផ្ទាល់ ឬដោយប្រយោល ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយ។

ប្រសិនបើក្រុមហ៊ុនបោះផ្សាយបានទិញ ឬនឹងទិញចលនទ្រព្យ និងអចលនទ្រព្យពីអភិបាល ឬភាគហ៊ុនិក ឯកសារផ្តល់ព័ត៌មានត្រូវមានបញ្ជាក់ពីវិធីសាស្ត្រនៃការកំណត់ថ្លៃ និងចំនួនទឹកប្រាក់ទូទាត់។

**ប្រការ ២២.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមុន និងក្រោយការបោះផ្សាយ និងប្រាក់ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់ នៅកាលបរិច្ឆេទនៃតារាងតុល្យការចុងក្រោយ។

**ប្រការ ២៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញក្រោមទម្រង់ជាតារាង នូវឈ្មោះរបស់បុគ្គលដែលកាន់កាប់ចាប់ពី ០៥ (ប្រាំ) ភាគរយនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ដោយត្រូវបញ្ជាក់ពីចំនួន និងភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់។

ឯកសារផ្តល់ព័ត៌មានត្រូវមានតារាងដែលបង្ហាញពីចំនួនមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ដោយអភិបាលម្នាក់ៗ បុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ០៥ (ប្រាំ) រូប ដោយបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់ពួកគេ

គេម្នាក់ៗ ព្រមទាំងបុគ្គលិកផ្សេងទៀត ក្រោមរូបភាពជាសរុប ដោយត្រូវបញ្ជាក់ជាភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់ធៀបនឹងចំនួនមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរនៅលើទីផ្សារ។

**ប្រការ ២៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានការកំណត់នូវកត្តាដែលយកមកប្រើប្រាស់ ក្នុងការដាក់តម្លៃមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់ជាសាធារណៈ។

ប្រសិនបើថ្លៃលក់មូលបត្រកម្មសិទ្ធិខ្ពស់ជាងតម្លៃចារឹក ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញនូវអំណះអំណាងអំពីប្រាក់បង់លើស ដោយផ្អែកលើ ÷

១-តម្លៃទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ ដោយឈរលើមូលដ្ឋានថ្លៃដើមប្រវត្តិសាស្រ្ត (Historical Cost) ឬថ្លៃដើមបច្ចុប្បន្ន (Current Cost)។

២-តម្លៃចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ ដែលគណនាដោយឈរលើមូលដ្ឋាននៃមធ្យមទម្ងន់នៃប្រាក់ចំណេញសុទ្ធក្រោយការបង់ពន្ធរយៈពេល ០៣ (បី) ឆ្នាំចុងក្រោយបន្តបន្ទាប់គ្នា ឬរយៈពេលខ្លីជាងនេះ ដោយគិតពីពេលចាប់ផ្តើមធ្វើប្រតិបត្តិការពាណិជ្ជកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៣-តម្លៃចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលប៉ាន់ស្មាន សម្រាប់រយៈពេល ០៣ (បី) ឆ្នាំនៃឆ្នាំសារពើពន្ធខាងមុខ ដោយឈរលើមូលដ្ឋានចំណេញប៉ាន់ស្មាន។ ការព្យាករណ៍ត្រូវតែធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ ហើយត្រូវពិនិត្យឡើងវិញ និងរាយការណ៍ ដោយសវនករឯករាជ្យ។

៤-តម្លៃក្នុងមួយឯកតាគិតជាមធ្យមក្នុងទីផ្សារនៃមូលបត្រកម្មសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាសម្រាប់រយៈពេល ០៦ (ប្រាំមួយ) ខែមុនការធ្វើសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ឬតម្លៃក្នុងមួយឯកតាគិតជាមធ្យមក្នុងទីផ្សារនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែដូចគ្នា ក្នុងករណីការបោះផ្សាយនោះជាសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈឡើងវិញ។

៥-កត្តាផ្សេងទៀតដោយបញ្ជាក់អំណះអំណាងថាក្រុមហ៊ុនបោះផ្សាយធ្លាប់បានយកមកប្រើសម្រាប់កំណត់ប្រាក់បង់លើស។

៦-គំរូផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.** ក្នុងការគណនាតម្លៃក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។

**ប្រការ ២៥.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធទៅនឹងសិទ្ធិផ្សេងៗភ្ជាប់ជាមួយមូលបត្រកម្មសិទ្ធិដែលជាកម្មវត្ថុនៃសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដូចខាងក្រោម ÷

១-ពិពណ៌នាពីសិទ្ធិទទួលភាគលាភ និងសិទ្ធិបោះឆ្នោតនៃមូលបត្រកម្មសិទ្ធិដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

២-ពិពណ៌នាពីសិទ្ធិទទួលភាគលាភ សិទ្ធិបោះឆ្នោត សិទ្ធិបរិវត្តន៍ និងសិទ្ធិជំរះបញ្ជី ព្រមទាំងមូលនិធិសម្រាប់ទូទាត់សងភាគហ៊ុនបុរិមាដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

៣-ប្រសិនបើមានការដាក់កំហិតណាមួយលើការបង់ភាគលាភទៅឱ្យអ្នកកាន់កាប់មូលបត្រកម្មសិទ្ធិដោយសារកិច្ចសន្យាបំណុលពាក់ព័ន្ធ ត្រូវពន្យល់ពីការដាក់កំហិតនោះ។

៤-ពិពណ៌នាពីសិទ្ធិសំខាន់ផ្សេងៗទៀតរបស់អ្នកកាន់កាប់មូលបត្រកម្មសិទ្ធិ។

**ប្រការ ២៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និងព័ត៌មានហិរញ្ញវត្ថុព្យាករណ៍ ដែលបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.** ហើយត្រូវភ្ជាប់របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំ និងធ្វើសវនកម្ម ស្របទៅតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្ម គណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ សម្រាប់រយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ។

**ប្រការ ២៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម និងព័ត៌មានហិរញ្ញវត្ថុព្យាករណ៍រួម ដែលបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.** ហើយត្រូវភ្ជាប់មករបាយការណ៍ហិរញ្ញវត្ថុរួមដែលរៀបចំ និងធ្វើសវនកម្ម ស្របតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្ម គណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ សម្រាប់រយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ។

**ប្រការ ២៨.-**

អនុលោមតាមមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យ អ្នកជំនាញ ឬភាគីពាក់ព័ន្ធដែលបានផ្តល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរលើសេចក្តីថ្លែង ឬរបាយការណ៍ ឬ

យោបល់ឱ្យធ្វើការផ្សព្វផ្សាយនៅក្នុងឯកសារផ្ដល់ព័ត៌មាន ត្រូវទទួលខុសត្រូវលើសេចក្ដីថ្លែងរបាយការណ៍ ឬយោបល់ដែលបានផ្ដល់ឱ្យនោះ។

**ប្រការ ២៩.-**

ក្រុមហ៊ុនបោះផ្សាយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះភាពត្រឹមត្រូវ ភាពគ្រប់គ្រាន់ និងភាពអាចជឿជាក់បាន នូវរាល់ព័ត៌មានដែលបានបង្ហាញនៅក្នុងឯកសារផ្ដល់ព័ត៌មាន។

ក្រុមហ៊ុនមូលបត្រ និងបុគ្គលពាក់ព័ន្ធដទៃទៀត ដែលផ្ដល់យោបល់ ឬព័ត៌មាន និងចូលរួមក្នុងការរៀបចំឯកសារផ្ដល់ព័ត៌មានត្រូវទទួលខុសត្រូវចំពោះយោបល់ ឬព័ត៌មាន និងការចូលរួមនោះ។

**ប្រការ ៣០.-**

បុគ្គលដាក់ពាក្យស្នើសុំត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំ នូវឯកសារដូចខាងក្រោម ÷

១-លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។

២-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។

៣-សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៤-លិខិតប្រគល់សិទ្ធិដោយមានបញ្ជាក់ពីតួនាទី និងភារកិច្ចជាអភិបាល ឬនាយកប្រតិបត្តិ ក្នុងការបម្រើការងារនៅក្នុងក្រុមហ៊ុនបោះផ្សាយ ដោយមានការចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

៥-កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗដែលមាន។

៦-លិខិតបញ្ជាក់ពីធនាគារពាណិជ្ជស្ដីពីការបើកគណនីដាច់ដោយឡែក សម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៧-កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

៨-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence Report) ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

៩-លិខិតបញ្ជាក់ពីកិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។

១០-លិខិតបញ្ជាក់ពីកិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

១១-លិខិតបញ្ជាក់ពីកិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់ជំនួស។

១២-កិច្ចព្រមព្រៀងសំខាន់ៗវិនិយោគចម្រុះ ប្រសិនបើមាន។

១៣-លិខិតបញ្ជាក់ពីធនាគារពាណិជ្ជ ឬលិខិតបញ្ជាក់ពីសវនករនូវចំនួនទឹកប្រាក់តម្កល់សម្រាប់ធ្វើជាមូលធន។

១៤-របាយការណ៍អនុសាសន៍ស្ដីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់សវនករឯករាជ្យដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.គ.**។

១៥-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យចេញដោយក្រុមហ៊ុនគណនេយ្យករជំនាញដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.គ.**។

១៦-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.គ.**។

**ប្រការ ៣១.-**

អគ្គនាយកនៃ **គ.ម.គ.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំ ពីការមិនយល់ព្រម ឬការយល់ព្រមជាគោលការណ៍ លើការចុះបញ្ជីឯកសារផ្ដល់ព័ត៌មានក្នុងរយៈពេល ០២ (ពីរ) ខែគិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។

**ប្រការ ៣២.-**

អគ្គនាយកនៃ **គ.ម.គ.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំ ផ្ដល់ព័ត៌មានបន្ថែម ឬព័ត៌មានជំនួស ឬសេចក្ដីបញ្ជាក់ ឬសេចក្ដីបំភ្លឺ។ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញតាមសំណើនេះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ឬក្នុងរយៈពេលជាក់លាក់ណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.គ.** គិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ករណីបុគ្គលដាក់ពាក្យស្នើសុំមិនបំពេញបានទៅតាមសំណើខាងលើ អគ្គនាយកនៃ **គ.ម.គ.** អាចចាត់វិធានការទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៣៣.-**

អគ្គនាយកនៃ **គ.ម.គ.** អាចបដិសេធលើសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់បុគ្គលដាក់ពាក្យស្នើសុំដោយផ្អែកលើមូលហេតុដូចខាងក្រោម ៖

១-បុគ្គលដាក់ពាក្យសុំមិនបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

២-ព័ត៌មាន ឬឯកសារដែលបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

៣-បុគ្គលដាក់ពាក្យស្នើសុំស្ថិតនៅក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ធុរកិច្ច ឬការរំលាយ។

៤-ការមិនអនុវត្តតាមទាំងស្រុង ឬមួយផ្នែក នូវសេចក្ដីសម្រេចរបស់តុលាការដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុល។

៥-បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ ៖

ក-មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ ស្របតាមអនុក្រឹត្យ។

ខ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្ដីសម្រេចរបស់ខ្លួន។

គ-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្ដីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាត ប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ ឬយុត្តិធម៌។

៦-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់កាន់មុខតំណែងទាំងនេះនៅក្នុងក្រុមហ៊ុនដែលត្រូវបានប្រកាសក្ស័យធន នៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-ស្ថានភាពហិរញ្ញវត្ថុ ឬវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ មិនទាន់មានលក្ខណៈគ្រប់គ្រាន់ ដើម្បីធានានូវដំណើរការនៃធុរកិច្ចប្រកបដោយចីរភាព និងភាពទុកចិត្ត។

៨-នៅពេលកើតមានហេតុការណ៍ណាមួយដែលនាំឱ្យ ៖

ក-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ មិនអាចដំណើរការអាជីវកម្មបានត្រឹមត្រូវ។

ខ-មានភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ។

ង-ការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំ នឹងនាំឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ដោយត្រូវពិចារណាលើលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់។

## ជំពូកទី ៣
## ការដាក់លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

### ប្រការ ៣៤.-

បុគ្គលដាក់ពាក្យស្នើសុំដែលទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចចាប់ផ្តើមធ្វើសំណើលក់មូលបត្រជាសាធារណៈបាន បន្ទាប់ពី ៖

១-បានរៀបចំលក្ខខណ្ឌនៃសំណើលក់ រួមទាំងការកំណត់ថ្លៃលក់មូលបត្រដែលការកំណត់ថ្លៃលក់មូលបត្រនេះត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ។

២-បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចក្នុងចំណុចទី ១ ខាងលើ ពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១២ នៃអនុក្រឹត្យ។

៣-បានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានរបស់បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅ **គ.ម.ក.**។

### ប្រការ ៣៥.-

បន្ទាប់ពីបានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព សម្រាប់រយៈពេលដូចកំណត់ក្នុងចំណុចទី ៣ នៃមាត្រា ៧ នៃអនុក្រឹត្យ។ នៅពេលការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ពេញលេញ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីអំពីការធ្វើបរិវិសកម្មនោះភ្លាមមក **គ.ម.ក.**។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលមានអាជ្ញាបណ្ណពី **គ.ម.ក.** ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យ។ ក្រុមហ៊ុនមូលបត្រត្រូវស្នើសុំ

ទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែក នៅធនាគារពាណិជ្ជដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យ។ ចំនួន និងបញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវកំណត់ដោយ **គ.ម.ក.**។ ការធ្វើបរិវិសកម្មនីមួយៗ ត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មបានបំពេញត្រឹមត្រូវ តាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្ម បានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែករណីដូចមានចែងក្នុងចំណុចទី ៤ "ខ" នៃមាត្រា ៧ និងចំណុចទី ២ នៃមាត្រា ១៨ នៃអនុក្រឹត្យ និងប្រការ ៣៩ និងប្រការ ៤០ នៃប្រកាសនេះ។

**ប្រការ ៣៦.-**

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្ម ករណីមូលបត្រកម្មសិទ្ធិធ្វើបរិវិសកម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់នោះ និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចដែលមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យ ឱ្យក្រុមហ៊ុនបោះផ្សាយក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់ មក **គ.ម.ក.** ភ្លាម។

**ប្រការ ៣៧.-**

ការធ្វើបរិវិសកម្មត្រូវបានកំណត់ដូចខាងក្រោម ÷

១-២០ (ម្ភៃ) ភាគរយនៃសំណើលក់ជាសាធារណៈសរុប ត្រូវបានបម្រុងសម្រាប់អ្នកវិនិយោគសញ្ជាតិខ្មែរ។

២-៨០ (ប៉ែតសិប) ភាគរយដែលនៅសល់ ត្រូវបើកចំហចំពោះអ្នកវិនិយោគសញ្ជាតិខ្មែរ និងអ្នកវិនិយោគមិនមែនសញ្ជាតិខ្មែរ។

ករណីការធ្វើបរិវិសកម្មមិនអាចសម្រេចបានតាមការកំណត់ខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចធ្វើការកំណត់នូវការបែងចែកឡើងវិញ ដើម្បីធានាភាពជោគជ័យនៃសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៣៨.-**

ក្រុមហ៊ុនមូលបត្រ ត្រូវចែកចាយលក់មូលបត្រកម្មសិទ្ធិក្នុងថ្ងៃដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ **គ.ម.ក.**។

ក្រុមហ៊ុនបោះផ្សាយ ភ្នាក់ងារបញ្ជិកាមូលបត្រ ឬក្រុមហ៊ុនមូលបត្រ ត្រូវបញ្ជូនមូលបត្រកម្មសិទ្ធិ ឬវិញ្ញាបនបត្រមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្មក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្ម។

**ប្រការ ៣៩.-**

អនុលោមតាមមាត្រា ២១ នៃច្បាប់ ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចអាចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក.**។ ករណីនេះ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ឈប់ទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រ និងជូនដំណឹងអំពីការព្យួរនេះភ្លាមដល់អ្នកធ្វើបរិវិសកម្ម និងសាធារណជន។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រត្រូវបញ្ជាក់ជូនអ្នកធ្វើបរិវិសកម្មថាអាចមានសិទ្ធិដកស្ទីការដែលបានធ្វើ ចំពោះសំណើលក់ជាសាធារណៈ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ អាចបន្តទទួលពាក្យស្នើសុំធ្វើបរិវិសកម្មឡើងវិញ បន្ទាប់ពីបញ្ហាដែលបណ្តាលឱ្យមានការព្យួរត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤០.-**

ក្រុមហ៊ុនបោះផ្សាយត្រូវផ្សព្វផ្សាយភ្លាមៗអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មានដល់សាធារណជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបញ្ជាក់នូវចំណុចដូចខាងក្រោម ÷

១-លេខសេរី និងកាលបរិច្ឆេទនៃការសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

២-មូលហេតុនៃការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៣-ពេលវេលា ទីកន្លែង និងរបៀបទូទាត់នៃការបង្វិលប្រាក់សងដល់អ្នកបានធ្វើបរិវិសកម្មដែលបានបង់ ឬបានតម្កល់សម្រាប់ការធ្វើបរិវិសកម្ម។ ពេលវេលានៃការបង្វិលសងនេះ ត្រូវធ្វើឡើងយ៉ាងយូរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៤-ព័ត៌មានផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤១.-**

ការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន អាចត្រូវបានលុបចោលផងដែរ ក្នុងករណីដែលការធ្វើបរិវិសកម្មមិនបានជោគជ័យ ឬនៅពេលក្រុមហ៊ុនបោះផ្សាយមិនអាចបញ្ចប់ការចែកចាយមូលបត្រកម្មសិទ្ធិអស់ តាមពេលកំណត់ដូចមានចែងក្នុងប្រកាសនេះ។

**ប្រការ ៤២.-**

ក្រុមហ៊ុនបោះផ្សាយត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលត្រូវធ្វើឡើងក្នុងទម្រង់ដែលកំណត់ដោយ **គ.ម.ក.** ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជ អំពីចំនួនទឹកប្រាក់នៅក្នុងគណនីដោយឡែកដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះ។

**ប្រការ ៤៣.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមូលបត្រកម្មសិទ្ធិ ឬវិញ្ញាបនបត្រមូលបត្រកម្មសិទ្ធិត្រូវបានបញ្ជូនទៅអ្នកធ្វើបរិវិសកម្ម ដូចមានកំណត់ក្នុងប្រការ ៣៩ នៃប្រកាសនេះដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៤.-**

ក្រុមហ៊ុនបោះផ្សាយ ត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចដូចមានចែងក្នុងជំពូកទី ៦ នៃច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

## ជំពូកទី ៤
## ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ

**ប្រការ ៤៥.-**

ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាន ឬការផ្សព្វផ្សាយសេចក្តីថ្លែងទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យ និងត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១៥ នៃអនុក្រឹត្យ។

ក្រុមហ៊ុនបោះផ្សាយត្រូវតែរៀបចំឯកសារផ្តល់ព័ត៌មាន ដើម្បីត្រៀមទុកផ្តល់ឱ្យសាធារណជន នៅក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ប្រតិបត្តិករទីផ្សារមូលបត្រ និងនៅ **គ.ម.ក.** ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបានការយល់ព្រមពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤៦.-**

រយៈពេលយ៉ាងតិច ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្តើមធ្វើបរិវិសកម្ម ក្រុមហ៊ុនបោះផ្សាយត្រូវជូនដំណឹងជាផ្លូវការ តាមរយៈសារព័ត៌មាន និងឧបករណ៍ផ្សព្វផ្សាយដែលទទួលស្គាល់ដោយអគ្គនាយកនៃ **គ.ម.ក.** ដោយបញ្ជាក់នូវព័ត៌មានដូចខាងក្រោម ៖

១-ឈ្មោះ និងប្រទេស ឬស្ថាប័នផ្សេងៗទៀត របស់ក្រុមហ៊ុនបោះផ្សាយ។

២-ចំនួន និងឈ្មោះមូលបត្រកម្មសិទ្ធិដែលនឹងត្រូវធ្វើសំណើលក់។

៣-ទីកន្លែងដែលសាធារណជនអាចទទួលបានឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម។

៤-កាលបរិច្ឆេទនៃការផ្សព្វផ្សាយជាសាធារណៈនៃការជូនដំណឹងអំពីការធ្វើបរិវិសកម្មជាផ្លូវការ។

៥-សេចក្តីថ្លែង ដើម្បីឱ្យសាធារណជនដឹងថាសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិត្រូវបានទទួលការយល់ព្រមជាគោលការណ៍ពី **គ.ម.ក.** រួចហើយ។

៦-សេចក្តីថ្លែង ដើម្បីឱ្យសាធារណជនដឹងថាការជូនដំណឹងជាផ្លូវការនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ មិនមែនដើម្បីអញ្ជើញឱ្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិឡើយ។

៧-កាលបរិច្ឆេទដែលការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ នឹងចាប់ផ្តើម។

៨-សេចក្តីថ្លែងដែលបញ្ជាក់ថាអ្នកដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ត្រូវពិចារណា ដោយផ្អែកទៅលើឯកសារផ្តល់ព័ត៌មាន។

ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មដែលត្រូវផ្សព្វផ្សាយ ត្រូវធ្វើឡើងក្នុងទម្រង់បោះពុម្ព។ បន្ថែមលើនេះ ក្រុមហ៊ុនបោះផ្សាយអាចផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិក ប៉ុន្តែក្រុមហ៊ុនបោះផ្សាយត្រូវរក្សាខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិកឱ្យដូចគ្នានឹងឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់បោះពុម្ព។

## ជំពូកទី ៥
## កម្រៃសេវាក្នុងការចុះបញ្ជី

**ប្រការ ៤៧.-**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សានិងចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន នៅពេលដាក់ពាក្យស្នើសុំឱ្យ **គ.ម.ក.** ដូចខាងក្រោម ÷

១-ជាសាច់ប្រាក់ចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ។

២-ជាសាច់ប្រាក់ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម។

**ប្រការ ៤៨.-**

បុគ្គលដាក់ពាក្យស្នើសុំធ្វើការពិនិត្យ និងចុះបញ្ជីឯកសារផ្ដល់ព័ត៌មានបន្ថែម ត្រូវបង់សោហ៊ុយ សម្រាប់ការពិនិត្យ និងចុះបញ្ជីឯកសារផ្ដល់ព័ត៌មានបន្ថែម នៅពេលដាក់ពាក្យស្នើសុំ ឱ្យ **គ.ម.ក.** ដូចខាងក្រោម ÷

១-ជាសាច់ប្រាក់ចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ។

២-ជាសាច់ប្រាក់ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ករណីសំណើបោះផ្សាយ-លក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម។

**ប្រការ ៤៩.-**

បុគ្គលដាក់ពាក្យស្នើសុំដែលមានបំណងឱ្យ **គ.ម.ក.** ធ្វើការពិនិត្យឡើងវិញចំពោះសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលអស់សុពលភាព ត្រូវបង់សោហ៊ុយពិនិត្យឡើងវិញ នៅពេលដាក់ពាក្យស្នើសុំ ឱ្យ **គ.ម.ក.** ដូចខាងក្រោម ÷

១-ជាសាច់ប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ។

២-ជាសាច់ប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម។

**ប្រការ ៥០.-**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយដូចមានចែងក្នុងប្រការ ៤៧ ប្រការ ៤៨ និងប្រការ ៤៩ នៃប្រកាសនេះ មិនត្រូវបានប្រគល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះជាឯកសារផ្តល់ព័ត៌មានទទួលបានការអនុញ្ញាត និងចុះបញ្ជី ឬត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**ប្រការ ៥១.-**

បុគ្គលដែលបំពានលើបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម ÷

១-ការស្នើឱ្យដាក់អនុស្សារណៈ។

២-ការព្រមាន ឬការដាស់តឿន។

៣-ការកត់សម្គាល់ជាសាធារណៈ ហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤-ការដាក់កំហិតលើការបោះផ្សាយមូលបត្រកម្មសិទ្ធិ។

៥-ការផ្តល់អនុសាសន៍លើការបណ្តេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៦-ការប្រកាសជាសាធារណៈនូវទណ្ឌកម្មរបស់បុគ្គលដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧-ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ឬការចែកចាយបន្ទាប់។

**ប្រការ ៥២.-**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ឬក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញមូលបត្រ ឬអ្នកជំនាញ ឬភាគីពាក់ព័ន្ធ ដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ៥៣.-**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំ ដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

**ប្រការ ៥៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥៥.-**

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០

គាត ឈន់

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
 នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងយុត្តិធម៌
-ធនាគារជាតិនៃកម្ពុជា
-គណៈកម្មការមូលបត្រកម្ពុជា
 "ដើម្បីជូនជ្រាប"
-ដូចប្រការ ៥៥
 "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ: ០០៧/១៨ គ.ម.ក./ប្រ.ក.

# ប្រកាស

## ស្តីពី

## ការបង្ហាញព័ត៌មានសាជីវកម្ម

* * * * *

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622
Website : www.secc.gov.kh

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-** គោលបំណង

ប្រកាសនេះមានគោលបំណងធានាឱ្យបាននូវប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្នុងការបង្ហាញព័ត៌មានសាជីវកម្ម ដើម្បីការពារផលប្រយោជន៍របស់វិនិយោគិន។

**ប្រការ ២.-** គោលដៅ

ប្រកាសនេះមានគោលដៅកំណត់ពីលក្ខខណ្ឌតម្រូវ យន្តការ នីតិវិធី និងកាតព្វកិច្ចរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ និងបុគ្គលពាក់ព័ន្ធក្នុងការបង្ហាញព័ត៌មានសាជីវកម្ម ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**ប្រការ ៣.-** វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រ និងបុគ្គលពាក់ព័ន្ធក្នុងការផ្តល់ព័ត៌មាននិងរបាយការណ៍ដែលត្រូវបង្ហាញ។ បុគ្គលចុះបញ្ជីលក់មូលបត្រក្នុងប្រកាសនេះ សំដៅដល់បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ឬមូលបត្របំណុល លើកលែងបុគ្គលចុះបញ្ជីលក់នីប៉ូស៊ីតធើរីរីស៊ីប។

**ប្រការ ៤.-** និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន÷

១-ការផ្ទេរទ្រព្យសកម្ម (Asset Transfer) សំដៅដល់ការផ្លាស់ប្តូរភាពជាម្ចាស់កម្មសិទ្ធិនៃទ្រព្យសកម្ម។

២-ការទិញមូលបត្រកម្មសិទ្ធិមកវិញ (Stock Buy-Back) សំដៅដល់ការទិញមូលបត្រកម្មសិទ្ធិដែលកំពុងចរាចរលើទីផ្សារមូលបត្រ (Outstanding Equity Securities) ត្រឡប់មកវិញ ដោយបុគ្គលចុះបញ្ជីលក់មូលបត្រ។

៣-ការរំលាយក្រុមហ៊ុនបញ្ចូលគ្នានិងការទិញយក (Merger & Acquisition) សំដៅដល់យុទ្ធសាស្ត្ររបស់បុគ្គលចុះបញ្ជីលក់មូលបត្រក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងទិញលក់ ក្នុងគោលបំណងសម្រេចបានកំណើនឆាប់រហ័ស ឬក្នុងគោលបំណងជាក់លាក់ផ្សេងទៀត។

៤-ការទទួលកាន់កាប់បន្ត (Takeover) សំដៅដល់ការសម្រេចបាននូវការទិញមូលបត្រកម្មសិទ្ធិ ការទិញធុរកិច្ច ឬទ្រព្យសកម្មរបស់នីតិបុគ្គលណាមួយ ដើម្បីគ្រប់គ្រង និងកាន់កាប់នីតិបុគ្គលនោះ។

៥-ឌីប៉ូស៊ីតធើរីរីស៊ីប (Depositary Receipts) សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលតំណាងឱ្យមូល-បត្រ របស់បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលត្រូវបានដាក់ឱ្យជួញដូរនៅក្នុងទីផ្សារមូលបត្រប្រតិស្រុតបរទេស។

៦-ព័ត៌មានសាជីវកម្ម (Corporate Disclosure) សំដៅដល់ឯកសារផ្តល់ព័ត៌មានជាប្រចាំដូចមានចែងក្នុងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

៧-ព័ត៌មានទាន់ពេល (Timely Disclosure) សំដៅដល់ព័ត៌មានទាំងឡាយណាដែលអាចមានផលប៉ះពាល់ដល់ថ្លៃ ឬការជួញដូរមូលបត្ររបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ហើយនៅពេលដែលព័ត៌មានទាំងនោះកើតមានឡើង បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវធ្វើការបង្ហាញព័ត៌មាននោះភ្លាម។

៨-ម៉ោងជួញដូរ (Trading Hours) សំដៅដល់ម៉ោងដែលអនុញ្ញាតឱ្យមានការជួញដូរនៅលើទីផ្សារមូលបត្រប្រតិស្រុត ស្របតាមវិធានប្រតិបត្តិការទីផ្សារមូលបត្រ ដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**)។

៩-ម៉ោងអនុវត្តការជួញដូរ (Trading Time) សំដៅដល់ម៉ោងដែលអនុញ្ញាតឱ្យមានការអនុវត្តការជួញដូរនៅលើទីផ្សារមូលបត្រប្រតិស្រុត ស្របតាមវិធានប្រតិបត្តិការទីផ្សារមូលបត្រ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

១០-សំណើទិញជែឧន៉រ (Tender Offer) សំដៅដល់សំណើសុំទិញដែលបើកចំហជាសាធារណៈដើម្បីទិញមូលបត្រកម្មសិទ្ធិរបស់បុគ្គលចុះបញ្ជីលក់មូលបត្រចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងចរាចរនៅលើទីផ្សារ (Outstanding Equity Securities) ឬសំណើសុំទិញដែលមានគោលដៅត្រួតត្រាលើបុគ្គលចុះបញ្ជីលក់មូលបត្រណាមួយ។

## ជំពូកទី ២

## ប្រភេទ និងលក្ខខណ្ឌនៃការបង្ហាញព័ត៌មានសាជីវកម្ម

### ប្រការ ៥.- ព័ត៌មានសាជីវកម្មដែលត្រូវបង្ហាញ

ព័ត៌មានសាជីវកម្មដែលបុគ្គលចុះបញ្ជីលក់មូលបត្រ ត្រូវបង្ហាញរួមមាន ព័ត៌មានទាន់ពេល របាយការណ៍សាមាយិក ព័ត៌មានពិសេស និងព័ត៌មានតាមការស្នើសុំ។

### ប្រការ ៦.- ព័ត៌មានដែលត្រូវបង្ហាញទាន់ពេល

បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិត្រូវផ្តល់ព័ត៌មានទាន់ពេលជូនវិនិយោគិន តាមរយៈទីផ្សារមូលបត្រប្រតិស្រុត តាមទម្រង់កំណត់ដោយទីផ្សារមូលបត្រប្រតិស្រុត និងចម្លងជូន **គ.ម.ក.** ក្នុងពេលដំណាលគ្នា

ក្នុងករណីមានហេតុការណ៍ណាមួយដូចខាងក្រោម÷

**ក. ហេតុការណ៍ពាក់ព័ន្ធនឹងធុរកិច្ច ឬផលិតកម្ម**

១-ការសម្រេចពាក់ព័ន្ធនឹងការប្រែប្រួលកម្មវត្ថុ លក្ខណៈ ឬគោលដៅនៃធុរកិច្ច ការផ្លាស់ប្ដូរផែនការវិនិយោគពាក់ព័ន្ធនឹងការប្រើប្រាស់សាច់ប្រាក់ដែលបានពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ ការផ្លាស់ប្ដូរគោលនយោបាយគណនេយ្យសំខាន់ៗ ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ការផ្លាស់ប្ដូរនាមករណ៍ ឬទីស្នាក់ការ ឬការសម្រេចផ្សេងទៀតដែលអាចមានផលប៉ះពាល់ខ្លាំងលើការគ្រប់គ្រងធុរកិច្ច របស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

២-ករណីបុគ្គលចុះបញ្ជីលក់មូលបត្រទទួលបានអាជ្ញាបណ្ណធុរកិច្ចថ្មី ឬចាប់ផ្ដើមមានផលិតផលថ្មីដែលសំខាន់ ឬការអភិវឌ្ឍសំខាន់ៗ ពាក់ព័ន្ធនឹងបច្ចេកវិទ្យា ផលិតផល ឬទីផ្សារ ឬការរកឃើញថ្មីនូវធនធានធម្មជាតិសំខាន់ៗ។

៣-ការសម្រេចទិញ លក់ ឬលុបចោលកិច្ចសន្យាប្រេនឆាយ ឬកិច្ចសន្យាផ្ដល់សិទ្ធិចែកចាយ។

៤-ការផ្អាក ឬបញ្ឈប់ប្រតិបត្តិការជាមួយអតិថិជនដែលទិញទំនិញ ឬសេវាដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃទំហំលក់សរុបនៃឆ្នាំជាប់ពន្ធចុងក្រោយ ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង៣០.០០០.០០០.០០០ (សាមសិបប៊ីលាន)រៀល ឬចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃទំហំលក់សរុបនៃឆ្នាំជាប់ពន្ធចុងក្រោយ ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀលឡើងទៅ។

៥-ការព្យួរ ការបញ្ឈប់ ឬការចាប់ផ្ដើមដំណើរការឡើងវិញនូវសកម្មភាពធុរកិច្ចណាមួយដែលមានទំហំចាប់ពី ១០(ដប់) ភាគរយឡើងទៅនៃទំហំលក់សរុបនៃឆ្នាំជាប់ពន្ធចុងក្រោយ ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀល ឬចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃទំហំលក់សរុបនៃឆ្នាំជាប់ពន្ធចុងក្រោយ ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀលឡើងទៅ។

៦-ការសម្រេចក្នុងការប្រមូលមកវិញ ឬកម្ទេចចោល ផលិតផលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃទំហំលក់សរុបនៃឆ្នាំជាប់ពន្ធចុងក្រោយ ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀល ឬចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃទំហំលក់សរុបនៃឆ្នាំសារពើពន្ធចុងក្រោយ ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ៣០.០០០.០០០.០០០(សាមសិបប៊ីលាន) រៀលឡើងទៅ។

**ខ. ហេតុការណ៍ពាក់ព័ន្ធនឹងដើមទុន ភាគហ៊ុន ឬបំណុល**

១-ការសម្រេចបង្កើន ឬបន្ថយដើមទុន ឬការសម្រេចបំបែក ឬបង្រួមមូលបត្រកម្មសិទ្ធិ។

២-ការសម្រេចបែងចែកភាគលាភ ឬការសម្រេចមិនបែងចែកភាគលាភ។

៣-ការសម្រេចផ្ដល់ឱ្យ ឬលុបចោលសិទ្ធិទិញមូលបត្រកម្មសិទ្ធិ (Stock Options)។

៤-ការសម្រេចបង្កើនកម្ចី ឬបោះផ្សាយមូលបត្របំណុល រយៈពេលខ្លី ឬរយៈពេលវែង ដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃមូលធនភាគហ៊ុនិកសរុប ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀល ឬចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលធនភាគហ៊ុនិកសរុប ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀលឡើងទៅ។

៥-ករណីបុគ្គលចុះបញ្ជីលក់មូលបត្រលុបបំណុល ឬសម្រេចធានាបំណុលឱ្យតតិយជន ដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃមូលធនភាគហ៊ុនិកសរុប ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀល ឬចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលធនភាគហ៊ុនិកសរុប ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀលឡើងទៅ។

៦-បុគ្គលចុះបញ្ជីលក់មូលបត្រខកខានក្នុងការទូទាត់ការប្រាក់ និងប្រាក់ដើម ដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃមូលធនភាគហ៊ុនិកសរុប ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀល ឬចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលធនភាគហ៊ុនិកសរុប ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀលឡើងទៅ។

៧-ករណីមានការសម្រេចបោះផ្សាយ ឬចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតបរទេស ឬករណីមូលបត្ររបស់បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបានព្យួរ ឬត្រូវបានដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុតបរទេស។

៨-ការសម្រេចដកចេញពីបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។

**គ. ហេតុការណ៍ពាក់ព័ន្ធនឹងការគ្រប់គ្រង**

១-ការសម្រេចរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក ដោយលម្អិតអំពីកាលបរិច្ឆេទប្រជុំ របៀបវារៈប្រជុំ ទីកន្លែងប្រជុំ និងលក្ខខណ្ឌសម្រាប់ការចូលរួម និងអ្នកចូលរួម។

២-សេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។

៣-ការប្រែប្រួល ឬការផ្លាស់ប្តូរណាមួយនៃក្រុមប្រឹក្សាភិបាល ឬថ្នាក់ដឹកនាំដែលមានអំណាចសម្រេចរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ជាអាទិ៍ នាយកប្រតិបត្តិ ឬប្រធានផ្នែកហិរញ្ញវត្ថុ។

៤-ការប្រែប្រួលភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១០% ឡើងទៅ ឬភាគហ៊ុនិកដែលមានសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៥-ការផ្លាស់ប្តូរប្រធាន ឬសមាជិកនៃគណៈកម្មាធិការសវនកម្មមុនអាណត្តិ ។

ឃ. ហេតុការណ៍ពាក់ព័ន្ធនឹងសកម្មភាពវិនិយោគ

១-ការចាប់ផ្តើម ឬការឈប់ធ្វើជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធនៃក្រុមហ៊ុនហ្វូលនិងណាមួយ ឬការទទួលបានក្រុមហ៊ុនណាមួយមកធ្វើជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធ នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ។

២-ការវិនិយោគក្នុងក្រុមហ៊ុនផ្សេងទៀត ដោយរួមទាំងការទិញ ឬលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនផ្សេងទៀត ដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃមូលធនភាគហ៊ុនិកសរុបរបស់បុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀល ឬចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលធនភាគ-ហ៊ុនិកសរុបរបស់បុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀលឡើងទៅ។

៣-ការវិនិយោគលើទ្រព្យសកម្ម ដោយរាប់បញ្ចូលទាំងការសាងសង់ ការទិញឬលក់ រោងចក្រ អគារ ឬបរិក្ខារ ដែលមានទំហំចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃទ្រព្យសកម្មសរុប ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀល ឬចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃទ្រព្យសកម្មសរុប ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ៣០.០០០.០០០.០០០(សាមសិបប៊ីលាន) រៀលឡើងទៅ។

ង. ហេតុការណ៍ពាក់ព័ន្ធនឹងចំណេញឬខាត

១-ការថយចុះ ឬការកើនឡើងនៃចំណូល ឬចំណេញ/ខាតប្រតិបត្តិការ ឬចំណេញ/ខាតសុទ្ធ ធៀបទៅនឹងពេលដូចគ្នានៃត្រីមាស ឬឆ្នាំជាប់ពន្ធចុងក្រោយ ចាប់ពី ៣០ (សាមសិប) ភាគរយឡើងទៅ ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀល ឬចាប់ពី ១៥ (ដប់ប្រាំ) ភាគរយឡើងទៅ ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀលឡើងទៅ។

២-ការថយចុះតម្លៃមូលធនភាគហ៊ុនិកសរុបច្រើនជាងពាក់កណ្តាលដោយធៀបនឹងតម្លៃមូលធនភាគហ៊ុនិកសរុបនៃឆ្នាំជាប់ពន្ធចុងក្រោយ ឬការថយចុះ ឬការខាតបង់តម្លៃ ចាប់ពី ១០ (ដប់) ភាគរយនៃទ្រព្យសកម្មសរុបនៃឆ្នាំជាប់ពន្ធចុងក្រោយ របស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៣-ករណីប្រធានសក្តិដែលមានផលប៉ះពាល់ចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃទ្រព្យសកម្មសរុប ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀល ឬចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃទ្រព្យសកម្មសរុបចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀលឡើងទៅ។

ច. ហេតុការណ៍ពាក់ព័ន្ធនឹងតុលាការ សវនករ ឬករណីផ្សេងៗទៀត

១-ករណីមានហេតុការណ៍ដែលអាចនឹងបណ្តាលឱ្យមានការរំលាយក្រុមហ៊ុន ឬការសម្រេចជម្រះបញ្ជី ឬរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត។

២-ករណីមានបណ្តឹងសុំបើកសំណុំរឿងក្ស័យធនទៅតុលាការ។

៣-ករណីបុគ្គលចុះបញ្ជីលក់មូលបត្រជាប់បណ្តឹងនៅតុលាការ ឬមានសេចក្តីសម្រេចរបស់តុលាការ ដែលអាចមានផលប៉ះពាល់ខ្លាំងដល់ការគ្រប់គ្រង ទ្រព្យសកម្ម ឬដំណើរការរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៤-ករណីបានដឹងពីការឃុំខ្លួន ឬការសម្រេចសេចក្តីរបស់តុលាការចំពោះការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមរបស់អភិបាល ឬថ្នាក់ដឹកនាំដែលមានអំណាចសម្រេចនៃបុគ្គលចុះបញ្ជីលក់មូលបត្រ ជាអាទិ៍ នាយកប្រតិបត្តិ ឬប្រធានផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងការអនុវត្តតួនាទី និងភារកិច្ច។

៥-ករណីបុគ្គលចុះបញ្ជីលក់មូលបត្រទទួលរងខាតបង់ ដែលមានចំនួនជាប្រាក់ចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលធនភាគហ៊ុនិកសរុប ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀល ឬចាប់ពី ២,៥ (ពីរក្បៀសប្រាំ) ភាគរយឡើងទៅនៃមូលធនភាគហ៊ុនិកសរុប ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀលឡើងទៅ។

៦-ករណីមានការបញ្ជាក់ថាអភិបាល និយោជិត ឬអតីតនិយោជិត បានក្លែងរបាយការណ៍ហិរញ្ញវត្ថុ ឬបានកែបន្លំទ្រព្យដែលមានតម្លៃចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលធនភាគហ៊ុនិកសរុប ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀល ឬចាប់ពី ២,៥ (ពីរក្បៀសប្រាំ) ភាគរយឡើងទៅនៃមូលធនភាគហ៊ុនិកសរុប ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ៣០.០០០.០០០.០០០ (សាមសិបប៊ីលាន) រៀលឡើងទៅ។

៧-ករណីមូលប្បទានប័ត្រ ប័ណ្ណសងតាមបញ្ជា ឬបិយាណត្តិ ត្រូវបានបដិសេធដោយធនាគារ ឬករណីប្រតិបត្តិការណាមួយជាមួយធនាគារត្រូវបានព្យួរ ឬហាមឃាត់។

៨-ការបញ្ចប់សេវាសវនកម្មរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រមុនបញ្ចប់អាណត្តិនៃកិច្ចសន្យាផ្តល់សេវាសវនកម្ម។

៩-ករណីយោបល់របស់សវនករឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុរបស់បុគ្គលចុះបញ្ជីលក់មូលបត្រជាទស្សនៈដែលមានបញ្ហា (Qualified Opinion) ជាទស្សនៈនៃការប្រឆាំង (Adverse Opinion) ឬជាទស្សនៈនៃការបដិសេធមិនទទួលខុសត្រូវ (Disclaimer of Opinion)។

១០-ករណីផ្សេងទៀតដែលទីផ្សារមូលបត្រប្រតិស្រុតយល់ថាអាចប៉ះពាល់ដល់ថ្លៃ ឬការជួញដូរមូលបត្ររបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

នៅពេលហេតុការណ៍ណាមួយដូចបានរៀបរាប់ក្នុងកថាខណ្ឌទី ១ ខាងលើ បានកើតឡើង បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិត្រូវផ្តល់ព័ត៌មាននៃហេតុការណ៍នោះដោយគ្មានការពន្យារពេល ជូនទីផ្សារមូលបត្រប្រតិស្រុត និងចម្លងជូន គ.ម.ក. ក្នុងពេលដំណាលគ្នាឱ្យបាន ១ (មួយ) ម៉ោងមុនម៉ោងអនុវត្តការជួញដូរ ឬបន្ទាប់ពីម៉ោងជួញដូរ ក្នុងករណីហេតុការណ៍នោះបានកើតឡើងចាប់ពី ១ (មួយ) ម៉ោងមុនម៉ោងអនុវត្តការជួញដូររហូតដល់ចប់ម៉ោងធ្វើការរបស់ទីផ្សារមូលបត្រប្រតិស្រុត។

ករណីហេតុការណ៍ណាមួយដូចបានរៀបរាប់ក្នុងកថាខណ្ឌទី ១ ខាងលើបានកើតឡើងក្នុងម៉ោងជួញដូរហើយមានលក្ខណៈជាសារវន្ត បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិត្រូវពិគ្រោះយោបល់ជាមួយទីផ្សារមូលបត្រប្រតិស្រុតភ្លាម និងចម្លងជូន គ.ម.ក. ក្នុងពេលដំណាលគ្នា ហើយទីផ្សារមូលបត្រប្រតិស្រុតអាចពិចារណាឱ្យផ្សព្វផ្សាយព័ត៌មាននៃហេតុការណ៍នោះ។ ក្នុងករណីនេះទីផ្សារមូលបត្រប្រតិស្រុតអាចសម្រេចព្យួរការជួញដូរមូលបត្ររបស់បុគ្គលចុះបញ្ជីលក់មូលបត្រនោះ។

បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិក៏ត្រូវផ្តល់ព័ត៌មានទាន់ពេលជូនទីផ្សារមូលបត្រប្រតិស្រុតតាមទម្រង់កំណត់ដោយទីផ្សារមូលបត្រប្រតិស្រុត និងចម្លងជូន គ.ម.ក. ក្នុងពេលដំណាលគ្នា នៅក្រៅម៉ោងជួញដូរ និងយ៉ាងយូរ ១ (មួយ) ម៉ោងមុនម៉ោងអនុវត្តការជួញដូរនៅថ្ងៃបន្ទាប់ ករណីក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ មានហេតុការណ៍ណាមួយដូចខាងក្រោម÷

១-ករណីមានហេតុការណ៍ដូចមានចែងក្នុងចំណុច ខ.១, ខ.៧, ច.១, ច.២ និងច.៧ កថាខណ្ឌទី១ ខាងលើ។

២-ការសម្រេចផ្លាស់ប្តូរនាមករណ៍។

៣-ករណីប្តឹង ឬត្រូវគេប្តឹងទៅតុលាការ ឬករណីទទួលបានសេចក្តីសម្រេចរបស់តុលាការ ដែលអាចមានផលប៉ះពាល់ដល់ការគ្រប់គ្រង ទ្រព្យសកម្ម ដំណើរការក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ឬពាក់ព័ន្ធនឹងការរំលោភបំពានច្បាប់និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ ឬសំណងការខូចខាតផ្សេងៗ។

៤-ហេតុការណ៍ផ្សេងទៀតដែលពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច ឬទ្រព្យសកម្មរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលអាចប៉ះពាល់ដល់ការសម្រេចវិនិយោគរបស់វិនិយោគិន។

បុគ្គលចុះបញ្ជីលក់មូលបត្របំណុលត្រូវផ្តល់ព័ត៌មានទាន់ពេលជូនទីផ្សារមូលបត្រប្រតិស្រុតតាមទម្រង់កំណត់ដោយទីផ្សារមូលបត្រប្រតិស្រុត និងចម្លងជូន គ.ម.ក. ក្នុងពេលដំណាលគ្នា នៅក្រៅម៉ោងជួញដូរ និងយ៉ាងយូរ១(មួយ) ម៉ោងមុនម៉ោងអនុវត្តការជួញដូរនៅថ្ងៃបន្ទាប់ករណីមានហេតុការណ៍ណាមួយដូចខាងក្រោម÷

១-ករណីហេតុការណ៍ដូចមានចែងក្នុងចំណុច ក.៥, ង.២, ច.១, ច.២, ច.៧ និង ច.៩ នៃកថាខណ្ឌទី១ ខាងលើ។

២- ការសម្រេចបន្ទយដើមទុន។

៣- ករណីដូចមានចែងក្នុងប្រការ៣៩ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

**ប្រការ ៧.-** របាយការណ៍សាមាយិកដែលត្រូវបង្ហាញ

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់របាយការណ៍សាមាយិកតាមទម្រង់កំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ជូន **គ.ម.ក.** រួមមានរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំត្រីមាស។

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យបុគ្គលចុះបញ្ជីលក់មូលបត្រផ្តល់នូវរបាយការណ៍ស្តីពីលទ្ធផលហិរញ្ញវត្ថុប្រចាំឆ្នាំ ឬប្រចាំត្រីមាសមុនធ្វើសវនកម្ម។

របាយការណ៍ដែលដាក់ជូន **គ.ម.ក.** ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវមានចុះកាលបរិច្ឆេទច្បាស់លាស់ និងមានឧទ្ទេសថា ***"បានអាន និងឯកភាព"*** ហើយត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលយ៉ាងតិច ២ (ពីរ) រូបសម្រាប់របាយការណ៍ប្រចាំត្រីមាស និងហត្ថលេខារបស់អភិបាលទាំងអស់សម្រាប់របាយការណ៍ប្រចាំឆ្នាំ។ អភិបាលអាចផ្ទេរសិទ្ធិជូនអភិបាលណាមួយក្នុងការចុះហត្ថលេខាលើរបាយការណ៍ ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតផ្ទេរសិទ្ធិ។

**ប្រការ ៨.-** របាយការណ៍ប្រចាំឆ្នាំ

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំជូន **គ.ម.ក.** ក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃបន្ទាប់ពីបញ្ចប់ឆ្នាំជាប់ពន្ធ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។ លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ព័ត៌មានដែលត្រូវបង្ហាញក្នុងរបាយការណ៍ប្រចាំឆ្នាំរួមមាន÷

១- ព័ត៌មានទូទៅរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក។

៣- ព័ត៌មានស្តីពីអភិបាលកិច្ចសាជីវកម្ម។

៤- សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ដោយរួមបញ្ចូលការវាយតម្លៃរបស់ក្រុមប្រឹក្សាភិបាលលើទស្សនវិស័យរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៥- របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ។

៦- របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង។

៧- ព័ត៌មានអំពីការជួញដូរមូលបត្ររបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៨- ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ។

៩-ការពិភាក្សានិងការវិភាគរបស់គណៈគ្រប់គ្រង។

១០-បញ្ជីរាយនាមភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់។

១១-ស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

១២-ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិនតាមការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក.**។

ក្នុងគោលដៅផ្ទៀងផ្ទាត់ និងត្រួតពិនិត្យរបាយការណ៍សាមាយិក បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ជូន **គ.ម.ក.** ក្នុងអំឡុងពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ នូវរបាយការណ៍របស់អ្នកគ្រប់គ្រង (Management Letter) បន្ទាប់ពីទទួលបានពីសវនករឯករាជ្យ សម្រាប់ប្រើប្រាស់ផ្ទៃក្នុង។ **គ.ម.ក.** មានសិទ្ធិតម្រូវឱ្យបុគ្គលចុះបញ្ជីលក់មូលបត្រ ធ្វើការពន្យល់ ផ្តល់ឯកសារពាក់ព័ន្ធ និង/ឬកែតម្រូវ ពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ។ ក្នុងករណីចាំបាច់ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់មន្ត្រីដើម្បីត្រួតពិនិត្យដល់ទីកន្លែងពាក់ព័ន្ធនឹងឯកសារ និង/ឬបញ្ជីគណនេយ្យ។

## ប្រការ ៩.-របាយការណ៍ប្រចាំត្រីមាស

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាសជូន **គ.ម.ក.** ក្នុងអំឡុងពេល ៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីបញ្ចប់ត្រីមាសនៃឆ្នាំជាប់ពន្ធ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។ លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ព័ត៌មានដែលត្រូវបង្ហាញក្នុងរបាយការណ៍ប្រចាំត្រីមាស រួមមាន៖

១-ព័ត៌មានទូទៅរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

២-ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក។

៣-សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ដោយរួមបញ្ចូលការវាយតម្លៃរបស់ក្រុមប្រឹក្សាភិបាលលើទស្សនវិស័យរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៤-របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

៥-ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន តាមការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ១០.-ព័ត៌មានពិសេសដែលត្រូវបង្ហាញ

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ព័ត៌មានពិសេសជូន **គ.ម.ក.** ក្នុងករណីមានការប្រែប្រួលរចនាសម្ព័ន្ធក្រុមហ៊ុនមួយផ្នែក ឬទាំងស្រុងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ រួមមានព័ត៌មានពាក់ព័ន្ធនឹងការទិញមូលបត្រកម្មសិទ្ធិមកវិញ ការរំលាយក្រុមហ៊ុនបញ្ចូលគ្នានិងការទិញយក ការទទួលកាន់កាប់បន្ត និងសំណើទិញផែនដី។

**ប្រការ ១១.- ការផ្តល់នូវព័ត៌មាន ឯកសារពាក់ព័ន្ធ និងរបាយការណ៍លទ្ធផល**

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធជូន **គ.ម.ក.** ភ្លាម ក្នុងករណីមានការសម្រេចទិញមូលបត្រកម្មសិទ្ធិមកវិញ ការរំលាយក្រុមហ៊ុនបញ្ចូលគ្នានិងការទិញយក ការទទួលកាន់កាប់បន្ត ឬសំណើទិញផែនទាំ និងត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុននឹងធ្វើប្រតិបត្តិការណាមួយនេះ។

បុគ្គលដែលមានបំណងរំលាយក្រុមហ៊ុនបញ្ចូលគ្នានិងការទិញយក ទទួលកាន់កាប់បន្ត ឬធ្វើសំណើទិញផែនទាំ ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រ ត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុននឹងធ្វើប្រតិបត្តិការណាមួយនេះ។

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់របាយការណ៍លទ្ធផលជូន **គ.ម.ក.** ក្នុងអំឡុងពេល ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបញ្ចប់ការទិញមូលបត្រកម្មសិទ្ធិមកវិញ ការរំលាយក្រុមហ៊ុនបញ្ចូលគ្នានិងការទិញយក ការទទួលកាន់កាប់បន្ត និងក្នុងអំឡុងពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបញ្ចប់សំណើទិញផែនទាំ។ ចំពោះករណីទិញមូលបត្រកម្មសិទ្ធិមកវិញ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ជូន **គ.ម.ក.** ផងដែរនូវរបាយ-ការណ៍លទ្ធផលប្រចាំថ្ងៃនៃការទិញមូលបត្រកម្មសិទ្ធិមកវិញ។

បុគ្គលដែលបានទទួលកាន់កាប់បន្ត ឬធ្វើសំណើទិញផែនទាំ ចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់របាយការណ៍លទ្ធផលជូន **គ.ម.ក.** ក្នុងអំឡុងពេល ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបញ្ចប់ការទទួលកាន់កាប់បន្ត និងក្នុងអំឡុងពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបញ្ចប់សំណើទិញផែនទាំ។

លក្ខខណ្ឌ និងនីតិវិធីនៃការអនុវត្តប្រតិបត្តិការនីមួយៗដូចមានចែងក្នុងប្រការ ១១ នេះ ត្រូវកំណត់ក្នុងបទប្បញ្ញត្តិដោយឡែក។

**ប្រការ ១២.- ការទិញមូលបត្រកម្មសិទ្ធិមកវិញ**

ករណីការទិញមូលបត្រកម្មសិទ្ធិមកវិញ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ព័ត៌មានជូន **គ.ម.ក.** ដែលមាននិទ្ទេសដូចខាងក្រោម÷

១- ការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬមហាសន្និបាតភាគហ៊ុនិក។

២- គោលបំណងនៃការទិញមូលបត្រកម្មសិទ្ធិមកវិញ។

៣- ព័ត៌មានលម្អិតអំពីការទិញមូលបត្រកម្មសិទ្ធិមកវិញ។

៤- ព័ត៌មានផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១៣.- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នានិងការទិញយក**

ករណីរំលាយក្រុមហ៊ុនបញ្ចូលគ្នានិងការទិញយក បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ព័ត៌មានជូន **គ.ម.ក.** ដែលមាននិទ្ទេសដូចខាងក្រោម÷

១- ការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬមហាសន្និបាតភាគហ៊ុនិក។

២-គោលបំណងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នានិងការទិញយក។

៣-ព័ត៌មានអំពីក្រុមហ៊ុនដែលជាកម្មវត្ថុនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នានិងការទិញយក។

៤-ព័ត៌មានលម្អិតអំពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នានិងការទិញយក។

៥-ព័ត៌មានផ្សេងទៀតដែលតម្រូវដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១៤.-ការទទួលកាន់កាប់បន្ត**

ករណីទទួលកាន់កាប់បន្តធុរកិច្ចដទៃទៀតតាមរយៈការទិញមូលបត្រកម្មសិទ្ធិ ឬការទិញយក ឬការផ្ទេរទ្រព្យសកម្មស្នូលរបស់ក្រុមហ៊ុនដែលជាកម្មវត្ថុនៃការទិញយក បុគ្គលចុះបញ្ជីលក់មូលបត្រ ឬបុគ្គលដែលមានបំណងទទួលកាន់កាប់បន្ត ត្រូវផ្ដល់ព័ត៌មានជូន **គ.ម.ក.** ដែលមាននិទ្ទេសដូចខាងក្រោម÷

១-ការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬមហាសន្និបាតភាគហ៊ុនិក។

២- គោលបំណងនៃការទទួលកាន់កាប់បន្ត។

៣-ព័ត៌មានពីក្រុមហ៊ុនដែលជាកម្មវត្ថុនៃការទទួលកាន់កាប់បន្ត។

៤-ព័ត៌មានលម្អិតអំពីប្រតិបត្តិការនៃការទទួលកាន់កាប់បន្ត។

៥-ព័ត៌មានផ្សេងទៀតដែលតម្រូវដោយអគ្គនាយក **គ.ម.ក.**។

ករណីមិនចាត់ទុកជាការទទួលកាន់កាប់បន្តមានដូចខាងក្រោម÷

១-ការទិញ ឬលក់ផលិតផល វត្ថុធាតុដើម ការទិញស្តុកទុក ឬសន្និធិដទៃទៀត។

២-ការទិញ ឬលក់មូលបត្រកម្មសិទ្ធិដែលមានទំហំមិនលើសពី ៣០ (សាមសិប) ភាគរយនៃមូលបត្រកម្មសិទ្ធិសរុបរបស់ក្រុមហ៊ុនគោលដៅ។

៣-ការទិញ ឬការលក់ទ្រព្យសកម្មដោយសារដល់ខួបផ្លាស់ប្តូរ។

៤-ការរំលាយក្រុមហ៊ុនបញ្ចូលគ្នានិងការទិញយករវាងផ្នែកនានារបស់ក្រុមហ៊ុនតែមួយ។

៥-សកម្មភាពផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១៥.-សំណើទិញតែនឌ័រ**

ករណីមានសំណើទិញតែនឌ័រ បុគ្គលដែលមានបំណងធ្វើសំណើទិញតែនឌ័រ ត្រូវផ្ដល់ព័ត៌មានជូន **គ.ម.ក.** ដែលមាននិទ្ទេសដូចខាងក្រោម÷

១-ព័ត៌មានអំពីបុគ្គលធ្វើសំណើទិញតែនឌ័រ។

៣-គោលបំណងនៃការធ្វើសំណើទិញតែនឌ័រ។

៤-ប្រភេទ ស៊េរី និងចំនួនមូលបត្រកម្មសិទ្ធិដែលជាកម្មវត្ថុនៃសំណើទិញតែនឌ័រ។

៥-វិធីសាស្ត្រនៃសំណើទិញតែនឌ័រ។

៦-លក្ខខណ្ឌនៃសំណើទិញតែនឌ័រ ដូចជារយៈពេល ថ្លៃ កាលបរិច្ឆេទទូទាត់ និងវិធីសាស្ត្រទូទាត់។

៧- ប្រភពមូលនិធិសម្រាប់ការធ្វើសំណើទិញផែនឌ័រ។

៨- ការតែងតាំងក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ពី **គ.ម.ក.** ឱ្យធ្វើជាភ្នាក់ងារក្នុងការធ្វើសំណើទិញផែនឌ័រ។

៩- ព័ត៌មានផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** បុគ្គលដែលទទួលបានការអនុញ្ញាតឱ្យធ្វើសំណើទិញផែនឌ័រ មិនត្រូវ÷

១- ដកសំណើសុំទិញទេ លុះត្រាតែមានហេតុការណ៍ប្រធានសក្តិ ឬមហន្តរាយដែលមិនអាចព្យាករណ៍ទុកជាមុនបាននិងបង្កឱ្យមានការខូចខាតចាប់ពី ១០ (ដប់) ភាគរយ ឡើងទៅនៃទ្រព្យសកម្មសរុបរបស់បុគ្គលដែលបានធ្វើសំណើ។

២- កែប្រែលក្ខខណ្ឌណាមួយនៃសំណើទិញផែនឌ័រដែលបានដាក់ជូន **គ.ម.ក.**។

៣- ទិញ ឬលក់ខុសពីលក្ខខណ្ឌដែលចែងក្នុងឯកសារនៃសំណើទិញផែនឌ័រដែលបានដាក់ជូន **គ.ម.ក.**។

**ប្រការ ១៦.-** ព័ត៌មានតាមការស្នើសុំដែលត្រូវបង្ហាញ

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ព័ត៌មានភ្លាម នៅពេលមានការស្នើសុំពីទីផ្សារមូលបត្រប្រតិស្រុត ឬពីអគ្គនាយកនៃ **គ.ម.ក.** ក្នុងករណីដូចខាងក្រោម÷

១- ករណីមានពាក្យចចាមអារាម ដំណឹង ឬព័ត៌មាន ដែលអាចធ្វើឱ្យមានការប៉ះពាល់ដល់បុគ្គលចុះបញ្ជីលក់មូលបត្រ ឬថ្លៃមូលបត្ររបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

២- ករណីមានការប្រែប្រួលថ្លៃ ឬទំហំជួញដូរមិនប្រក្រតីនៃមូលបត្រ។

៣- ករណីមានព្រឹត្តិការណ៍ដែលអាចមានផលប៉ះពាល់ដល់ផលប្រយោជន៍វិនិយោគិន។

**ប្រការ ១៧.-** ការបង្ហាញព័ត៌មានតាមការស្ម័គ្រចិត្ត

បុគ្គលចុះបញ្ជីលក់មូលបត្រអាចស្នើសុំបង្ហាញព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ចសំខាន់ ឬព័ត៌មានក្រៅពីព័ត៌មានសាជីវកម្មដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ ដល់វិនិយោគិន តាមរយៈទីផ្សារមូលបត្រប្រតិស្រុត និងចម្លងជូន **គ.ម.ក.** ក្នុងពេលដំណាលគ្នា។

បុគ្គលចុះបញ្ជីលក់មូលបត្រអាចស្នើសុំបង្ហាញព័ត៌មានហិរញ្ញវត្ថុព្យាករណ៍ ឬព័ត៌មានហិរញ្ញវត្ថុដែលមិនទាន់ធ្វើសវនកម្មឬត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ ដល់វិនិយោគិន តាមរយៈទីផ្សារមូលបត្រប្រតិស្រុត និងចម្លងជូន **គ.ម.ក.** ក្នុងពេលដំណាលគ្នា។ ករណីនេះ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវ÷

១- បញ្ជាក់ឱ្យបានច្បាស់លាស់ថា ព័ត៌មានហិរញ្ញវត្ថុនេះ ជាព័ត៌មានហិរញ្ញវត្ថុព្យាករណ៍ ឬព័ត៌មានហិរញ្ញវត្ថុដែលមិនទាន់ធ្វើសវនកម្មឬត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យនៅឡើយ។

២-បញ្ជាក់ឱ្យបានច្បាស់លាស់ពីវិធីសាស្ត្រ ឬមូលដ្ឋានដែលប្រើប្រាស់សម្រាប់ការព្យាករណ៍ ឬប៉ាន់ស្មានលើព័ត៌មានហិរញ្ញវត្ថុនេះ។

ក្នុងករណីព័ត៌មានហិរញ្ញវត្ថុសំខាន់ដែលបានផ្សព្វផ្សាយជាសាធារណៈប្រែប្រួលយ៉ាងតិច ២០ (ម្ភៃ) ភាគរយពីរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម ឬត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបកស្រាយភ្លាមពីមូលហេតុនៃការប្រែប្រួលនេះជូនវិនិយោគិន តាមរយៈទីផ្សារមូលបត្រប្រតិស្រុត និងចម្លងជូន គ.ម.ក. ក្នុងពេលដំណាលគ្នា។

ទីផ្សារមូលបត្រប្រតិស្រុតអាចបដិសេធសំណើសុំបង្ហាញព័ត៌មានរបស់បុគ្គលចុះបញ្ជីលក់មូលបត្រក្នុងករណីព័ត៌មាននោះមិនមានភាពចាំបាច់។

## ជំពូកទី ៣
## នីតិវិធី និងយន្តការក្នុងការបង្ហាញព័ត៌មាន

### ប្រការ ១៨.- ការតែងតាំងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវចាត់តាំងអភិបាល ឬបុគ្គលិកជាន់ខ្ពស់យ៉ាងតិច ១ (មួយ) រូបជាបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន និងអាចមានបុគ្គលិក ១ (មួយ) ឬច្រើនរូបទៀត ជាជំនួយការក្នុងការអនុវត្តការងារ និងបំពេញមុខងារជំនួសបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន នៅពេលបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានអវត្តមាន។ បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានត្រូវទទួលខុសត្រូវលើការអនុវត្តការងារពាក់ព័ន្ធនឹងការបង្ហាញព័ត៌មានសាជីវកម្មរបស់ជំនួយការ។ បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន និងជំនួយការនេះត្រូវឆ្លងកាត់ការបណ្តុះបណ្តាលដែលរៀបចំដោយ គ.ម.ក. និងទីផ្សារមូលបត្រប្រតិស្រុត។

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបញ្ជូនអត្តសញ្ញាណបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន និងជំនួយការជាលាយលក្ខណ៍អក្សរជូន គ.ម.ក. និងចម្លងជូនទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុត។

ករណីមានការផ្លាស់ប្តូរឬអវត្តមាន បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានឬជំនួយការ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមជូន គ.ម.ក. និងទីផ្សារមូលបត្រប្រតិស្រុត។ ប្រសិនបើតំណែងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាននៅទំនេរ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវជ្រើសរើសបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានថ្មី ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ។

### ប្រការ ១៩.- ការទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មាន

បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានត្រូវទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មានសាជីវកម្មដូចមានចែងក្នុងជំពូកទី២ នៃប្រកាសនេះ។ បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានត្រូវរក្សាទំនាក់ទំនងដោយផ្ទាល់គ្រប់ពេលវេលាជាមួយនឹងមន្ត្រីទទួលបន្ទុកព័ត៌មានសាជីវកម្មនៃ គ.ម.ក. និងមន្ត្រីទទួលបន្ទុកនៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ២០.- មធ្យោបាយ និងបែបបទក្នុងការផ្តល់ព័ត៌មាន**

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវរៀបចំព័ត៌មានដូចមានចែងក្នុងជំពូកទី២ នៃប្រកាសនេះ ជាលាយលក្ខណ៍អក្សរ ដោយត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីឈ្មោះនិងអក្សរកាត់របស់បុគ្គលចុះបញ្ជីលក់មូលបត្រ កាលបរិច្ឆេទនិងពេលវេលានៃការបញ្ជូន ហើយត្រូវផ្តល់ជូនទីផ្សារមូលបត្រប្រតិស្រុត និង/ឬ **គ.ម.ក.** ដោយផ្ទាល់ ឬតាមរយៈទូរសារ ឬសារអេឡិចត្រូនិច ឬប្រព័ន្ធអេឡិចត្រូនិចផ្សេងទៀត។ ព័ត៌មានដែលត្រូវបង្ហាញនេះត្រូវផ្តល់ជាភាសាខ្មែរ និងភាសាអង់គ្លេស ក្នុងពេលដំណាលគ្នា។ ចំពោះព័ត៌មានដែលត្រូវផ្តល់ជាភាសាអង់គ្លេសត្រូវបញ្ជាក់ថា "Unofficial Translation" និងអាចមានហត្ថលេខារបស់បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន។

ក្រៅពីព័ត៌មានសាជីវកម្មដែលត្រូវផ្សព្វផ្សាយជាសាធារណៈដូចមានចែងក្នុងប្រកាសនេះ បុគ្គលចុះបញ្ជីលក់មូលបត្រអាចផ្តល់ឯកសារសម្រាប់ប្រើប្រាស់ផ្ទៃក្នុង ជូនទីផ្សារមូលបត្រប្រតិស្រុត និង/ឬ **គ.ម.ក.** ដោយបញ្ជាក់ថា "**មិនសម្រាប់ផ្សព្វផ្សាយជាសាធារណៈ**"។ ប៉ុន្តែទីផ្សារមូលបត្រប្រតិស្រុត ឬ **គ.ម.ក.** អាចពិនិត្យ និងតម្រូវឱ្យផ្សព្វផ្សាយជាសាធារណៈបាន ករណីយល់ឃើញថាដើម្បីការពារផលប្រយោជន៍វិនិយោគិន។

ក្នុងករណីចាំបាច់និងបន្ទាន់ ការផ្តល់ព័ត៌មានសាជីវកម្មស្របតាមប្រកាសនេះ អាចធ្វើឡើងដោយផ្ទាល់មាត់ ឬតាមរយៈទូរសព្ទ ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិច និងត្រូវធ្វើជាលាយលក្ខណ៍អក្សរភ្លាម។

**ប្រការ ២១.- ការពិនិត្យ និងផ្សព្វផ្សាយព័ត៌មានដែលទទួលបានពីបុគ្គលចុះបញ្ជីលក់មូលបត្រ**

ទីផ្សារមូលបត្រប្រតិស្រុតត្រូវពិនិត្យភ្លាមលើព័ត៌មានដែលទទួលបាន ដូចមានចែងក្នុងប្រការ ៦ ប្រការ ១៦ និងប្រការ ១៧ នៃប្រកាសនេះ មុននឹងផ្សព្វផ្សាយដល់វិនិយោគិន។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវពិនិត្យភ្លាមលើព័ត៌មានដែលទទួលបាន ក្រៅពីព័ត៌មានដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ មុននឹងសម្រេចបញ្ជូនទៅទីផ្សារមូលបត្រប្រតិស្រុត ដើម្បីផ្សព្វផ្សាយដល់វិនិយោគិន។

ទីផ្សារមូលបត្រប្រតិស្រុត ឬអគ្គនាយកនៃ **គ.ម.ក.** អាចស្នើសុំឱ្យបុគ្គលចុះបញ្ជីលក់មូលបត្រផ្តល់ឯកសារចាំបាច់ និង/ឬអាចចុះធ្វើការត្រួតពិនិត្យដល់ទីកន្លែង ដើម្បីពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានសាជីវកម្មដែលផ្តល់ដោយបុគ្គលចុះបញ្ជីលក់មូលបត្រ ឬដើម្បីពង្រឹងការអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងប្រកាសនេះ។ ករណីនេះ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់កិច្ចសហការ និងផ្តល់ឯកសារភ្លាមដោយគ្មានការយឺតយ៉ាវ។

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្សព្វផ្សាយភ្លាមរាល់ព័ត៌មានសាជីវកម្ម តាមរយៈគេហទំព័ររបស់ខ្លួនបន្ទាប់ពីព័ត៌មាននោះត្រូវបានផ្សព្វផ្សាយដោយទីផ្សារមូលបត្រប្រតិស្រុត ហើយធានាថាគេហទំព័រនោះត្រូវមានផងដែរនូវផ្នែកទំនាក់ទំនងវិនិយោគិន (Investor Relations) ក្នុងវិស័យមូលបត្រ ដោយមានបញ្ជាក់លេខទូរសព្ទ សារអេឡិចត្រូនិចរបស់បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន និងប្រអប់សំណួរ-ចម្លើយ ដើម្បីឱ្យវិនិយោគិនអាចសាកសួរព័ត៌មានពាក់ព័ន្ធ។

**ប្រការ ២២.- ការប្រែប្រួល ឬការកែតម្រូវព័ត៌មានដែលបានបង្ហាញរួច**

ករណីមានការប្រែប្រួល ឬការកែតម្រូវព័ត៌មានដែលបានបង្ហាញរួច បុគ្គលចុះបញ្ជីលក់មូលបត្រ ត្រូវផ្តល់ព័ត៌មានលម្អិតអំពីការប្រែប្រួល ឬការកែតម្រូវនោះភ្លាមជូនទីផ្សារមូលបត្រប្រតិស្រុត ឬ **គ.ម.ក.** ដើម្បីផ្សព្វផ្សាយជាសាធារណៈ និងទទួលខុសត្រូវលើព្យសនកម្មដែលបង្កឡើងដោយការបង្ហាញព័ត៌មានខុសនោះ ប្រសិនបើមាន។

**ប្រការ ២៣.- កាតព្វកិច្ចជូនដំណឹងរបស់ទីផ្សារមូលបត្រប្រតិស្រុត**

ករណីបុគ្គលចុះបញ្ជីលក់មូលបត្របានប្រព្រឹត្តបំពានកាតព្វកិច្ចផ្តល់ព័ត៌មាន ដូចមានចែងក្នុងប្រការ ៦ ប្រការ ១៦ និងប្រការ ១៧ នៃប្រកាសនេះ ទីផ្សារមូលបត្រប្រតិស្រុតត្រូវជូនដំណឹងដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរជាបន្ទាន់ ទៅ **គ.ម.ក.** ដើម្បីពិនិត្យ និងចាត់វិធានការ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៤

## កាតព្វកិច្ចក្នុងការអនុវត្តការផ្តល់ព័ត៌មាន

**ប្រការ ២៤.- កាតព្វកិច្ចរបស់បុគ្គលចុះបញ្ជីលក់មូលបត្រក្នុងការអនុវត្តការផ្តល់ព័ត៌មាន**

បុគ្គលចុះបញ្ជីលក់មូលបត្រ ត្រូវ÷

១- ធានាថាយន្តការនៃការផ្តល់ព័ត៌មានមានប្រសិទ្ធភាព និងនិរន្តរភាព។

២- ធានាថារាល់ព័ត៌មានដែលផ្តល់ជូនទីផ្សារមូលបត្រប្រតិស្រុត និង/ ឬ **គ.ម.ក.** មានភាពត្រឹមត្រូវ ច្បាស់លាស់ ពេញលេញ និងទាន់ពេលវេលា ដោយមិនត្រូវមានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស។ រាល់ព័ត៌មានដែលផ្តល់ជូនទីផ្សារមូលបត្រប្រតិស្រុត និង/ ឬ **គ.ម.ក.** ត្រូវស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៣- ការពារ និងរក្សាទុករាល់ព័ត៌មានដែលត្រូវបង្ហាញដូចមានចែងក្នុងជំពូកទី២ នៃប្រកាសនេះ ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ។

៤- ផ្តល់ព័ត៌មានបន្ថែម និងឯកសារចាំបាច់ផ្សេងៗតាមការស្នើសុំរបស់ទីផ្សារមូលបត្រប្រតិស្រុត ឬអគ្គនាយកនៃ **គ.ម.ក.**។

៥- ធានាថាព័ត៌មានសាជីវកម្មដូចមានចែងក្នុងជំពូកទី២ នៃប្រកាសនេះ មិនត្រូវផ្សព្វផ្សាយជាសាធារណៈ នោះក្នុងរូបភាពណាក៏ដោយ មុនពេលទទួលបានការអនុញ្ញាតពីទីផ្សារមូលបត្រប្រតិស្រុត ឬអគ្គនាយកនៃ **គ.ម.ក.**។

៦-មានក្រមសីលធម៌ និងវិធាននៃផ្ទៃក្នុង ពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានសាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

**ប្រការ ២៥.-កាតព្វកិច្ចរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់**

អភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន ៖

១-ត្រូវរក្សាការសម្ងាត់នូវរាល់ព័ត៌មានសាជីវកម្មដូចមានចែងក្នុងជំពូកទី២ នៃប្រកាសនេះ ដោយមិនត្រូវធ្វើឱ្យលេចធ្លាយ ឬផ្សព្វផ្សាយ រហូតដល់ព័ត៌មាននោះត្រូវបានផ្សព្វផ្សាយជាសាធារណៈអនុលោមតាមប្រកាសនេះ។

២-ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមក្រមសីលធម៌ និងវិធាននៃផ្ទៃក្នុងពាក់ព័ន្ធនឹងការបង្ហាញព័ត៌មានសាជីវកម្ម។

៣-មិនត្រូវអនុវត្តការងារណាដែលនាំឱ្យមានទំនាស់ផលប្រយោជន៍។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវផ្តល់ព័ត៌មានសាជីវកម្មដល់បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន និងត្រូវទទួលខុសត្រូវលើការផ្តល់ព័ត៌មានរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

## ជំពូកទី ៥

## ទោសប្បញ្ញត្តិ

**ប្រការ ២៦.-ពិន័យអន្តរការណ៍**

ដោយមិនគិតពីទោសទណ្ឌផ្សេងទៀត ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា បុគ្គលចុះបញ្ជីលក់មូលបត្រ និង/ឬបុគ្គលពាក់ព័ន្ធ ដែលល្មើសនឹងកថាខណ្ឌទី១,២,៣ ឬ៤ នៃប្រការ៦ ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ កថាខណ្ឌទី៥ នៃប្រការ៦ ករណីចុះបញ្ជីលក់មូលបត្របំណុល កថាខណ្ឌទី១ នៃប្រការ៧, ប្រការ៨, ប្រការ៩, ប្រការ១០, កថាខណ្ឌទី១,២,៣ ឬទី៤ នៃប្រការ១១, កថាខណ្ឌទី២ នៃប្រការ១៥, ប្រការ១៦ , ប្រការ១៨ , ប្រការ២០ , កថាខណ្ឌទី១ , ៣ ឬទី៤ នៃប្រការ២១, ប្រការ២២, ប្រការ២៣, ប្រការ២៤ ឬប្រការ២៥ នៃប្រកាសនេះ ឬមិនគោរពតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.** ឬបន្តប្រព្រឹត្តល្មើសដដែល ឬប្រព្រឹត្តល្មើសករណីផ្សេងទៀត ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការ ២៧ នៃប្រកាសនេះ និង/ឬទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់មិនលើសពី ៥០០.០០០.០០០ (ប្រាំរយលាន) រៀល។

**ប្រការ ២៧.-ទណ្ឌកម្មរដ្ឋបាល**

បុគ្គលចុះបញ្ជីលក់មូលបត្រនិង/ឬបុគ្គលពាក់ព័ន្ធ ដែលល្មើសនឹងកថាខណ្ឌទី៣នៃប្រការ៧, ប្រការ១២, ប្រការ១៣, ប្រការ១៤, កថាខណ្ឌទី១ នៃប្រការ១៥, កថាខណ្ឌទី២ ឬទី៣ នៃប្រការ១៧ ឬប្រការ១៩ នៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលពី **គ.ម.ក.**។

អគ្គនាយកនៃ **គ.ម.ក.** អាចដាក់ទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

១-ព្រមាន ឬដាស់តឿន។

២-ការស្នើឱ្យដាក់អនុស្សារណៈ។

៣-ការកត់សម្គាល់ជាសាធារណៈ ហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤-ដាក់កំហិតលើការបោះផ្សាយលក់មូលបត្រ។

៥-ការផ្តល់អនុសាសន៍លើការបណ្តេញចេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន។

៦-ការប្រកាសជាសាធារណៈនូវទណ្ឌកម្មរបស់បុគ្គលដែលប្រព្រឹត្តល្មើសច្បាប់និងបទប្បញ្ញត្តិជាធរមាន។

៧-ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្រ ឬការចែកចាយបន្ទាប់។

## ជំពូកទី ៦

## អន្តរប្បញ្ញត្តិ

### ប្រការ ២៨-ការអនុវត្តកាតព្វកិច្ចផ្តល់ព័ត៌មានជាភាសាអង់គ្លេស

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវចាប់ផ្តើមអនុវត្តការផ្តល់ព័ត៌មានជាភាសាអង់គ្លេស ដូចមានចែងក្នុងប្រកាសនេះ បន្ទាប់ពីមានការជូនដំណឹងពីទីផ្សារមូលបត្រប្រតិស្រុត ឬ **គ.ម.ក.**។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

### ប្រការ ២៩.-ការចេញគោលការណ៍ណែនាំ និងទម្រង់ក្នុងការបង្ហាញព័ត៌មាន

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំ និងទម្រង់ក្នុងការបង្ហាញព័ត៌មាន ស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់បុគ្គលចុះបញ្ជីលក់មូលបត្រ ឬបុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រប្រតិស្រុតនិងសាធារណជន។

### ប្រការ ៣០.-បរិវាទកម្ម

ប្រកាសលេខ ០០២/១២ គ.ម.ក/ប្រក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម ត្រូវទុកជានិរាករណ៍។

**ប្រការ ៣១.- ការអនុវត្ត**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៣ រោច ខែទុតិយាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៣១

"ដើម្បីអនុវត្ត"

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ